# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣៧ លេខ ៣ ខែ មីនា

ព.ស. ២៥០៧ គ.ស. ១៩៦៥

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

បេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ផ្នែកសាសនា ទំព័រ

១– អំពីទេវតា (វិចារណកថា) លោក ផេង - ជ្រីវ រៀបរៀង (ត–ចប់) . . . ២១៩
២– សាមគ្គីធម៌ សម្ដេចព្រះពោធិវ័ង្ស រៀបរៀង . . . . . . ២២៦
៣– ការត្រាស់ដឹងនៃព្រះសម្ពុទ្ធ ព្រះមហា ប៉ាង ខាត់ រៀបរៀង (ត–ចប់) . . ២៣៥
៤– ធម៌គ្រប់គ្រងលោក លោក ប៊ូ ប៉ូ រៀបរៀង . . . . . . ២៤៦
៥– អំពីគិហិវត្ត ព្រះមុនីកោសល សូរ ហាយ រៀបរៀង . . . . . ២៥២

ផ្នែកអក្សរសាស្ត្រ

៦ - វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង–ខាត់ រៀបរៀង (ត) . . . ២៦២
៧– បរមាធិប្បាយអំពីសុភ កុសលានុរក្ខិតោ ភិក្ខុ ឡាយ ត្រី ហៅ ភូ រៀបរៀង . . ២៦៤
៨– ក្រមួនលាបមាត់ លោក មាស ហាំ រៀបរៀង . . . . . . ២៨០
៩– វិវត្តន៍នៃអក្សរខ្មែរ លោក ឱ. គាម រៀបរៀង . . . . . . ២៨៥
១០– រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ កន ប្រែរៀបរៀង(ត) . . . ២៩៣
១១ រឿងចៅរលាជ្ជូង លោក ឱ. គាម ស្រាវជ្រាវនិងរៀបរៀង (ត) . . . ២៩៨
១២– ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឱ. គាម ស្រាវជ្រាវ (ត) . . . . . ៣០៣

ផ្នែកកំណត់ទិនប្រវត្តិការណ៍

១៣– ពិធីបុណ្យបូជាសព និង ការតាំងចៅអធិការ និង ឧបជ្ឈាយ៍ . . . . ៣១១

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០រ០០ ។

# ផ្នែកសាសនា

ពាក្យឃាតមិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អទៅ,
ឲ្យដុសខាតចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ·
ប.ព.

## អំពីទេវតា

(វិចារណកថា)

លោក ផេង ជ្រឹវ រៀបរៀង

មានអ្នកខ្លះទៅបន់ស្រន់ អ្នកតាកន្លែងនេះ អ្នកខ្លះទៅបន់ស្រន់យាយទេពកន្លែងនោះ អ្នកខ្លះទៀតទៅសំពះបន់ស្រន់ព្រាយទេសបារមីកន្លែងដទៃទៀតដែលល្បីថាពូកែ សុំឲ្យជួយគាំពារខ្លួនក្នុងការរកទទួលទាន សុំឲ្យជួយខ្លួនក្នុងការព្យាបាលរោគកូនប្រពន្ធឪពុកម្ដាយ សុំឲ្យជួយគាំពារខ្លួនក្នុងការប្រឡង សុំឲ្យជួយគាំពារខ្លួនក្នុងការលេងល្បែងស៊ីសង មានបៀ ផ្ទះ កន្ទុយលេខជាដើម សុំឲ្យជួយគាំពារខ្លួនក្នុងការទិញឆ្នោត ។ល។ ហើយតាំងសច្ចាថាបើបានសម្រេចដូចបំណង នឹងថ្វាយវត្ថុនេះវត្ថុនោះ ជាអាទិ៍ គឺស្លាធម៌បួន ប្រាក់ កោរសក់ អង្ករ ។ល។

សួរថា: អ្នកបន់ស្រន់ទាំងនេះ បានទទួលលទ្ធផលគ្រប់គ្នាដូចសេចក្ដីបន់ស្រន់ឬទេ ?

ឆ្លើយថា: បើតាមដែលបានដឹង គឺមានបានខ្លះ តែគាត់គិតណាស់ចំពោះដង្វាយដែលថានឹងត្រូវថ្វាយនោះ អ្នកបន់ស្រន់មិនដែលហ៊ានខានឡើយ ទោះជាបានក្តី មិនបានក្តី ព្រោះខ្លាចវត្ថុតាំងនោះធ្វើបាបដល់ខ្លួនៗ

ឥឡូវសូមយកបញ្ហាបានឬមិនបាននេះមកពិចារណាដោះស្រាយ ៗ ដែលបាននោះ មកពីវត្ថុតាំងនេះផ្តល់ឲ្យតាមសេចក្តីបន់ស្រន់មែនឬយ៉ាងណា? ដែលមិនបាននោះ មកពីវត្ថុនេះមិនព្រមផ្តល់ឲ្យ ព្រោះមិនពេញចិត្ត ឬខឹងនឹងអ្នកបន់ស្រន់នោះឬយ៉ាងណា ?

ខ្ញុំយល់ថា ដែលបានក្តី ដែលមិនបានក្តី មិនមែនមកពីវត្ថុនេះឡើយ ព្រោះកុំតែពេលដែលគេបន់នោះ មិនដែលឃើញឬ មិនដែលឮវត្ថុស័ក្តិសិទ្ធិ ពោលប្រាប់ថាអញជួយឯង ឬអញមិនជួយឯងនោះសោះឡើយ អើ! ដែលឃើញតែមនុស្ស ដែលគេសន្មតថាជាតួរូបសម្រាប់ឲ្យវត្ថុស័ក្តិសិទ្ធិ សណ្ឋិតចូលនោះពិតមែន ៗ រឿងនេះ បើតាមការពិសោធន៍មិនប្លែកគ្នាពីរឿងទេវតាឡើយ ៗ បើនិយាយយ៉ាងខ្លីថា វត្ថុអស់នេះមិនមានសមត្ថភាពអ្វីបន្តិចបន្តួចនឹងជួយមនុស្សឡើយ ៗ ដែលបានគឺបានដោយខ្លួនឯង ដែលមិនបាន គឺមិនបានដោយខ្លួនឯង ៗ

យើងធ្លាប់ឃើញស្រាប់ តែកន្លែងណា តែដំបន់ណា តែប្រទេសណា មានអ្នកខ្លាំងពូកែ មានខ្លះមានរិទ្ធិអំណាច មានអ្នកមានបុណ្យដូចជាតួអង្គសម្តេចព្រះ នរោត្តម-សីហនុ ឧបយុវរាជ ព្រះប្រមុខរដ្ឋប្រទេស

កម្ពុជា អ្នកនៅជិតខាងព្រះអង្គ ប្រជារាស្ត្រជាកូនចៅព្រះអង្គ រមែងតែបានទទួលសេចក្ដីសុខ សេចក្ដីចំរើន ពីព្រះអង្គជាធម្មតា ប្រទេសជិតខាងកើតចម្បាំងកាប់សម្លាប់គ្នា ប្រទេសកម្ពុជាមានសន្តិសុខបរិបូណ៌ ទាល់តែមាននាមថា ''កោះសន្តិភាព'' (សង្គមរាស្ត្រនិយម) ។ ប្រសិនបើវត្ថុស័ក្ដិសិទ្ធិនោះ ៗ ពិតជាមានសមត្ថភាព ពិតជាមានឫទ្ធិអំណាច អាចផ្ដល់អ្វីបានតាមសេចក្ដីបន់ស្រន់មែន ហេតុអ្វីអ្នក ''ដើរព្រះ'' អ្នកដំបន់ជាមួយក៏នៅតែរហេមរហាម ។ ខ្ញុំបានសង្កេតឃើញជាក់នឹងភ្នែកនូវការរយីករយោក នូវការមិនសមរម្យនេះ នៃអ្នកដើរព្រះ នៃអ្នកដំបន់របស់វត្ថុស័ក្ដិសិទ្ធិនោះ ៗ ។ សព្វថ្ងៃ មិនត្រឹមតែគ្រហស្ថទេដែលប្រកាន់ជំនឿស្មោកគ្រោកនេះ សូម្បីព្រះសង្ឃខ្លះក៏នៅយល់ដោយឥតពិចារណាថាជាការណ៍ស័ក្ដិសិទ្ធិដែរ ហើយព្រះសង្ឃនេះ ថែមទាំងតាំងខ្លួនជាដើរព្រះថែមទៀតផង ។

គួរឲ្យអៀនខ្មាសពេក តែកាលណាបានឃើញភ្ញៀវចូលទៅក្នុងព្រះវិហារ ចូលទៅជិតពេង ឬតូបអ្នកតា អ្នកដើរព្រះ ភាគច្រើន គឺស្ត្រីស្លៀកពាក់មិនជាបើបី មានកាន់ដើរស្រាពដាក់ខ្សែក ខ្សែចង្កេះ និងគាថាមួយ ១ ម្នាក់ ស្ទុះមកធ្វើបដិសណ្ឋារកិច្ច ដូចអ្នកសុំទាន ដោយពោលអួតថាទុកឲ្យខ្ញុំជួយបន់ បើខ្ញុំបន់ហើយទៀងតែនឹងបានសម្រេចដូចសេចក្ដីប្រាថ្នា ។ រួចបើភ្ញៀវយល់ព្រមថាត្រូវពឹងខ្លួនមែន អ្នកនេះស្រាប់តែ

អរកខិបកខុប កន្ត្រាក់យកជើងពានមកអុជធូបអុជទៀន សម្រឹងស្មឹងស្មាធិ៍ ធ្វើជាចូល ប្រើសំឡេងខ្មោចមួយរំពេច ភ្នែកក្រឡិបក្រឡាប់មូលផុចកាក់ ញាក់ទទ្រើក ខ្លះស្ទុះឡើងទៅកៀកព្រះសូរងព្រះពុទ្ធរូបឥតខ្លាចបាប ដៃពាំពើន សំឡឹងចំមករកភ្ញៀវ ធ្វើទឹកមុខម្តងក្រញូវ ម្តងញញឹម មួយសន្ទុះក្រោយមក គេក៏ចេញ ឬចុះមកវិញ ហើយប្រាប់ថាព្រះអង្គព្រមជួយហើយ លោកយាយស្រឡាញ់លោកណាស់ លោកទៀងតែឡើងបុណ្យសក្តិទៀតជាប្រាកដ ។ល។ ភ្ញៀវខ្លះជាអ្នកទ្រើស លុះបានឮពាក្យបញ្ចោរបោកបញ្ឆោតដូច្នោះ ក៏សប្បាយចិត្តពន់ពេក ហូតលុយពីហោប៉ៅហុចឲ្យទៅភ្លាម ដោយសង្ឃឹមថាទៀងតែនឹងបានសម្រេចដូចបំណង ។

មិនតែប៉ុណ្ណោះ ពួកជើងព្រះទាំងនោះ ជួនកាលមានការអាក់អន់ចិត្តរវាងគ្នានឹងគ្នាផងក៏មាន ព្រោះតែរឿងដណ្តើម «ម៉ូយ» ។

គួរឲ្យអស់សំណើចណាស់ បើព្រះអង្គរបស់ខ្លួន បើយាយទេពឬអ្នកតារបស់ខ្លួនពូកែមែន ហេតុដូចម្តេចក៏មិនបន់ស្រន់យកខ្លួនឯង ទុកមុនជាគំរូឲ្យហើយទៅ ក៏ឃើញតែនៅរហេមរហាម រយីករយាក ដែលជាហេតុផ្ទុយនឹងការណ៍ពិតទៅវិញ ឬព្រះអង្គហ្នឹង យាយទេពហ្នឹង អ្នកតាហ្នឹងក៏ចិត្តអាក្រក់ម្ល៉េះ ចំពោះតែកូនចៅខ្លួន ។

គេអាចឆ្លើយប្រឆាំងមកវិញថា: ដែលព្រះអង្គ . . . អាចជួយបាន ចំពោះតែអ្នកណាដែលមានវាសនាទេ ខ្លួនជាជើងព្រះក៏ដោយ

បើគ្មានវាសនា ព្រះអង្គ .... ជួយមិនបានទេ ។ អ្នកណាមិនចង់មាន មិនចង់បាន មិនចង់ធ្វើ ?

ចម្លើយនេះឃើញថាត្រឹមត្រូវពិតប្រាកដមែន តែត្រូវតែទៅលើខុស ។

សួរថា: យ៉ាងដូចម្តេច បានជាត្រូវទៅលើខុស ?

ឆ្លើយថា: ដែលថាត្រូវទៅលើខុសនោះ ព្រោះវាសនាមិនមែនផ្តល់ផលយើងដោយគ្មានធ្វើឡើយ ឬក៏ដោយសារតែការបន់ស្រន់នោះទេ ។ អ្វីៗ ទាំងអស់ គឺសម្រេចទៅលើ «កម្ម» ទាំងស្រុង ដែលប្រែមកថា «ធ្វើ» គឺថាអ្វីទាំងអស់កើតមកតែពីធ្វើ បើគ្មាន «ធ្វើ» គឺគ្មាន «ផល» ។ ហើយធ្វើនេះទៀត ត្រូវប្រព្រឹត្តដោយខ្លួនឯង ទើបបានសម្រេចផលយ៉ាងគាប់ប្រសើរបំផុត ។

ព្រះពុទ្ធបរមគ្រូ ទ្រង់ត្រាស់សំដែងថា; «អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា ....» ប្រែថា ខ្លួនត្រូវទីពឹងខ្លួន អ្នកដទៃណានឹងជាទីពឹងប្រសើរជាងខ្លួន ។

អ្នកកវីជាតិបារាំងឈ្មោះឡាហ្វុងតែនពោលថា: «aide toi, le ciel t'aidera» ប្រែថា «ជួយខ្លួនឯង ទើបទេវតាជួយ» បានន័យថាត្រូវខំប្រឹងធ្វើដោយខ្លួនឯងទៅ គង់នឹងបានសម្រេចជាប្រាកដ ។

សម្តេចសហជីវិន ព្រះប្រមុខរដ្ឋកម្ពុជា ក្នុងវិធីកសាងប្រទេសជាតិទ្រង់មានព្រះបន្ទូលឲ្យដាក់ពាក្យស្លោកថា: «កម្ពុជា ជួយខ្លួនដោយខ្លួនឯង» ។

គឺថាត្រូវតែខ្មែរជួយខ្មែរ ទើបប្រទេសជាតិ នឹងបានដល់នូវវឌ្ឍនភាព ទោះបីមានជំនួយខ្លះពីបរទេសក៏ដោយ ។

សព្វថ្ងៃ ប្រទេសទាំងអស់ក្នុងសកលលោក ទោះបីខាងអឺរុបក្តី ខាងអាស៊ីក្តី តែងយល់ដូចគ្នាទាំងអស់ គឺថាផលកើតមកតែពី "ធ្វើ" ។ ដូច្នេះហើយ ទើបប្រទេសចិនដែលកាលពីដើម ប្រជារាស្ត្រភាគច្រើនស៊ីតែបបរនោះ បានញ៉ាំងផលិតផលឲ្យកើតមានយ៉ាងបរិបូណ៌ ហើយប្រជារាស្ត្រទៀតក៏មានឋានៈជីវភាពខ្ពស់ជាងពីសម័យមុន ៗ ប្រទេសចិនប្រជាមានិតទុកផ្ទះអ្នកតា ទុកហ៊ិងស៊ុយជារឿងព្រេងអស់ទៅហើយ ។

ពាក្យភាសិតដ៏ប្រសើរក្រៃលែងទាំងបីខាងលើ បញ្ជាក់ឲ្យឃើញថា គ្មានទេវតា អារក្ស អ្នកតា ព្រាយបិសាចណា អាចជួយមនុស្សបានឡើយ មានតែមនុស្សជួយមនុស្ស ទើបអាចកើតផលប្រយោជន៍ចំពោះខ្លួនបាន ។ អេ! បើឲ្យមនុស្សជួយទេវតា អារក្ស អ្នកតា . ដោយឧទ្ទិសផលកុសល ដែលខ្លួនបានធ្វើទៅឲ្យនោះ ប្រហែលជាមានបានសម្រេចខ្លះទៅវិញ ព្រោះអមនុស្សទាំងនេះ គ្មានអ្វីយកមកធ្វើកុសលទេ ហើយកន្លែងធ្វើកុសលក៏គ្មានដែរ ។

សម្រេចសេចក្តីទៅ: ការបន់ស្រន់ ការបួងសួង ការសំបូងសម្រួង នឹងការឲ្យពរសព្ទសាធុការ គេធ្វើ គ្រាន់តែជាការសំដែងសេចក្តីគួរសម អនុលោមទៅតាមទំនៀមទម្លាប់ប្រពៃណីសម្រាប់ប្រទេសតែប៉ុណ្ណោះ ។

តែបើជនណាយល់ថាអំពើទាំងនេះ អាចផ្តល់ផលដល់អ្នកទទួលនឹងដល់អ្នកធ្វើមែន ជននោះឈ្មោះថាយល់ដោយក័ន្តច្រឡំជាពិតប្រាកដ ។

តាមការសង្កេត ភូមិណា ដំបន់ណា ប្រទេសណា ដែលមានការបេះដឹងអនថ់យ ភូមិនោះ ដំបន់នោះ ប្រទេសនោះ ច្រើននិយមការបន់ស្រន់ និងបួងសួងជាធម្មតា ។

> ជោគលាភ តែងចូលទៅរកបុរសសីហៈ ដែលជាអ្នកមានព្យាយាមក្លៀវក្លា មានតែបុរសគម្រក់ទេ តែងពោលថា «ស្រេចតែព្រេងសំណាង» បុគ្គលប្ដូរផ្ដាញ់វាសនា ហើយធ្វើខ្លួនព្យាយាមឲ្យពេញជាកូនប្រុសតាមកំលាំងខ្លួនដែលអាចធ្វើបាន ថាៈបើព្យាយាមប្រឹងប្រែងធ្វើហើយ នៅតែមិនសម្រេចទៀត គេវាទឹងកើតទោសអ្វី ?
>
> ——ស្រីហិតោបទេស——

# សាមគ្គីធម៌

សម្តេចព្រះពោធិវង្ស ហៀ រៀង

## នមត្ថុ រតនត្តយស្ស

សូមនមស្ការដោយគោរព ចំពោះព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។

លំដាប់អំពីនេះ ខ្ញុំករុណា អាត្មា សូមសំដែងអំពីសាមគ្គីធម៌ជូនអស់លោក-អ្នកទាំងឡាយ ជាសេចក្តីសង្ខេបឲ្យសមដល់កាលវេលា ។ មុនដំបូងសូមលើកយកពាក្យថាសាមគ្គីមកចែកចេញជាប្រភេទគឺ :

១– សាមគ្គី ការព្រមព្រៀងគ្នា,

២– សាមគ្គីធម៌ ច្បាប់សម្រាប់ប្រតិបត្តិ ឲ្យមានការព្រមព្រៀងគ្នា,

៣– សាមគ្គីភាព បែបបទ ឬរបៀបការព្រមព្រៀងគ្នា,

៤– សាមគ្គីរស រសជាតិរបស់ការព្រមព្រៀងគ្នា,

៥– សាមគ្គីរសានិសង្ស អានិសង្សនៃសាមគ្គីរស គឺផលដែលកើតអំពីការព្រមព្រៀងគ្នា, ជារសឆ្ងាញ់ក្រៃលែង ។

ទាំង ៥ នេះ មានសាមគ្គីជាមូលដ្ឋាន គួរជ្រាបថាសាមគ្គីគឺការព្រមព្រៀងគ្នាត្រូវមានសាមគ្គីធម៌ គឺច្បាប់សម្រាប់ប្រតិបត្តិឲ្យកើតមានសាមគ្គី-ភាព គឺបែបបទ ឬរបៀបនៃការព្រមព្រៀងគ្នា, សាមគ្គីភាពបង្កើតឲ្យមាន

សាមគ្គីរស គឺរសជាតិនៃការព្រមព្រៀងគ្នា ដែលនាំឲ្យពេញចិត្តស្រឡាញ់រាប់អានគ្នា, សាមគ្គីរសនេះបង្កើតទៅជាសាមគ្គីរសាទិសង្ឃ ដែលជាផលសម្រេចតាមគោលបំណង ។ ព្រោះហេតុនោះសាធុជនគួរជ្រាបលក្ខណៈធម៌ទាំង ៤ នេះឲ្យជាក់ច្បាស់ គឺគួរជ្រាបថា សាមគ្គីរសាទិសង្ឃកើតមាន ព្រោះអាស្រ័យសាមគ្គីរស ១ កើតមាន ព្រោះអាស្រ័យសាមគ្គីភាព ១ កើតមាន ព្រោះអាស្រ័យសាមគ្គីធម៌ ដែលជាច្បាប់ប្រាប់របៀបបែបបទ នៃសាមគ្គី ១ នេះ ជាមូលដ្ឋានដើម ។

ឥឡូវនេះ ខ្ញុំករុណា អាត្មា នឹងសំដែងអំពីសាមគ្គីធម៌តទៅ, សូមនាំយកពុទ្ធភាសិតមកតំកល់ទុកជាគោលថា :

សុខា សង្ឃស្ស សាមគ្គី
សមគ្គានំ តបោ សុខោ

„ការព្រមព្រៀង នៃពួកក្រុម នាំឲ្យមានសុខស្រួល, សេចក្ដីព្យាយាមរបស់អ្នកដែលមានការព្រមព្រៀងគ្នា នាំឲ្យបានសុខស្រួល” នេះជាឱវាទនៃព្រះសក្យមុនីគោតមបរមគ្រូរបស់យើង ។

## អធិប្បាយសង្ខេប

មនុស្សដែលមានចំនួនតាំងពីបួនប្រាំនាក់ឡើងទៅ រហូតរាប់រយរាប់ពាន់នាក់ហៅថាពួកបក្រុម ១ នេះ បើហៅតាមភាសាបាលីថា „សង្ឃ” ទោះបព្វជិត គ្រហស្ថក្ដី ដែលមានចំនួនច្រើនហៅថា „សង្ឃ” ប្រែថា

ពួក ឬក្រុម(១) ៗ ក្នុងពួកក្រុមនីមួយ ៗ បើមានសាមគ្គី គឺការព្រមព្រៀងគ្នា ទើបបានសេចក្ដីសុខ ៗ ឯសេចក្ដីសុខនោះគឺស្រួល ឥតលំបាកចិត្ត ឥតតាស់តែងគ្នា ឥតមានហេតុដែលនាំឲ្យស្អុះស្អាប់ក្នុងចិត្ត ៗ

ពួកក្រុមដែលមានការព្រមព្រៀងគ្នា ត្រូវការព្យាយាមបំពេញកណីយ-កិច្ចណាមួយ សេចក្ដីព្យាយាមនោះ នឹងនាំឲ្យបានសុខស្រួលទៀត គឺថា នឹងបានសម្រេចតាមបំណង ឥតមានឧបសគ្គណាមួយមកស្កាក់ដំណើរ បានឡើយ ព្រោះសាមគ្គីជាគ្រឿងឧបករណ៍ ១ ដ៏ធំក្រៃលែង នឹងជាកម្លាំង ១ ដ៏ខ្លាំងក្លាបំផុត ឬជាអាវុធ ១ ដ៏សក្ដិសិទ្ធិបំផុត ៗ

សេចក្ដីដែលពោលខាងលើនេះឃើញថាការព្រមព្រៀងគ្នា ជាបំណុច សំខាន់ក្នុងពួកក្រុមនីមួយ ៗ, ចុះការព្រមព្រៀងគ្នានោះ តើដូចម្ដេច? ការព្រមព្រៀងគ្នានោះមាន ៣ យ៉ាងគឺ :

១– ការព្រមព្រៀងគ្នាដោយកាយ ហៅថា «កាយសាមគ្គី»

២– ការព្រមព្រៀងគ្នាដោយវាចា ហៅថា «វចីសាមគ្គី»

៣– ការព្រមព្រៀងដោយចិត្ត ហៅថា «មនោសាមគ្គី ឬចិត្តសាមគ្គី»

ការព្រមព្រៀងគ្នាដោយកាយ បានសេចក្ដីថាក្នុងពួក ឬក្រុមនីមួយៗ ដែលជាសង្គមតូច ឬធំ កាលបើមានកិច្ចការអ្វីនីមួយដែលត្រូវធ្វើរួមគ្នា, ឥតមានអ្នកណាមួយហ៊ានសម្ងំលាក់ខ្លួនឡើយ គឺទៅរួបរួមជាមួយគ្នា

---

១ សង្ឃ. ស័ព្ទនេះ ប្រែថា ពួក,ក្រុម,ហ្វូង,។ល ដូចជាភិក្ខុសង្ឃ ពួកភិក្ខុ ឬ ក្រុមភិក្ខុ មិគសង្ឃ ពួកម្រឹគ ឬហ្វូងម្រឹគ: សកុណសង្ឃ ហ្វូងសត្វស្លាបជាដើម ។

ជួយបំពេញកិច្ចការនោះ តាមកាលវេលាដែលបានកំណត់ទុក វៀរលែងតែមានធុរៈផ្ទាល់ខ្លួន ជាធុរៈចាំបាច់ហើយ បានឲ្យដំណឹងជាមុន ។

ការព្រមព្រៀងគ្នាដោយវាចា បានសេចក្ដីថា ក្នុងឱកាសដែលពួកក្រុមមានការប្រជុំ បញ្ចេញយោបល់រៀងខ្លួន ចំពោះកិច្ចការណាមួយដែលត្រូវបង្កើតត្រូវធ្វើ, ប្រជុំជនក្នុងពួកក្រុមនោះ ចេះស្ដាប់គ្នាទៅវិញទៅមក បើឃើញថាអ្នកណាមានវាចាសមតាមហេតុផលហើយ ក៏អនុលោមតាមភ្លាម មិនមានគំនិតគិតប្រឆាំង ហើយចេះតែស្រែកតវ៉ាដោយមិនសមតាមហេតុផលឡើយ ។ បើអ្នកណាម្នាក់ ស្ដាប់ទីប្រជុំដែលថ្លែងសេចក្ដីនោះមិនពេញចិត្តខ្លួន ក៏សូមឱកាសថ្លែងឲ្យទីប្រជុំស្ដាប់យោបល់របស់ខ្លួន ទោះបីគេទទួលយក ឬមិនទទួល ក៏មិនអាក់អន់ស្រពន់ចិត្ត ។ មនុស្សភាគតិចក្នុងទីប្រជុំ ត្រូវអនុលោមស្របតាមមនុស្សភាគច្រើនជាដរាប ។

ការព្រមព្រៀងដោយចិត្ត បានសេចក្ដីថា មានចិត្តស្មើគ្នា មានអធ្យាស្រ័យត្រូវគ្នា មិនធ្វើចិត្តឲ្យបែកកន្ទែកចេញពីគ្នា មិនតាំងចិត្តដណ្ដើមប្រជែងយកឈ្នះគ្នា គឺធ្វើចិត្តឲ្យស្របរួមជាមួយគ្នា ។ ការធ្វើចិត្តដូច្នេះជាការកម្រណាស់ ព្រោះតាមគម្ពីរក្នុងព្រះពុទ្ធសាសនាថា មនុស្សក្នុងលោកសន្និវាសនេះ នានត្តកាយា នានត្តសញ្ញី គឺមានកាយក៏ផ្សេងគ្នា ចិត្តក៏ផ្សេងគ្នាដែរ ទាំងកាយទាំងចិត្តមិនដូចគ្នាទេ ។ នេះជាសេចក្ដីពិតមែន ព្រោះរូបកាយនៃមនុស្សរាប់សែន រាប់លាននាក់សុទ្ធតែ

ផ្សេងពីគ្នា បើមិនផ្សេងច្រើនក៏គង់បន្តិចបន្តួច សូម្បីកូនភ្លោះក៏គង់ផ្សេងគ្នាខ្លះដែរ ល្មមឲ្យចំណាំបានឥតមានច្រឡំគ្នាឡើយ ។ រូបកាយផ្សេងពីគ្នាយ៉ាងណា ចិត្តក៏ផ្សេងគ្នាយ៉ាងនោះដែរ ។ អ្នកមានគំនិតប្រាជ្ញាដែលប្រាថ្នាចង់បានសេចក្ដីសុខរាល់ខ្លួននឹងអ្នកដទៃ ក្នុងពួកក្រុមឬសង្គមនីមួយៗ នោះគេតែងប្រដៅចិត្តពត់ចិត្តទប់ចិត្តរក្សាចិត្ត សម្របសម្រួលចិត្តរបស់ខ្លួនឲ្យស្របរួមជាមួយគ្នា មិនដណ្ដើមប្រជែងយកឈ្នះគ្នា បោះបង់អស្មិមានះចេញ ដើម្បីយកឱកាសឲ្យមានសាមគ្គី គឺការព្រមព្រៀងគ្នាតាមផ្លូវចិត្តកើតឡើង ក្នុងពួកក្រុមរបស់ខ្លួនវៀរលែងតែមនុស្សខ្លះក្នុងពួកក្រុមជាមួយដែលជាមនុស្សទុជ៌ន មានគំនិតអាក្រក់ មានសេចក្ដីយល់ខុសយ៉ាងច្បាស់លាស់ មនុស្សបែបនេះ មិនត្រូវសម្របចិត្តអនុលោមបានឡើយ ត្រូវតែរួមគ្នាបដិសេធមនុស្សដែលមានគំនិតអាក្រក់នោះចេញ កុំឲ្យនៅរួមក្នុងពួកឬសង្គមជាមួយឡើយ ។

ពួកក្រុមឬសង្គមណាមួយ ដែលបានការព្រមព្រៀងគ្នាហើយ កាលបើត្រូវការនឹងបំពេញមុខការណាមួយ ដែលមានប្រយោជន៍ជាសាធារណៈ សូម្បីការនោះធំហើយកម្រផងយ៉ាងណាក្ដី, បើពួកក្រុម ឬសង្គមនោះមិនបោះបង់សេចក្ដីព្យាយាមចោលទេ កិច្ចការទាំងនោះគង់នឹងបានសម្រេចតាមបំណងដោយអាស្រ័យសាមគ្គីយ៉ាងមាំមួន ។

ម្យ៉ាងទៀត, សាមគ្គីនេះ ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់ត្រាស់សរសើរ

ថាជាធម៌នាំឲ្យកើតសេចក្ដីចំរើន មិនមែននាំឲ្យកើតសេចក្ដីវិនាសឡើយ ដូចពុទ្ធភាសិតក្នុងអបរិហានិយធម្មសូត្រ មានដូច្នេះជាដើមថា៖

យាវកីវញ្ច ភិក្ខវេ ភិក្ខូ សមគ្គា

សន្និបតិស្សន្តិ សមគ្គា វុដ្ឋហិស្សន្តិ

សមគ្គា សង្ឃករណីយានិ ករិស្សន្តិ

វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា

នោ បរិហានិ „ម្នាលភិក្ខុទាំងឡាយ, ពួកភិក្ខុ (ដែលមានចំនួនច្រើនរូប) ដែលត្រូវប្រជុំ ក៏ព្រមព្រៀងគ្នាប្រជុំ, ពេលដែលក្រោកចាកទីប្រជុំ ក៏ព្រមព្រៀងគ្នាក្រោក, ពេលដែលត្រូវធ្វើកិច្ចការរបស់សង្ឃ ក៏ព្រមគ្នាធ្វើកិច្ចការរបស់សង្ឃ, (កាលបើមានការព្រមព្រៀងគ្នាដូច្នេះ) អស់កាលត្រឹមណា, សេចក្ដីចំរើនទឹងកើតមានប្រាកដដល់ភិក្ខុទាំងឡាយ មិនមែននាំឲ្យកើតសេចក្ដីវិនាសឡើយ អស់កាលត្រឹមនោះ” ។

ពុទ្ធភាសិតមានប៉ុណ្ណេះជាដើម ជាព្រះបរមពុទ្ធោវាទដ៏ឧត្ដម សម្រាប់ពួកបព្វជិតនិងគ្រហស្ថជាពុទ្ធបរិស័ទ ដែលមានបំណងចង់បានសេចក្ដីចំរើន, ចង់ចៀសវាងឲ្យផុតពីសេចក្ដីវិនាស, គួរពិចារណាឲ្យយល់សេចក្ដីក្នុងពុទ្ធភាសិតនេះ ឲ្យច្បាស់លាស់ ហើយគួរប្រតិបត្តិធ្វើតាម ។

# សេចក្ដីអធិប្បាយ

ពុទ្ធភាសិតខាងលើនេះ មានចំណុចដ៏សំខាន់ ៣ យ៉ាងគឺ:

១ — ព្រមព្រៀងគ្នាប្រជុំ

២ — ព្រមព្រៀងគ្នាក្រោកចាកទីប្រជុំ

៣ — ព្រមព្រៀងគ្នាធ្វើកិច្ចការ

ត្រង់បទថាព្រមព្រៀងគ្នាប្រជុំ បានសេចក្ដីថា អ្នកដែលត្រូវមកកាន់ទីប្រជុំនោះ បានមកដល់ព្រមព្រៀងគ្នា តាមពេលកំណត់ គឺថាការប្រជុំម្ដង ៗ សុទ្ធតែបានកំណត់ពេលទុកជាមុន ដូចបានកំណត់ថានៅថ្ងៃទី ១២ ខែមេសា ព.ស. ២៥០០ វេលាម៉ោង ៧ ព្រឹក ត្រូវប្រជុំគ្នានៅទីព្រះសក្យមុនីចេតិយ ក្រុងភ្នំពេញ ។ អ្នកដែលត្រូវមកប្រជុំបានមកដល់មុនម៉ោង ៧ បន្តិច ឬត្រឹមម៉ោង ៧ គត់ បានជួបជុំព្រមគ្នា យ៉ាងនេះ ហៅថាព្រមព្រៀងគ្នាប្រជុំ ។ ការប្រជុំបែបនេះចាត់ថាជាការប្រជុំត្រឹមត្រូវមានរបៀបរៀបរយ មិនរយីករយាក ។ ប្រសិនបើអ្នកដែលត្រូវមកប្រជុំនោះបណ្ដែតបណ្ដោយទម្រន់ដំអក់ដោយការធ្វេសប្រហែស មកក្រោយពេលកំណត់ឆ្ងាយពេក ឬមិនទាន់មកផង ដោយឥតឡើងដំណឹងមុន, បើមកខុសពេលតែម្នាក់ ក៏មិនជាអ្វីប៉ុន្មាន ប្រសិនបើមកខុសពេលច្រើនគ្នាឬមិនមកច្រើនគ្នា ទីប្រជុំនោះអាចចាត់ទុកថាជាទីប្រជុំមិនព្រមព្រៀងគ្នា ក្លាយទៅជារយីករយាកខ្ជីខ្ជា ។ ការប្រជុំបែបនេះនឹងមិន

មិនថេរយូរទៅមុខបានឡើយ នឹងត្រូវវិនាសបាត់ក្នុងអនាគតដ៏ខ្លី ដោយហេតុថាការប្រជុំខ្វះខាតសាមគ្គីធម៌ គឺច្បាប់ឬកម្រិតព្រមព្រៀងគ្នា ។ ប្រសិនបើការប្រជុំនោះមិនវិនាសបាត់ទៅទេ ដោយអ្នកចាត់ការមានព្យាយាមចេះតែបង្កកិច្ចប្រជុំនោះទៅទៀត ប៉ុន្តែអ្នកដែលត្រូវមកប្រជុំនៅតែមិនអាចធ្វើការប្រជុំនោះឲ្យបានព្រមព្រៀងឲ្យត្រឹមត្រូវតាមពេលវេលាបានទេ ទីប្រជុំនោះចាត់ថាជាទីប្រជុំយើករយាកខ្ជិលខ្ជា ឥតតម្លៃថ្លៃថ្នូរ ជាទីប្រជុំធូរថយសាបរលាប មិនអាចឲ្យចំរើនផលសមតាមប្រាថ្នាបានឡើយ ដូចពុទ្ធភាសិតថា យំ កិញ្ចិ សិថិលំ កម្មំ ន តំ ហោតិ មហប្ផលំ «អំពើណាមួយដ៏ធូរថយ អំពើនោះមិនអាចឲ្យសម្រេចផលដ៏ធំបានឡើយ», ដូច្នេះ ពួកបព្វជិតក្តី ពួកពុទ្ធបរិស័ទជាគ្រហស្ថក្តី ដែលមានអធិការតម្រូវឲ្យមានការប្រជុំនោះ គួរខំប្រឹងចាត់ការប្រជុំឲ្យបានព្រមព្រៀងគ្នា ទើបជាហេតុ នឹងនាំឲ្យសម្រេចផលសមតាមបំណងបាន ។

ត្រង់បទថាព្រមព្រៀងគ្នាក្រោកចាកទីប្រជុំនោះ បានសេចក្តីថា អ្នកដែលមកប្រជុំទាំងប៉ុន្មាន បាននៅក្នុងទីប្រជុំរហូតដល់ផុតកិច្ចប្រជុំ ឬផុតកាលកំណត់ទើបក្រោកចាកទីប្រជុំព្រមគ្នា ក្នុងឱកាសដែលអធិបតីនៃការប្រជុំបានឲ្យដំណឹងថា អស់កិច្ចប្រជុំហើយ ។ ប្រសិនបើការប្រជុំនោះមិនទាន់ចប់នៅឡើយទេ ប៉ុន្តែអ្នកដែលប្រជុំនោះខ្លះមានកិច្ចធុរៈ មិនអាចធន់ទ្រាំនៅបានរហូតដល់ទីបំផុត គួរជំរាបអធិបតីឲ្យបានជ្រាបមុន ហើយសឹមចេញទៅ ។ ក្នុងព្រះវិន័យ មានពុទ្ធប្បញ្ញត្តិហាមថា :

យោ បន ភិក្ខុ សង្ឃេ វិនិច្ឆយកាថា វត្តមានាយ ឆន្ទំ អទត្វា ឧដ្ឋាយាសនា បក្កមេយ្យ បាចិត្តិយំ

«ភិក្ខុណាមួយ, បើជំនុំសង្ឃកំពុងវិនិច្ឆ័យសេចក្តី (អ្វីមួយ), ឥតបានឲ្យឆន្ទៈសោះ ហើយក្រោកចេញ (ពីទីប្រជុំនោះ) ទៅ, ត្រូវអាបត្តិបាចិត្តិយ:» ដូច្នេះការក្រោកចាកទីប្រជុំនោះ បើបានឲ្យដំណឹងមុន ក៏នៅក្នុងឋានៈព្រមព្រៀងគ្នាដដែល ។

ដែលហៅថាក្រោកចាកទីប្រជុំមិនព្រមព្រៀងគ្នានោះ គឺថាកំពុងតែប្រជុំ អ្នកខ្លះក្រោកចាកចេញទៅឯណេះ ខ្លះទៅឯណោះឥតប្រាប់ដំណឹងអ្វីសោះ ធ្វើឲ្យទីប្រជុំនោះរយីករយាក ឥតមានរបៀបរៀបរយ ។ ការក្រោកទីប្រជុំ មិនព្រមព្រៀងគ្នាយ៉ាងនេះ ជាហេតុនាំឲ្យការប្រជុំនោះឥតតម្លៃ ថែមទាំងមិនឲ្យមានដំណើរបិតទៅបានអង្វែងផងទៀត ដោយហេតុអ្នកមកប្រជុំនោះមានចិត្តរាគខ្សោយបន្តិចម្តង ៗ មិនយូរប៉ុន្មានការប្រជុំនោះក៏នឹងវិនាសបាត់ទៅ ។

ដូច្នេះ គួរពួកបព្វជិតក្តី ពួកពុទ្ធបរិស័ទជាគ្រហស្ថក្តី ដែលមានអង្គការណាមួយតម្រូវឲ្យមានការប្រជុំ គប្បីចាត់របៀបការប្រជុំនោះឲ្យរៀបរយ ឲ្យបានរួបរួមព្រមព្រៀងគ្នា រហូតដល់ចប់កិច្ចប្រជុំ សឹមក្រោកដោយព្រមព្រៀងគ្នាតែម្តង ដូច្នេះជាកិច្ចប្រសើរល្អណាស់ ព្រោះនាំឲ្យការប្រជុំនោះមានតម្លៃល្អផង នាំឲ្យការប្រជុំនោះមានអាយុយឺនយូរផង ។

(នៅមានត)

# ការត្រាស់ដឹងនៃព្រះសម្ពុទ្ធ

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

(ត - ចប់)

ពាក្យថា «អវិជ្ជា» ក្នុងទីនេះ មិនប្រែថា «ល្ងង់ខ្លៅ» ទេ ខ្ញុំយើងរកពាក្យឲ្យមានបំនួនពេញពោរប៉ុនគ្នានឹងពាក្យ «អវិជ្ជា» ពិបាកណាស់ បានតែប្រែបន្ទប់សព្ទថា «អវិជ្ជា» ។ អវិជ្ជាក្នុងបដិច្ចសមុប្បាទនេះ លោកខ្លះប្រែថា «អ្វីដែលមិនគប្បីដឹង ពុំនោះអ្វីដែលមិនចាំបាច់ត្រូវដឹង» ព្រោះប្រស្នាដែលថាអ្វីជាហេតុឲ្យកើតសង្ខារនោះ រាតទៅដល់ប្រស្នាដែលនិយាយ ថាជីវៈ នឹង សរីរៈ នេះជារបស់តែមួយជាមួយគ្នាទេឬអ្វី ? ជាអន្តគ្គាហិកទិដ្ឋិ លទ្ធិប្រកាន់ទីបំផុត (Extremisme) ដែលព្រះសម្ពុទ្ធទ្រង់មិនព្រមព្យាករ ព្រមទាំងមិនសំដែងសោះតែម្ដង បានជាទ្រង់ប្រើពាក្យថា អវិជ្ជាសំដៅសេចក្ដីថា «អ្វីដែលមិនចាំបាច់ត្រូវដឹង» នេះ ។

សង្ខារក្នុងបដិច្ចសមុប្បាទនេះ មិនមែនជាកម្មដូចសង្ខារក្នុងខន្ធប្រាំទេ លោកសំដៅយកវត្ថុធាតុដែលផ្សំចូលគ្នា (Agrégat) ឲ្យកើតជាសរីរៈ ជាទីកើតនៃជីវៈ ដូចសង្ខារ ព្រោះជីវិតមនុស្ស ក៏ត្រូវកើតពីសង្ខារតាមច្បាប់បដិច្ចសមុប្បាទ កាលបើមានសង្ខារហើយ វិញ្ញាណក៏ចូលមក ឬក៏កើតឡើង ទើបលោកពោលថាសង្ខារជាហេតុឲ្យកើតវិញ្ញាណ កាលបើមានវិញ្ញាណកើតហើយ នាមរូបក៏កើតឡើងដែរ មានកាយគន្ធៈភ្នែក ត្រចៀក ច្រមុះ ។ល។

ដែលធ្វើឲ្យកើតការប៉ះពាល់ (ផស្ស) បើមានការប៉ះពាល់ហើយ ក៏កើតមានការដឹង (វេទនា) តទៅ ក៏ធ្វើឲ្យកើតសេចក្ដីប្រាថ្នា (តណ្ហា) កើតការប្រកាន់ (ឧបាទាន, ឧបាទានធ្វើឲ្យកើតមានភពដែលអ្នកអស្ដ្រើតហៅថា Existence ដល់មកត្រង់នេះ ក៏កើតកំណើតឡើង (ជាតិ) កើតឡើងហើយក៏មានការ ចាស់ ឈឺ ស្លាប់ ក្នុងពេលដែលមិនទាន់ស្លាប់ ក៏កើតមានសេចក្ដីសោកទន្ទឹះខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងការអស់សង្ឃឹម (ឧបាយាស) ។ បើយើងមិនត្រូវការឲ្យមានសេចក្ដីទុក្ខក្ដៅក្រហាយ ចាស់ ឈឺ ស្លាប់ ដូចពោលមកនេះទេ ក៏ត្រូវធ្វើកុំឲ្យកើត ការដែលធ្វើមិនឲ្យកើត ក៏ត្រូវរំលត់តណ្ហា ឧបាទាន ធ្វើឲ្យរលត់ វិញ្ញាណ ដែលលទ្ធិព្រាហ្មណ៍បញ្ញត្តថា «អាត្មន ឬ អត្តា» ឲ្យ «អាត្មន ឬអត្តា» រត់ចូលទៅរកព្រហ្មវិញ តែព្រះសម្ពុទ្ធទ្រង់ត្រាស់ថា «និព្វាន» ។

ដូច្នេះ ផលទីបំផុត ត្រូវចេះដឹងអរិយសច្ច គឺដឹងថាជីវិតនេះជាទុក្ខ, ដឹងថា ទុក្ខនេះមានហេតុ (សមុទយ) តែទុក្ខនេះអាចរលត់បាន (និរោធ) ព្រោះមានផ្លូវប្រតិបត្តិឲ្យរលត់ទុក្ខ (មគ្គ) ។

បើយើងបានពិចារណាយ៉ាងនេះហើយ យើងឃើញច្បាស់ថា ការត្រាស់ដឹងនៃព្រះសម្ពុទ្ធជាការរកឃើញថ្មីទៀត ហើយមានការសំខាន់យ៉ាងក្រៃលែង ក្នុងរាត្រីកាលដែលទ្រង់បានត្រាស់ដឹងនោះ គឺទ្រង់បានសាងវិជ្ជាមួយដ៏ធំក្រៃលែង ដែលឥតមានមនុស្សណាបានធ្វើមកពីក្នុងកាលមុន

នោះ ព្រោះគ្រឿងផ្សំឲ្យកើតមានជីវិត ផ្សំឲ្យកើតមានចិត្តនេះ កាលពីសម័យមុន អ្នកគន់គិតរកមិនទាន់ឃើញ ដែលគន់គិតរកហើយនិយាយ "ឃើញហើយ" ក៏ឃើញមិនពិត ព្រោះយល់ខុសថា មនុស្សសត្វកើតចេញមកពី «ព្រហ្ម» ដែលហៅថា «អាត្មន ឬ អត្តា» ទាំងក្រោយដែលព្រាហ្មណ៍បានរកសាងព្រះព្រហ្មឲ្យមានរូបកើតឡើងហើយ បើថាសេចក្តីយល់ឃើញនេះជាសេចក្តីពិតមែន នុះនាំឲ្យយើងយល់ថា កំណើតមនុស្សសត្វសព្វសារពើឆាយណាស់ សព្វបើគ្រាន់តែផង់ល្អងធូលីបាទជើងនៃព្រះព្រហ្ម ក៏អាចក្លាយកើតជាមនុស្សសត្វសព្វសារពើបាន ។ ឯទ្រឹស្តីដែលស្តីថា សង្ខារផ្សំគ្នាឲ្យកើតមានជីវិតឡើងដែលជាតួខន្ធប្រាំនេះ ជាការគន់គិតរកឃើញថ្មីជាទីឯក ដែលមិនទាន់មាននរណារកឃើញ បានជាព្រះសម្ពុទ្ធទ្រង់ប្រកាសអាសអាងថាៈ «ការត្រាស់ដឹងទ្រង់បានរកឃើញដោយព្រះអង្គឯង មិនមានគ្រូបាអាចារ្យណាបង្រៀនព្រះអង្គឡើយ» ។ ការគន់គិតរកឃើញទ្រឹស្តីថ្មីនេះ ជាការបដិវត្តន៍ដ៏ធំក្រៃលែងតមកពីលទ្ធិព្រាហ្មណ៍ ហើយអ្នកប្រាជ្ញគន់គិតរកខាងប្រទេសអស្តង្គតពោលសរសើរថា «ការត្រាស់ដឹង» ឬបើពោលម្យ៉ាងទៀតថា «ការរកឃើញ» នៃអង្គព្រះសម្ពុទ្ធនេះ ត្រឹមត្រូវទៅតាមគោលវិទ្យាសាស្ត្រយ៉ាងអស្ចារ្យបំផុត ។

វិធីការញែកសភាពចិត្តដូចសេចក្តីដែលបានពោលមកហើយ ក៏ដូចគ្នានឹងការញែកធាតុនៃអ្នកវិទ្យាសាស្ត្រដែរ គឺត្រូវតែញែកតាមវិធីនេះ

ទើបបានកើតទៅជាទ្រឹស្តីមួយដ៏ពិត ៗ មួយទៀត បើយើងពិចារណាឲ្យល្អិតទៅ យើងឃើញថា ព្រះសម្ពុទ្ធនឹងពួកអ្នកប្រាជ្ញគន់គិតមានដំណើរទៅផ្សេង ៗ គ្នា អ្នកគន់គិតក្នុងលោកបច្ចុប្បន្ននេះ បើបានរកឃើញវិធីដ៏ប្រសើរណាមួយ ហើយច្រើនតែមិនយកការដែលខ្លួនរកឃើញនោះទៅប្រើសម្រាប់ខ្លួនឯងទេ អ្នកទស្សនវិជ្ជា ដែលរកឃើញវិជ្ជាអ្វីមួយខាងទស្សនវិជ្ជាច្រើនតែចងក្រងវិជ្ជានោះជាទ្រឹស្តី ហើយយកទៅលក់ផ្សាយឲ្យដល់ជនដទៃ ៗ ខ្លួនឯងមិនបានប្រតិបត្តិតាមទ្រឹស្តីនោះទេ ឯអ្នកគន់គិតរកវិជ្ជាធម្មសាស្ត្រក៏ដូច្នោះដែរ កាលបើបានអ្វីប្រសើរ ៗ ខ្លួនឯងមិនព្រមប្រតិបត្តិតាមដោយម៉ត់ចត់ទេ ឯព្រះសម្ពុទ្ធវិញ ផ្ទុយគ្នាស្រឡះ ទ្រង់បានយកវិជ្ជាដែលទ្រង់រកឃើញនោះ ទៅប្រើលាងសំអាតកិលេសសេចក្តីសៅហ្មង សាងសេចក្តីបរិសុទ្ធិឲ្យដល់ចិត្តព្រះអង្គទៀត ៗ ដូច្នេះការត្រាស់ដឹងរបស់ព្រះអង្គ មិនមែនបានសេចក្តីត្រឹមតែថារកឃើញទ្រឹស្តីវិជ្ជាប៉ុណ្ណោះទេ ស៊ីសេចក្តីរហូតទៅដល់ថា ទ្រង់បានប្រើវិជ្ជាដែលទ្រង់រកឃើញនោះ សម្រាប់ធ្វើឲ្យកើតសេចក្តីភ្ញាក់ស្វាងដល់ព្រះអង្គទៀត ធម៌ណាដែលទ្រង់ទុកជាធម៌អាក្រក់ ដូច លោភៈ ទោសៈ មោហៈ ជាដើម ទ្រង់បានលាងសំអាតធ្វើឲ្យអស់ពីសន្តានព្រះអង្គទៅ ធម៌អាក្រក់ទាំងនេះមិនដុះឡើងក្នុងសន្តានព្រះអង្គវិញទៀតទេ សន្តានព្រះអង្គប្រព្រឹត្តទៅតែក្នុងផ្លូវមជ្ឈិមបដិបទាបរិសុទ្ធស្អាតឥតមន្ទិលសៅហ្មងអ្វីឡើយ គឺការត្រាស់

ដឹងព្រះអង្គ មិនមែនបានសម្រេចត្រឹមតែភាគទ្រឹស្តីប៉ុណ្ណោះទេ បានសម្រេចដល់ភាគបដិបត្តិថែមទៀតផង ។

សេចក្តីដូចបានពោលមកនេះ ទើបបានជាយើងហ៊ានពោលថា ការត្រាស់ដឹងនៃព្រះសម្ពុទ្ធជាការសម្រេច ដល់កំពូលខ្ពស់ក្រៃលែងបំផុត ជាងការសម្រេចនៃអ្នកប្រាជ្ញទាំងឡាយក្នុងលោក ។

ក្នុងពេលដែលទ្រង់បានត្រាស់ដឹង ព្រះសម្ពុទ្ធបានសម្រេចនិព្វាន ជាន់ទីមួយ គឺសឧបាទិសេសនិព្វាន ឬកិលេសនិព្វានហើយ ការដែលបានសម្រេចបែបនេះ ហើយដែលអ្នកគន់គិតរកកាលពីជំនាន់មុនហៅថា "មោក្ស" បើតាមសេចក្តីយល់ឃើញនៃលទ្ធិព្រាហ្មណ៍សម័យនោះ ។

ទ្រង់ត្រាស់ដឹងហើយទ្រង់សោយសេចក្តីសុខ មិនមែនសេចក្តីសុខដូចជាយើងធ្លាប់ដឹងមកនោះទេ ជាសេចក្តីសុខរបស់ចិត្តដែលបរិសុទ្ធរួចស្រឡះចាកមន្ទិលសៅហ្មងគ្រប់ប្រការយ៉ាងអស់ជើង ដែលលោកហៅថា "វិមុត្តិសុខ" ហើយទ្រង់បានប្រើវេលាក្រោយថ្ងៃដែលទ្រង់ត្រាស់ដឹងមក ពិចារណាធម៌ដែលមានបច្ច័យទាក់ទងគ្នាដូចជាកូនច្រវាក់ ហៅតាមពុទ្ធភាសិតថា "បដិច្ចសមុប្បាទ" ជាធម៌ដែលបានគន់គិតរកឃើញដោយព្រះអង្គឯង ទ្រង់ពិចារណាត្រឡប់ចុះត្រឡប់ឡើង ជាអនុលោមបដិលោម ទាំងខាងការកើតនិងទាំងខាងការរលត់ សំដែងឲ្យឃើញថា ព្រះសម្ពុទ្ធទ្រង់សំគាល់ថាញាណទាំង ៣ ប្រការដែលទ្រង់បានក្នុងរាត្រីកាល ត្រាស់

ដឹងនោះ មានការសំខាន់ដ៏ក្រៃលែង បានជាទ្រង់យកមកពិចារណាសាក្រោយម្តងទៀត ទ្រង់ពិចារណាសាចុះសាឡើងគ្រប់ទាំង ៣ យាមនៃរាត្រីកាល(១) គ្រប់យាមទាំង ៣ ដែលទ្រង់ពិចារណាបដិច្ចសមុប្បាទជាអនុលោមនោះ ទ្រង់ដាក់ក្នុងព្រះទ័យថា ធម៌ដែលទ្រង់បានរកឃើញនោះ ជាធម៌ត្រឹមត្រូវតាមហេតុផលពិតមែន ៗ ដោយការដាក់ក្នុងព្រះទ័យនេះឯង បានជាទ្រង់បន្លឺឧទានចេញមក ។ បូរយកឧទានក្នុងយាមនៃរាត្រីកាលមួយ ៗ មកពិចារណាមើល! យើងនឹងឃើញថា មានការសំខាន់ពិតមែន គួរឲ្យកោតស្ងើចបំផុត ដូចឧទានក្នុងយាមនៃរាត្រីកាលទីមួយថា :

«កាលណា ធម៌ទាំងឡាយបានប្រាកដដល់ព្រាហ្មណ៍អ្នកមានក្តីព្យាយាម កាលនោះ សេចក្តីសង្ស័យទាំងពួងរបស់ព្រាហ្មណ៍នោះ អស់រលីងធេងទៅ ព្រោះបានដឹងច្បាស់នូវធម៌ព្រមទាំងហេតុ»,

ឧទានក្នុងយាមទីពីរថា :

«កាលណា ធម៌ទាំងឡាយប្រាកដដល់ព្រាហ្មណ៍ អ្នកមានក្តីព្យាយាម កាលនោះ សេចក្តីសង្ស័យរបស់ព្រាហ្មណ៍នោះ

(១) សម័យពុទ្ធកាល លោកចែករាត្រីកាលជា៣យាម យាមមួយៗមាន ៤ ម៉ោង ហៅថា បឋមយាម, មជ្ឈិមយាម, បច្ឆិមយាម ។

អស់លើងផងទៅ ព្រោះបានដឹងច្បាស់ នូវព្រះនិព្វាន ជាទីអស់ទៅនៃបច្ច័យ»,

ឧទានក្នុងយាមទីបីថា : –

«កាលណា ធម៌ទាំងឡាយប្រាកដដល់ព្រាហ្មណ៍ អ្នកមានក្តីព្យាយាម កាលនោះ ព្រាហ្មណ៍នោះ បានកំចាត់បង់នូវមារ ព្រមទាំងសេនានៃមារ បីដូចព្រះអាទិត្យរះឡើងកំចាត់បង់នូវងងឹត ហើយធ្វើឲ្យអាកាសភ្លឺស្វាងរុងរឿងដោយរស្មីរបស់ខ្លួនដូច្នោះឯង» ។

ក្នុងឧទានទាំង ៣ នេះ ព្រះសម្ពុទ្ធទ្រង់ប្រើពាក្យថា «ព្រាហ្មណ៍» ជាពាក្យកណ្តាល ៗ ដែលគេប្រើក្នុងសម័យនោះ សម្រាប់ហៅអ្នកគន់គិតរកធម៌កសាងខ្លួន ដើម្បីឲ្យលុះធម្មវិសេស ឯពាក្យថា «ធម៌» ដែលទ្រង់ប្រើក្នុងឧទាននោះសំដៅយកបដិច្ចសមុប្បាទធម៌ ១២ យ៉ាង ដែលជាទ្រឹស្តីធំនេះឯង ។ ឧទានទាំងអស់នេះ ទ្រង់បានបន្លឺនៅក្រោមដើមមហាពោធិមណ្ឌល ក្នុងរាត្រីកាលដែលទ្រង់បានត្រាស់ដឹង ។

តទៅ ព្រះសម្ពុទ្ធស្តេចទ្រង់ពុទ្ធដំណើរទៅកាន់ទីដទៃ ៗ ទៀត ក្នុងពេលដែលទ្រង់សោយវិមុត្តិសុខ មុនដំបូងស្តេចទៅប្រថាប់ក្រោមដើមអជបាលនិគ្រោធដែលឋិតនៅខាងបូព៌ទិសនៃពោធិមណ្ឌល ក្នុងទីនោះមានព្រាហ្មណ៍ម្នាក់ជាអ្នកធ្លាប់តែគម្រាមកំហែងគេថា ហុំហុំ = ហុំ ៗ ចូល

ទៅរកគាល់ព្រះសម្ពុទ្ធ ព្រាហ្មណ៍នោះជាបឋមបុរសដែលបានស្តាប់ធម៌ព្រះអង្គមុនគេ បានក្រាបសួរព្រះអង្គថា "បុគ្គលដែលឈ្មោះថា ព្រាហ្មណ៍នោះតើដូចម្តេច ? ធម៌អ្វីដែលធ្វើបុគ្គលនោះឲ្យទៅជាព្រាហ្មណ៍ ?"

ព្រះសម្ពុទ្ធត្រាស់តបថា :

"ព្រាហ្មណ៍ណា ជាអ្នកបន្សាត់បង់នូវបាបធម៌ចោលអស់លែងគម្រាមកំហែងគេថា ហុំ ហុំ = ហុំ ៗ ហើយ ជាអ្នកមិនមានកិលេស មានខ្លួនទូន្មានហើយ ចេះចប់ត្រៃវេទ បានព្រហ្មចរិយធម៌ចប់ហើយ មិនមានគំនរគឺរាគាទិកិលេសក្នុងលោកនេះទេ ព្រាហ្មណ៍នោះគួរគប្បីហៅខ្លួនដោយវាទៈ ថា "ព្រាហ្មណ៍" តាមធម៌បាន" ។

ពុទ្ធវចន ដែលទ្រង់ត្រាស់ចំពោះព្រាហ្មណ៍នេះ យើងអាចទុកដាក់ថា ជាវិធីមួយដែលទ្រង់លើកយកមកបដិវត្តមុនដំបូងក្នុងកាលនោះ គឺទ្រង់យល់ថាជាការចាំបាច់ត្រូវយកវិធីព្រាហ្មណ៍មកប្រើ គឺព្រាហ្មណ៍មានពិធីលាងបាបចុះមុជទឹកក្នុងស្ទឹងលាងបាប កក់សក់ជម្រះកាយ ទាំងអស់នេះ គេប្រកាន់ជឿថា ជាការបន្សាត់បង់បាបឲ្យទៅតាមខ្សែទឹក ព្រាហ្មណ៍ចប់អានវេទ ការនិយាយនឹងព្រាហ្មណ៍ ក៏ត្រូវប្រារព្ធដល់វេទ តែការបន្សាត់បង់បាបដែលជាវិធីព្រះសម្ពុទ្ធ មិនមែនចុះទៅមុជទឹកក្នុងស្ទឹងលាងបាបទេ គឺជាការលាងសំអាតកិលេសសេចក្តីសៅហ្មងឲ្យស្អាតចេញ

ពីចិត្ត ឯការសិក្សាវេទដែលព្រាហ្មណ៍ជឿថា បានបុណ្យកុសលនោះ ទ្រង់ក៏សំដែងដូច្នោះដែរ តែទ្រង់សំដៅដល់ការធ្វើចិត្តឲ្យបរិសុទ្ធវិញ: ដែលទ្រង់ត្រាស់ចំពោះព្រាហ្មណ៍នោះ គេច្រើនតែទុកដាក់ថាជាការបន្តិចបន្តួចទេ មិនធំដុំអ្វីដូចបឋមទេសនានោះឡើយ តែបើយើងពិចារណាមើលឲ្យល្អិតទៅ ឃើញថាមិនមែនបន្តិចបន្តួច ដូចគេយល់នោះទេ ធំសំខាន់ណាស់ ព្រោះអាចយល់ដល់វិធីដែលទ្រង់នឹងធ្វើបដិវត្តន៍តទៅថ្ងៃមុខ ៗ មួយទៀត ព្រាហ្មណ៍នេះជាអាទិបុគ្គលដែលបានត្រងត្រាប់ស្តាប់ពុទ្ធោវាទមុនអ្នកដទៃទាំងអស់ ចាប់ដើមតាំងតែពីទ្រង់បានត្រាស់ដឹងមក ។

តទៅទៀត ទ្រង់ចេញពីអជបាលនិគ្រោធនេះទៅកាន់មុចលិន្ទស្រះ ដែលឋិតនៅទិសអាគ្នេយ៍នៃមហាពោធិមណ្ឌលក្នុងទីនេះ ទ្រង់បន្លឺឧទានថា

“វិវេកគឺការស្ងាត់ចាកកិលេសនៃអ្នកត្រេកអរ ដែលបានចេះដឹងធម៌ ដែលបានឃើញធម៌ ទៅតាមសេចក្តីពិត ជាសេចក្តីសុខ,

ការមិនព្យាបាទ គឺការសង្រួមចិត្តមិនគិតបៀតបៀនសត្វទាំងឡាយ ការប្រាសចាករាគៈ កន្លងផុតកាមទាំងឡាយ ជាសេចក្តីសុខ,

ការកំចាត់បង់អស្មិមានៈ គឺការប្រកាន់ថាខ្លួន ជាបរមសុខនៅក្នុងលោកនេះ” ។

អ្នកគន់គិតរកទាំងឡាយ បានយកពាក្យ ៗ ទាំងនេះមកជាវត្ថុធាតុ សម្រាប់ពិចារណា គេពិចារណាថា ព្រះសម្ពុទ្ធទ្រង់គន់គិតរកទ្រឹស្តីថ្មីមួយទៀត គឺទ្រឹស្តី "អនត្តា : ការមិនមានអត្តា, អាត្មន ឬ ព្រលឹង" ការមិនមានអត្តានេះ អ្នកទស្សនវិជ្ជាឥណ្ឌាបុរាណបានគន់គិតមកហើយ រហូតមកដល់សម័យឧបនិស័ទ តែគេគិតរកឃើញត្រឹមតែ "ទុក្ខំ និង អនិច្ចំ : ទុក្ខ និងមិនទៀងទាត់" តែគេនៅប្រកាន់ជឿថាមាន អត្តា គឺលទ្ធិប្រកាន់ "អាត្មន" នេះនៅឡើយ ដែលជាគោលធំក្នុងលទ្ធិព្រាហ្មណ៍ ។ ឯព្រះសម្ពុទ្ធទ្រង់គន់គិតឃើញថា មិនមាន "អត្តា ឬ អាត្មន" នេះទេ ហើយទ្រង់ប្រកាសផ្ទុយថា "អនត្តា ឬ និរាត្មន" ទៅវិញ ជាការបដិវត្តន៍បំបាត់លទ្ធិអាត្មនចោលចេញ សេចក្តីនេះ ក៏អាចចាត់ទុកថាជាគោល គឺ "ទ្រឹស្តីមួយដ៏ធំក្រៃលែង" បាន ព្រោះជាលក្ខណៈពិសេសដោយចំពោះរបស់ព្រះពុទ្ធសាសនាពិតប្រាកដ ។

ក្រោយសោយវិមុត្តិសុខហើយ ទ្រង់ពិចារណាតទៅទៀតថា ធម៌ដែលទ្រង់ត្រាស់ដឹងនេះ គួរសំដែងប្រាប់ដល់មនុស្សទូទៅឬទេ ? ពិចារណាហើយទ្រង់ឃើញថា ធម៌នេះជ្រាលជ្រៅណាស់ ចូលចិត្តបានកម្រ តែក៏មានមនុស្សខ្លះអាចយល់បាន ដូចផ្កាឈូក ៣ ចំពូក មួយនៅក្នុងទឹក មួយទៀតលូតឡើងស្មើនឹងទឹក មួយនោះទៀត លូតខ្ពស់ហួសពីទឹកហើយ ពួកដែលលូតខ្ពស់ហួសពីទឹកហើយតែងបានទទួលពន្លឺព្រះ-

អាទិត្យហើយនឹងរីកក្នុងថ្ងៃនោះពួកដែលនៅស្មើនឹងទឹក អាចនឹងរីកក្នុងថ្ងៃព្រឹកស្អែកពួកដែលនៅលិចក្នុងទឹក អាចនឹងរីកក្នុងថ្ងៃតទៅបានតែពួកដែលនៅកប់ទឹកកប់ភក់ ទុកដូចជាបុគ្គលទី ៤ ពួកនេះអាចត្រូវអន្តរាយដោយត្រីស៊ីឬអណ្ដើកកាត់មិនទៀងថា នឹងបានរីកដូចគេបីពួកខាងដើមនោះទេ វេនេយ្យសត្វក៏ដូច្នោះដែរ ពួកខ្លះមានសទ្ធា វិរិយ សតិ សមាធិ បញ្ញា ចាស់ក្លាហើយ បើបានស្ដាប់ធម៌ ក៏អាចចូលចិត្តសេចក្ដីបាន អាចនឹងសម្រេចភ្លាម ៗ បាន ដូចផ្កាឈូកដែលលូតខ្ពស់ផុតពីទឹក ហើយពួកខ្លះទៅរង់ចាំបន្តិច ដូចផ្កាឈូកដែលលូតមកត្រឹមស្មើនឹងទឹក ពួកខ្លះទៀត រង់នៅចាំយូរបន្តិចទៅដូចផ្កាឈូកដែលនៅលិចក្នុងទឹក ទីបំផុតក៏អាចនឹងលូតមករីកនឹងគេបានដែរ នៅសល់ពួកមួយទៀតដែលនៅកប់ទឹកកប់ភក់ជ្រៅពេក គឺអ្នកមិនមានសទ្ធា, វិរិយ, សតិ, សមាធិ, បញ្ញាសោះ ពួកនេះប្រដៅមិនបាន ក៏ត្រូវបណ្ដោយឲ្យលិចទឹកទៅតាមយថាកម្ម ទ្រង់ប្រៀបធៀបដូច្នេះហើយ ទើបទ្រង់ដាក់ព្រះទ័យថា ត្រូវប្រកាសសាសនាព្រះអង្គដល់មនុស្សសត្វទៅក្នុងលោក ។

(ចប់)

# ធម៌គ្រប់គ្រងលោក

លោក ក៊ី ប៊ូ រៀបរៀង

ពាក្យថា "លោក" ក្នុងទីនេះ សំដៅយកមនុស្សលោក ៗ មនុស្សលោកគ្រប់ជាតិនៅក្នុងប្រទេសមួយ ៗ ដែលបានសុខបានចម្រើននោះ ដោយសារតែមានចិត្តអៀនខ្មាសគេ កោតខ្លាចគេ ហើយខំកាន់ច្បាប់សម្រាប់ប្រទេសរបស់ខ្លួន មិនហ៊ានប្រព្រឹត្តល្មើសក្រែងគេចាប់ឃុំខាំងធ្វើទុក្ខទោសតាមកំហុសរបស់ខ្លួន ៗ ឯច្បាប់សម្រាប់ប្រទេសនោះ ជាច្បាប់ខាងអាណាចក្រ ជាច្បាប់ខាងអាជ្ញា ជាច្បាប់ប្រើអំណាចខាងគតិលោក ៗ អ្នកកាន់ច្បាប់អាណាចក្រខាងគតិលោកនេះ នៅមិនទាន់ជួនល្មមដល់គោលបំណងក្នុងការត្រួតត្រាប្រទេសទេ ព្រោះមានអ្នកកាន់តែច្បាប់ខាងអាណាចក្រម្យ៉ាង មិនកាន់ច្បាប់សាសនចក្រម្ខាងទៀតផង ៗ ធម្មតារទេះទាំងពួង បើមានតែកង់ម្ខាង មិនអាចនឹងលឿនទៅកាន់ទីដៅបានឡើយ ត្រូវតែមានកង់ទាំងពីរខាង ទើបនឹងអាចបរឲ្យលឿនទៅតាមគោលបំណងបាន ៗ ហេតុនេះ បានជាក្នុងប្រទេសមួយ ៗ មិនដែលមានចក្រតែម្ខាងទេ គេបង្កើតឲ្យមានចក្រទាំងពីរខាង គឺអាណាចក្រម្ខាង ជាគូនឹងសាសនចក្រម្ខាងទៀត ទើបអ្នកប្រទេសនោះ ៗ បានទៅជាសុខសាន្តត្រាណរៀបរយល្អ ៗ

មនុស្សគ្រប់ជាតិក្នុងប្រទេសមួយ ៗ តែងមានលទ្ធិសាសនាមួយ ៗ ប្រចាំជាតិរៀងខ្លួន ៗ មនុស្សម្នាក់ ៗ តែងកាន់ច្បាប់ខាងអាណាចក្រផង កាន់ច្បាប់ខាងសាសនាចក្រផង ៗ ក្នុងទីនេះ ច្បាប់ខាងអាណាចក្រលើកទុក ខ្ញុំសូមសរសេរតែច្បាប់ខាងសាសនាចក្រម្យ៉ាង ៗ ឯច្បាប់ខាងសាសនាចក្រនោះសោតទៀត ក៏មិនត្រូវត្រង់គ្នាជាធ្លុងមួយដែរ សឹងតែបែកខ្វែកគ្នាទៅតាមលទ្ធិសាសនាប្រចាំជាតិរៀងខ្លួន ៗ តាមការសង្កេតមើលឃើញថា នៅនាសម័យបច្ចុប្បន្ននេះ មានលទ្ធិសាសនាធំ ៗ ដែលមនុស្សនិយមគោរពរាប់អានទូទៅពេញសកលលោកត្រឹម ៤ ពួក គឺ លទ្ធិសាសនាព្រាហ្មណ៍ ១ ពួក លទ្ធិសាសនាពុទ្ធៈ ១ ពួក លទ្ធិសាសនាគ្រិស្ត ១ ពួក លទ្ធិសាសនាអ៊ិស្លាម ១ ពួក ៗ

តាមលទ្ធិសាសនាព្រាហ្មណ៍ប្រកាន់ថា មហាព្រហ្មជាព្រះកសាងលោកហើយគ្រប់គ្រងលោក ៗ តាមលទ្ធិសាសនាគ្រិស្ត និង អ៊ិស្លាម ប្រកាន់ថា ព្រះម្ចាស់សួគ៌ ជាព្រះកសាងលោកហើយគ្រប់គ្រងលោក ៗ តាមលទ្ធិសាសនាពុទ្ធ ប្រកាន់ថា ធម៌ជាគ្រឿងកសាងលោកហើយគ្រប់គ្រងលោក ៗ

ក្នុងទីនេះ លទ្ធិសាសនា ៣ ពួកលើកទុកពុំបាននាំមកអធិប្បាយទេ ខ្ញុំសូមអធិប្បាយតែអំពីលទ្ធិសាសនាពុទ្ធ ម្យ៉ាងប៉ុណ្ណោះ តាមព្រះពុទ្ធដីកាមួយបទដែលលោកចែងទុកក្នុងគម្ពីរសុត្តន្តបិដក អង្គុត្តរនិកាយ ទុកនិបាតថា ៖

ទ្វេ មេ ភិក្ខវេ សុក្កា ធម្មា លោកំ បាលេន្តិ ។ កតមេ ទ្វេ? ហិរិ ច ឱត្តប្បញ្ច . . . ។

ភិក្ខុទាំងឡាយ សុក្កធម៌ ២ យ៉ាងនេះរមែងគ្រប់គ្រងលោក គឺហិរិ ១ ឱត្តប្បៈ ១ ។

ធម៌ស ធម៌ស្អាត ធម៌ល្អ ហៅថា សុក្កធម៌ ។ ហិរិ ប្រែថា ចិត្តអៀនខ្មាសបាបហើយមិនហ៊ានធ្វើបាប ។ ចំណែកចិត្តអៀនខ្មាសអ្នកដទៃ ដោយយល់ឃើញថា បើខ្លួនធ្វើអាក្រក់ ធ្វើមិនសមគួរនឹងពូជពង្សត្រកូលរបស់ខ្លួនហើយ មុខជាអ្នកផងដទៃ គេនឹងតិះដៀលនិន្ទាខ្លួនជាមិនខាន ដោយគិតខ្មាសគេយ៉ាងនេះ ក៏មិនហ៊ានធ្វើបាប ដូច្នេះមិនចាត់ថាចិត្តមានហិរិតាមច្បាប់ពុទ្ធសាសនាឡើយ គ្រាន់តែរាប់ថាអ្នកមានចិត្តចេះអៀនខ្មាសតាមលោកវោហារបាន ព្រោះអ្នកខ្មាសគេនេះ កាលបើស្ងាត់កំបាំងពីភ្នែកពីត្រចៀកគេហើយ មុខជាហ៊ានធ្វើបាបមិនលែងឡើយ ។

ឱត្តប្បៈ ប្រែថា ចិត្តខ្លាចផលរបស់បាបដែលប្រគល់ឲ្យខ្លួនជាអ្នកធ្វើហើយមិនហ៊ានធ្វើបាបជាហេតុ ។ ចំណែកចិត្តកោតខ្លាចមាតាបិតាគ្រូអាចារ្យឬលោកជាអាណាព្យាបាលណាមួយ ក្រែងលោកស្តីបន្ទោសធ្វើទុក្ខបុកម្នេញខ្លួន ព្រោះធ្វើខុសធ្វើអាក្រក់នោះហើយ ក៏ហ៊ានធ្វើបាប ។ ចិត្តយ៉ាងនេះច្បាប់ពុទ្ធសាសនា មិនហៅថា ឱត្តប្បៈទេ គ្រាន់តែហៅថាចិត្តកោតខ្លាចតាមសំដីអ្នកស្រុកនោះទើបសមល្មម ព្រោះចិត្តកោតខ្លាចគេ

នេះ កាលបើកបាំងពីមុខគេ មុខជាហ៊ានធ្វើបាបមិនខានឡើយ ។

មនុស្សគ្រប់រូប ក្នុងម្នាក់ ៗ តែងមានសុខខ្លះមានទុក្ខខ្លះនៅលាយឡំគ្នា គ្មានអ្នកណាមួយមានសុទ្ធតែសុខឬមានសុទ្ធតែទុក្ខម្យ៉ាង ៗ នោះទេ ។ ចុះសុខទុក្ខនោះកើតមានមកពីណា ! ។ ប្រាកដជាកើតមានមកពីបុណ្យបាប ព្រោះបុណ្យជាហេតុឲ្យកើតសុខបាបជាហេតុឲ្យកើតទុក្ខ ។ សុខទុក្ខជាផលរបស់បុណ្យនិងបាប ។ ច្បាប់ពុទ្ធសាសនាប្រាប់ថា បើចង់បានសុខច្រើន ត្រូវខំធ្វើបុណ្យជាហេតុនោះឲ្យបានច្រើន ។ បើអ្នកណាគិតចង់បានសុខឲ្យច្រើនលើសលុប ប៉ុន្តែមិនធ្វើបុណ្យជាហេតុសោះ អ្នកនោះពិតជាមិនបានបន្តិចបន្តួចឡើយ កុំថាដល់ទៅសុខច្រើន ព្រោះតែខ្វះគ្មានហិរិ ឱត្តប្បៈ ។

ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា ហិរិឱត្តប្បៈជាលោកបាលធម៌ ប្រែថា ធម៌ថែរក្សាមនុស្ស ។ មនុស្សគ្រប់រូបតែងមានអាណាព្យាបាលចាំបីបាច់ថែរក្សាតាំងពីនៅជាក្មេងតូចរហូតដល់ចាស់ជរា គ្មានអ្នកណាមួយរស់នៅតោលតែឯកឯងកើតទេ ។ បើដូច្នេះ ហេតុអ្វីបានជាព្រះបរមសាស្តាទ្រង់ត្រាស់ថា ហិរិ ឱត្តប្បៈ ជាធម៌ថែរក្សាមនុស្សទៅវិញ ។ ហេតុតែព្រះពុទ្ធអង្គទ្រង់ជ្រាបច្បាស់ណាស់ថា មនុស្សថែរក្សាមនុស្សដូចគ្នាជាការលំបាកណាស់ មិនមែនជាការងាយទេ ប្រៀបដូចម៉ែឪបីបាច់ថែរក្សាកូនតូចបង្ខំឲ្យស្លៀកខោពាក់អាវ កូននោះស្លៀកពាក់ខោអាវ

បានតែមួយរំពេចស្រាតចោលអស់ទៅ ព្រោះវាមិនចេះអៀនខ្មាសគេផង វាមិនខ្លាចក្រែងមានជម្ងឺដម្កាត់ផង ៗ សេចក្ដីនេះយ៉ាងណា អ្នកដែលគ្មានចិត្តខ្មាសបាប គ្មានចិត្តខ្លាចបាប ក៏ហ៊ានធ្វើបាបងាយ ៗ ដូចជាកូនក្មេងតូចហ៊ានស្រាតខោអាវចេញអស់ពីខ្លួនងាយ ៗ យ៉ាងនោះដែរ ៗ

ហេតុនេះ មនុស្សម្នាក់ ៗ ត្រូវតែមានហិរិ គឺមានចិត្តអៀនខ្មាសបាប និងត្រូវតែមាន ឱត្តប្បៈ គឺមានចិត្តខ្លាចបាប មិនហ៊ានធ្វើបាបដោយខ្លួនឯងតែម្ដង មិនបាច់មានគេហាមប្រាមទេ ៗ អ្នកណាមានហិរិ ឱត្តប្បៈច្រើន មិនហ៊ានធ្វើ តាំងពីតូចដល់ធំកល់ពេលហើយអ្នកនោះតែងបានសុខច្រើនជាងទុក្ខ ៗ

ម្យ៉ាងទៀត ហិរិ ឱត្តប្បៈ ជាហេតុឲ្យកើតសីលទ្រទ្រង់សីលគ្រប់ប្រភេទឲ្យជាប់ល្អបរិសុទ្ធ មិនឲ្យសៅហ្មងឬដាច់ធ្លុះធ្លាយសិក្ខាបទណាមួយឡើយ ៗ ឧទាហរណ៍ ដូចព្រះបរមសាស្ដាកាលនៅជាព្រះពោធិសត្វសោយព្រះជាតិជានាគរាជព្រះនាមភូរិទត្ត ព្រះអង្គទ្រង់បំពេញសីលបារមី សូម្បីអាលម្ពាយចាប់យកព្រះអង្គទៅធ្វើទុក្ខបុកម្នេញឲ្យច្រៀងរាំ ដូចម្ដេចក៏ដោយក៏ព្រះអង្គចេះតែធ្វើតាមទាំងអស់ មិនប្រទូសរាយតបទៅអាលម្ពាយវិញសោះ តាំងព្រះទ័យមាំមួនថា បើក្ស័យជីវិតក៏ក្ស័យទៅចុះ កុំឲ្យតែសីលអញដាច់ខូចខាត ព្រោះព្រះអង្គមានហិរិ ឱត្តប្បៈ ដ៏ពេញបរិបូណ៌ មិនមែនទ្រង់ទំអត់ទ្រាំទុក្ខវេទនាដោយសារអៀនខ្មាសគេ

ឬដោយសារអោលម្ពាយទេ ប្រាកដជាព្រះអង្គមានហិរិ ឧត្តប្បៈ ខ្ពស់ ស្អប់បាប ខ្លាចបាបយ៉ាងដាច់ខាត ។ ហេតុនេះ បានជាព្រះអង្គទ្រង់ត្រាស់ប្រាប់ថា ហិរិ និង ឧត្តប្បៈ ជាលោកបាលធម៌ គឺធម៌គ្រប់គ្រងមនុស្សលោក ដូចបានអធិប្បាយសង្ខេបមកហើយ ។

> កូនក្មេង ដែលមាតាបិតាណា មិនបានឲ្យរៀនសូត្រ មាតានោះ ត្រូវរាប់ជាសត្រូវ បិតានោះត្រូវរាប់ជាបុគ្គលមានពៀរ ព្រោះកូនមិនបានរុងរឿងក្នុងទីប្រជុំជន ដូចកុកនៅកណ្ដាលហ្វូងហង្ស ។
>
> ស្រីហិតោបទេស

# អំពីគិហិវត្ត

ព្រះមុនីកោសល សួរ-ហាយ រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ក្នុងការសំដែងចំពោះគិហិវត្តនេះ សូមដកស្រង់យករឿងសិង្គាលកគហបតីមកទុកជាខាងដើម ដែលព្រះសម្ពុទ្ធជាម្ចាស់ទ្រង់សំដែងគិហិវត្តរបស់គ្រហស្ថ ហើយទ្រង់ប្រារព្ធនឹងសិង្គាលកគហបតី ដែលមានមកក្នុងសិង្គាលសូត្រនៃគម្ពីរទីឃនិកាយ ដូចនិទានតទៅនេះ :

សម័យមួយព្រះមានព្រះភាគគង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបដ្ឋាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯងកូនគហបតីឈ្មោះសិង្គាលកៈ ក្រោកឡើងអំពីព្រឹក មានសំពត់ស្លៀកពាក់ជណ្ដប់ទទឹក មានសក់ក៏ទទឹកចេញអំពីក្រុងរាជគ្រឹះប្រណម្យអញ្ជលីថ្វាយបង្គំទិសទាំង ៦ គឺទិសខាងកើត ១ ខាងត្បូង ១ ខាងលិច ១ ខាងជើង ១ ខាងក្រោម ១ និងទិសខាងលើ ១ ។

ក្នុងពេលព្រឹកនោះឯង ព្រះមានព្រះភាគទ្រង់ស្បង់ចីពរ និងបាត្រ ស្ដេចចូលទៅក្រុងរាជគ្រឹះដើម្បីបិណ្ឌបាតទ្រង់ទតឃើញសិង្គាលកគហបតីបុត្រ ដែលកំពុងផ្គងអញ្ជលីថ្វាយបង្គំទិសទាំង ៦ មានទិសខាងកើតជាដើម ទើបទ្រង់សួរសិង្គាលកគហបតីបុត្រថា នែគហបតីបុត្រ ហេតុអ្វីបានជាអ្នកផ្គងអញ្ជលីថ្វាយបង្គំទិសទាំង ៦ ដូច្នេះ ? សិង្គាលកគហបតីបុត្រក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលបិតារបស់ខ្ញុំជិតនឹងធ្វើ

មរណកាល បានផ្តាំនឹងខ្ញុំព្រះអង្គថា ហៃបា ! អ្នកត្រូវតែថ្វាយបង្គំទិស ខ្ញុំព្រះអង្គធ្វើសក្ការៈគោរពរាប់អានបូជាពាក្យរបស់បិតា ។ ព្រះមានព្រះភាគត្រាស់ថា នែគហបតីបុត្រ ! ក្នុងវិន័យរបស់អរិយៈគេមិនត្រូវថ្វាយបង្គំទិសទាំង ៦ ដូច្នេះទេ ។ សិង្គាលកគហបតីបុត្រក្រាបទូលសួរថា បពិត្រព្រះអង្គចុះក្នុងវិន័យរបស់អរិយៈគេគប្បីថ្វាយបង្គំទិសទាំង ៦ ដូចម្តេច ? បើក្នុងវិន័យរបស់អរិយៈ គេគប្បីថ្វាយបង្គំទិសទាំង ៦ យ៉ាងណា សូមព្រះអង្គទ្រង់សំដែងធម៌ ចំពោះខ្ញុំព្រះអង្គយ៉ាងនោះឲ្យបាន ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលគហបតីបុត្រ បើដូច្នោះចូរអ្នកចាំស្តាប់ចុះ ចូរកំណត់ទុកក្នុងចិត្តឲ្យប្រពៃចុះតថាគតនឹងសំដែងប្រាប់ ។ សិង្គាលកគហបតីបុត្រក៏ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះអង្គថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់សំដែងថា ម្នាលគហបតីបុត្រ អរិយសាវ័កតែងលះបង់នូវកម្មកិលេស ៤ ប្រការផង មិនធ្វើអំពើអាក្រក់ដោយហេតុ ៤ ប្រការផង មិនសេពគប់នូវអបាយមុខ គឺជាប្រធានសេចក្តីវិនាសនៃភោគសម្បត្តិ ៦ ប្រការផង អរិយសាវ័ក វៀរចាកបាបធម៌ទាំង ១៤ យ៉ាង ទើបឈ្មោះថាជាអ្នកបិទបាំងទិសទាំង ៦ ជាអ្នកប្រតិបត្តិដើម្បីជំនះក្នុងលោកទាំងពីរ គឺលោកនេះក៏បានប្រារព្ធពេញចិត្តហើយ ១ លោកខាងមុខក៏ពេញចិត្តទៀត ១ ។ កាលបើអរិយសាវ័កនោះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ រមែងទៅកើតឯសុគតិសួគ៌ទេវ-

លោកបាន ។ នេះជានិទានក្នុងបាលី ។

តាមដំណាលក្នុងអដ្ឋកថាសិង្គាលសូត្រថា ឪពុករបស់សិង្គាលមាណព នោះជាគហបតិមហាសាល មានទ្រព្យ ៤០ កោដិដែលទុកដាក់ក្នុងឃ្លាំង ។ គហបតិមហាសាលនោះជាអ្នកចូលចិត្តចំពោះព្រះភគវ័ត ជាឧបាសក សោតាបន្ន ទាំងភរិយារបស់គហបតិមហាសាលនោះជាឧបាសិកាសោតា-បន្នាដែរ តែកូនឈ្មោះសិង្គាលមាណពជាអ្នកមិនមានសទ្ធាមិនជ្រះថ្លា ចំពោះព្រះភគវ័តសោះ ។ ម្ដាយឪពុករបស់សិង្គាលមាណពតែងឲ្យឱវាទរឿយៗ ថា នែកូន ចូរអ្នកឯងឧស្សាហ៍ចូលទៅគាល់ព្រះពុទ្ធបរមគ្រូ, ព្រះសារីបុត្ត, ព្រះមោគ្គល្លាន, ព្រះមហាកស្សប ឬព្រះអសីតិមហាសាវ័ក ។ សិង្គាលមាណពនិយាយយ៉ាងនេះថា កិច្ចដែលចូលទៅរកពួកសមណៈរបស់លោកម្ដាយឪពុក ខ្ញុំមិនត្រូវការទេ ព្រោះថាការចូលទៅកាន់សំណាក់ពួកសមណៈ ត្រូវតែលុតក្រាបថ្វាយបង្គំផ្ដោម ៗ នាំឲ្យរួយចង្កេះឈឺជង្គង់ ហើយត្រូវអង្គុយគាល់ផ្ទាល់ផែនដី នាំឲ្យប្រឡាក់នាំឲ្យចាស់សំពត់អាវ កាលបើចូលទៅអង្គុយជិត តែងមានការនិយាយប្រស្រ័យចំពោះពួកសមណៈ កាលបើបាននិយាយប្រស្រ័យ សេចក្ដីស្និទ្ធស្នាលក៏កើតមាន បន្ទាប់មកត្រូវតែនិមន្តទៅឲ្យទានមានចីវរទាននិងបិណ្ឌបាតទានជាដើម កាលបើយ៉ាងនេះ នាំឲ្យតែខាតប្រយោជន៍ ព្រោះហេតុនោះ ខ្ញុំមិនបាច់ចូលទៅរកពួកសមណៈរបស់លោកម្ដាយឪពុកទេ ។

ម្តាយឪពុក បើទុកជាខំទូន្មានសិង្គាលមាណពជាកូននោះអស់មួយជីវិត ក៏មិនអាចបញ្ចុះបញ្ចូលកូនក្នុងសាសនាបានឡើយ ។ លំដាប់តមក ឪពុករបស់សិង្គាលមាណពមានជម្ងឺធ្ងន់ ដេកនៅលើគ្រែគិតថា «អញគួរឲ្យឱវាទដល់កូនចុងក្រោយបង្អស់ថា នែកូន ឯងចូរថ្វាយបង្គំទិស អញនឹងឲ្យឱវាទយ៉ាងនេះ កូននោះប្រហែលជាមិនយល់សេចក្តីថានឹងថ្វាយបង្គំទិសដើម្បីប្រយោជន៍អ្វីដូច្នេះទេ លុះព្រះពុទ្ធបរមគ្រូ ឬសាវ័កឃើញវាកំពុងថ្វាយបង្គំទិសមុខជានឹងសួរថា អ្នកឯងធ្វើអី? វានឹងឆ្លើយថា ឪពុករបស់ខ្ញុំទូន្មានខ្ញុំថា ចូរឯងថ្វាយបង្គំទិស លំដាប់នោះព្រះពុទ្ធឬព្រះសាវ័កមុខជាសំដែងធម៌ប្រាប់ថា ឪពុករបស់អ្នកឯង មិនមែនឲ្យអ្នកឯងថ្វាយបង្គំទិសបែបនេះទេ ឲ្យថ្វាយបង្គំទិសដូច្នេះវិញទេតើ»? ឪពុករបស់សិង្គាលមាណព មានគោលបំណងចង់ឲ្យកូនបានជួបនឹងព្រះសម្ពុទ្ធ លុះគិតឃើញដូច្នេះហើយទើបហៅមកផ្តាំថា «នែកូន ឯងត្រូវក្រោកឡើងអំពីព្រលឹមថ្វាយបង្គំទិស» ធម្មតាពាក្យបណ្តាំរបស់ឪពុក ដែលមានជម្ងឺធ្ងន់កំពុងដេកលើគ្រែសម្រាប់ស្លាប់ ជាពាក្យដែលកូនគួរនឹករលឹកឃើញអស់មួយជីវិត ព្រោះហេតុនោះបានជាសិង្គាលមាណពជាកូន រលឹកឃើញពាក្យបណ្តាំរបស់ឪពុក ហើយក្រោកឡើងអំពីព្រលឹម ដើរចេញអំពីផ្ទះទៅក្នុងទីឆ្ងាយអំពីផ្ទះ ថ្វាយបង្គំទិសទាំង ៦ តាមបណ្តាំរបស់ឪពុកតែរៀងរាល់ព្រឹកពិតមែន ។

លំដាប់នោះ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងអំពីកិច្ចថ្វាយបង្គំទិសចំពោះសិង្គាលមាណពថា :

ម្នាលគហបតីបុត្រ ការធ្វើកិច្ចនមស្ការចំពោះទិសទាំង ៦ នោះ ពុំមែនសំដៅយកទិសធម្មតា ដូចការយល់របស់អ្នកនោះឡើយ ។ ឯទិសទាំង ៦ ក្នុងអរិយវិន័យនោះ សំដៅយកទិសគឺបុគ្គលអ្នកមានគុណ ឬ បុគ្គលដែលត្រូវទាក់ទងប្រាស្រ័យគ្នា ។

ទិសទាំង ៦ ដូចមានពុទ្ធគាថាខាងក្រោមនេះ

មាតាបិតា ទិសា បុព្វា
អាចរិយា ទក្ខិណា ទិសា
បុត្តាទារា ទិសា បច្ឆា
មិត្តាមច្ចា ច ឧត្តរា
ទាសកម្មករា ហេដ្ឋា
ឧទ្ធំ សមណព្រាហ្មណា
ឯតា ទិសា នមស្សេយ្យ
អលមត្តោ កុលេ គិហី ។

ប្រែថា មាតាបិតាទុកជាទិសខាងកើត, គ្រូអាចារ្យទុកជាទិសខាងស្តាំ, កូននិងប្រពន្ធទុកជាទិសខាងលិច មិត្រអាមាត្យទុកជាទិសខាងជើង ទាសកម្មករទុកជាទិសខាងក្រោម, សមណព្រាហ្មណ៍ទុកជាទិសខាងលើ គ្រហស្ថក្នុងត្រកូលជាអ្នកអាចគ្រប់គ្រងផ្ទះ គប្បីនមស្ការទិសទាំងឡាយនុ៎ះ ។

បន្ទាប់តទៅនេះ សូមលើកឡើងអធិប្បាយពង្រីកសេចក្តីចំពោះកិច្ចវត្ត របស់មាតាបិតានិងបុត្រធីតាដូចដំណើរសេចក្តីតទៅ

មាតាបិតាទុកទិសខាងកើត ដែលកូនប្រុសស្រីត្រូវទំនុកបំរុងដោយ ហេតុ ៥ យ៉ាងគឺ

១- ករណា: ការចិញ្ចឹមមាតាបិតា

២- កិច្ចករណា: ជួយធ្វើការរបស់មាតាបិតា

៣- កុលវំសដ្ឋបនៈ: តម្កល់វង្សត្រកូលមាតាបិតា

៤- ទាយជ្ជបដិបជ្ជនៈ: ប្រតិបត្តិនូវទ្រព្យមត៌ក

៥- ទក្ខិណានុប្បទានៈ: ទទួលទក្ខិណាទានចំពោះមាតាបិតា ដែលធ្វើមរណកាល ។

## សូមអធិប្បាយគុណមាតាបិតាជាមុន

លោកអ្នកមានគុណទាំងឡាយ មានច្រើនពួក ប៉ុន្តែមាតាបិតាជា បុគ្គលមានគុណចំពោះកូនប្រុសស្រីមុនដំបូងបង្អស់ជាងលោកឯទៀត បាន ជាព្រះសម្ពុទ្ធទ្រង់សំដែងហើយថា មាតាបិតាទុកជាទិសខាងកើតឬដែល ហៅថាទិសបូពិ គឺជាទិសមុនដំបូងជាងទិសឯទៀត ដោយហេតុថាទិស បូពិនោះ ជាទិសដែលព្រះអាទិត្យរះឡើង ។

មាតាបិតាជាបុគ្គលមានគុណដ៏ធ្ងន់លើកូនប្រុសស្រីមុនដំបូងបង្អស់ៗ បុគ្គលជាបុត្រធីតាត្រូវយល់ថាក្នុងលោកមានមាតាបិតានេះហើយ ជាអ្នក

មានសមត្ថភាពក្នុងការគ្រប់គ្រង រក្សាបុត្តធីតា យ៉ាងប្រពិតប្រពៃទៀតហើយ ជួយជីវិតឲ្យកូនរស់រានជាធំពេញ ។

ធម៌ដែលកប់ថាជាគុណរបស់មាតាបិតា ដែលធ្លាប់ស្រោចស្រពទៅលើកូនប្រុសស្រីនោះ មានច្រើនយ៉ាងតាមហឫទ័យរបស់មាតាបិតា ដែលប៉ុនប៉ងប្រយោជន៍ដើម្បីកូនប្រុសស្រីពិតមែន ប៉ុន្តែគុណនោះបើប្រមូលដោយរួបរួម បានដល់ ព្រហ្មវិហារធម៌ទាំង ៤ ប្រការគឺ

១- មេត្តា ចិត្តរបស់មាតាបិតាដែលជាប់ស្អិតស្និទ្ធស្នាលស្នេហាប្រារព្ធនឹកមមៃចំពោះកូនតាំងអំពីឋិតនៅក្នុងគភ៌ថា កាលណាន៎! នឹងបានឃើញបុត្រ សូមឲ្យបុត្ររបស់អាត្មាអញ មានសេចក្ដីសុខតាំងអំពីឋិតនៅក្នុងគភ៌ដរាបដល់ប្រសូត្រចាកគភ៌មកហើយ ក៏ឲ្យបានសុខប្រាសចាករោគគ្រប់យ៉ាង !

២- ករុណា កាលបុត្រសម្រាលចាកផ្ទៃមកហើយជាបុត្រនៅក្នុងជាក់ជាទារកទារិកា មានមុខខាត់រូបឆោមប្រាកដចំពោះភ្នែកមាតាបិតា ហើយ មាតាបិតាតែងចាប់អារម្មណ៍ ដោយសេចក្ដីករុណាស្រឡាញ់ចំពោះកូនជានិច្ច ខំព្យាបាលបំបមថ្នមរក្សាការពារកំដៅត្រជាក់ ឬមូសស្រមោចជាដើម មិនឲ្យប៉ះពាល់ដល់កូន កាលបើកូនពុំសូវស្រួលដោយជម្ងឺណាមួយមាតាបិតាក៏មានចិត្តទុក្ខព្រួយ ដោយសេចក្ដីករុណាអាសូរចំពោះកូនជានិច្ច ។

៣- មុទិតា ចិត្តរបស់មាតាបិតាត្រេកអររីករាយសប្បាយ ក្នុងកាលដែលឃើញកូនមានសាច់ឈាមថ្លោសធំចម្រើនឡើងហើយ ដែលអាចចេះវារ ដើររត់បានហើយ ទាំងកូននោះមានសុខភាពបរិបូណ៌ មានទ្រង់ទ្រាយក៏សមរម្យល្អក្តី មិនសូវសមរម្យក្តីឲ្យតែបុត្រមានសេចក្តីសុខ ក៏ចិត្តមាតាបិតាចេះតែមានសេចក្តីត្រេកអរជាដរាបចំពោះកូនប្រុសស្រី ៗ

៤- ឧបេក្ខា ចិត្តរបស់មាតាបិតា ដែលដាច់ជំពាក់ចំពោះកូនប្រុសស្រី កាលបើកូនប្រុសស្រីមានវ័យធំចម្រើនឡើងហើយ បានរៀបចំកូនប្រុសស្រីឲ្យមានភរិយាស្វាមី បានចែកកេរ្តិ៍អាករផ្ទះសម្បែង តាមសមគួរដល់ឋានៈនៃខ្លួនហើយ ឧបេក្ខាចិត្តរបស់មាតាបិតាក៏អាចកើតឡើងតាំងអំពីពេល ដែលបានរៀបចំឲ្យមានគូស្រករនិងទ្រព្យសម្បត្តិដែលខ្លួនបានចែកល្មមចិញ្ចឹមជីវិតដោយខ្លួនឯងបាន ដោយហេតុឃើញថាកូនប្រុសស្រីអាត្មាអញមានដើមទុន មានមុខរបរអាចគ្រប់គ្រងគ្រួសារបាន ។ ចិត្តរបស់មាតាបិតា ដែលធូរល្ហែអំពីសេចក្តីទុក្ខព្រួយក្នុងការគ្រប់គ្រង ហើយនឹកសង្ឃឹមកក់ក្តៅចំពោះកូនប្រុសស្រី ក្នុងកាលដែលរៀបអាពាហ៍ពិពាហ៍ហើយ ព្រមទាំងចែកទ្រព្យសម្បត្តិសមគួរហើយ ដូចនេះឈ្មោះថាឧបេក្ខា ។

ព្រហ្មវិហារធម៌ ៤ ប្រការ គឺជាធម៌ដែលមាននៅដ៏ប្រសើរក្នុងចិត្តនៃមាតាបិតា ដូចអធិប្បាយមកនេះឈ្មោះថាជាគុណនៃមាតាបិតា ដែលជាធម៌ស្រោចស្រពរបស់ព្រំទៅលើកូនប្រុសស្រី ។

មួយទៀត មាតាបិតាមាននាមបញ្ញត្តិ ៤ ពួកគឺៈ

១- ព្រហ្ម មាតាបិតាជាសម្មតិព្រហ្មរបស់កូនប្រុសស្រី ដោយហេតុលោកមានគុណធម៌គឺព្រហ្មវិហារ ៤ ដូចបានសំដែងមកហើយ ។

២- បុព្វទេវតា មាតាបិតាទុកជាទេវតាខាងដើម ឬទេវតាមុនដំបូងជាងទេវតាឯទៀត ដោយហេតុថាមាតាបិតាជាអ្នកអភិបាលរក្សាកូនដោយផ្ទាល់ខ្លួន មុនជាងទេវតាឯទៀតទាំងអស់ ។

៣- បុព្វាចារ្យ មាតាបិតាទុកជាគ្រូអាចារ្យមុនដំបូងជាងគ្រូអាចារ្យឯទៀត ដោយហេតុថា មាតាបិតាមានឋានៈថាជាគ្រូអាចារ្យរបស់កូនប្រុសស្រីទាំងអស់ ព្រោះជាអ្នកបង្ហាត់បង្រៀនតាំងអំពីឥរិយាបថទាំង ៤ គឺ ដើរ ឈរ អង្គុយ ដេក ព្រមទាំងបង្រៀនឲ្យចេះពាក្យស័ព្ទពាក្យសំដីខ្ពស់ទាប ឲ្យស្គាល់នាមស័ព្ទឈ្មោះមនុស្សសត្វ ឈ្មោះវត្ថុដែលនៅជុំវិញខ្លួន ឲ្យស្គាល់ញាតិមិត្ត ឲ្យចេះគួរសមដោយបដិសណ្ឋារៈចំពោះចាស់ទុំចំពោះភ្ញៀវ ។

៤- អាហុនេយ្យ មាតាបិតាជាបុគ្គលគួរដល់សក្ការបូជារបស់កូនប្រុសស្រី ។ ពាក្យថា អាហុនេយ្យនេះ ជាព្រះនាមរបស់ព្រះអរហន្តដែលលោកជាបុគ្គលបរិសុទ្ធផុតចាកអាសវកិលេសគ្រប់យ៉ាង ជាបុញ្ញក្ខេត្តនៃសត្វលោក មាតាបិតាពុំមែនជាបុគ្គលបរិសុទ្ធដូចព្រះអរហន្តនោះឡើយ ប៉ុន្តែមាតាបិតាមានចិត្តស្មោះត្រង់ល្អដ៏ក្រៃលែងចំពោះកូនប្រុសស្រី អាច

រាប់បានថា លោកមានចិត្តបរិសុទ្ធផុតអំពីការវៀចវេរក្បត់ចិត្តចំពោះកូន ព្រោះហេតុនោះ មាតាបិតាលោកប្រៀបថាទុកដូចជាព្រះអរហន្តរបស់កូនចៅប្រុសស្រី ចាត់ជាបុញ្ញក្ខេត្តដ៏ប្រសើរមួយរបស់កូនប្រុសស្រីធ្វើសក្ការៈគោរពបូជា តាំងអំពីមាតាបិតាដែលមានជីវិតនៅឡើយ ។

ព្រហ្មវិហារធម៌ ៤ យ៉ាង និងចរិយាក្តងនាមបញ្ញត្តិ ៤ យ៉ាង ដូចបានអធិប្បាយមកដោយសង្ខេបនេះ លោករាប់ថាជាគុណដ៏ធំទូលាយរបស់មាតាបិតា ដែលបានអនុវត្តទៅលើកូនចៅប្រុសស្រី ដូចយើងរាល់រូបបានទទួលការឧបត្ថម្ភសង្គ្រោះអំពីមាតាបិតាមកហើយ ត្រូវយើងជាកូនចៅប្រុសស្រីនឹករលឹកចំពោះមាតាបិតារឿយ ៗ ត្រូវបំពេញកិច្ចកតញ្ញូកតវេទិ-តាធម៌ចំពោះលោកអ្នកមានគុណឲ្យរឿយ ៗ ទាន់មាតាបិតានឹងជួនយើងមានជីវិតរស់នៅ ។

(នៅមានត)

## ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប ៣.

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(អ)

*ព្រះមហា ចាន់ ខាត់ រៀបរៀង*

**អនាចារិន** គុ. ដែលមិនប្រព្រឹត្តតាមច្បាប់ ឬ ប្រពៃណី ។

**អនាចិណ្ណ** គុ. ដែលមិនបានធ្វើតាម, ដែលមិនបានកាន់យក ។

**អនាប្បណ្ណ** គុ. ដែលមិនដើរដាន ។

**អនាប្ត** គុ. ដែលមិនប្រញាប្តហើយ ។ - **ការិន៍** គុ អ្នកធ្វើការដែល . . . . មិនប្រញាប្តហើយ ។

**អនាជ្ញា** ស្រី អនាជ្ញា, ការមិនមែនជាអាជ្ញា ។

**អនាជ្ញាត** គុ. ដែល . . . មិនស្គាល់ហើយ, ដែលគេមិនដែលស្គាល់ ឬ មិនដែលដឹង ។

**អនាឍ្យ** គុ. ដែលមិនមានទ្រព្យ, ក្រីក្រ ។

អនាតប គុ ដែលមិនមានកំដៅ, ដែលមិនក្ដៅ, ដែលមានម្លប់។

អនាតុរ គុ. ដែលមិនឈឺ, ដែលជានា, មាំមួន, ដែលមិនរកដោយកាម ។

អនាត្មន៑ បុ. អនាត្មន ។ គុ. ដែលមិនមានសេចក្ដីដឹងខុសត្រូវ ។

អនាត្ម- ត្វ នបុំ. ភាវនៃបុគ្គលមិនមានអាត្មន ។ អនាត្ម-វន្ត៑ គុ ដែលមិនមានអាត្មា, ដែលមិនមែនជាម្ចាស់ខ្លួន, ដែលមិនដឹងក្តី ។ – (អនាត្ម) ជ្ញ. គុ. ដែលមិនដឹងខុសត្រូវ, ជ្ញតា ស្រី. ភាវនៃបុគ្គលមិនដឹងសេចក្ដីខុសត្រូវ ។–វេទិន៑ គុ. ដែលមិនដឹងអាត្មា, ។ – វេទិតា ស្រី. ភាវនៃបុគ្គលមិនដឹងអាត្មា, សេចក្ដីល្ងង់ខ្លៅ ។ – សម្បន្ន គុ. ដែលមិនបរិបូណ៌ដោយអាត្មា, ដែលមិនមានសេចក្ដីដឹងខុសត្រូវ ។

អនាត្មីន គុ. ដែលប្រព្រឹត្តទៅតាមខ្លួន ។

អនាត្មីយ គុ. ដែលមិនមែនជារបស់ខ្លួន ។

អនាត្ម្យ គុ. ដែលមិនមែនខ្លួន, នបុំ. កិរិយាមិនមែនខ្លួន, មោហធម៌ ។

អនាថ គុ. ដែលមិនមែនទីពឹង, តែលតោល, ក្រីក្រ ។ ត្វ–ភា្វ ជាអ្នកមិនមានទីពឹង ។ –សភា ស្រី. អនាថសភា, គ្រឹហាដែនជនក្រីក្រ។

(នៅមានត)

# បរមាធិប្បាយអំពីសុរា

និពន្ធដោយ

កុសលានុរក្ខិតោ ភិក្ខុ ឡាយ គ្រី ហៅ កូ

ពិនិត្យដោយលោក ញូង សឿង

មុននឹងប្រព្រឹត្តនូវអំពើអ្វីមួយ មនុស្សអ្នកប្រព្រឹត្តសុទ្ធតែយល់ខ្លួនឯងថាជាហេតុនៃសេចក្តីសុខ-ចំរើនរបស់ខ្លួន ទើបហ៊ានប្រព្រឹត្តធ្វើ ឬព្យាយាមតស៊ូចំពោះការងារនោះ ៗ ដូចជនខ្លះព្យាយាមវាយទ្រព្យធ្វើមាន ព្រោះសង្ឃឹមមកវិញនូវប្រយោជន៍ពិសេសណាមួយ ជនខ្លះលះបង់កាមសុខ គោរសក់ ស្លៀកសពាក់ស សុំសីលដប់រៀនធម៌កម្មដ្ឋាន ព្រោះយល់ថាជាហេតុនៃសេចក្តីសុខស្ថាពររបស់ខ្លួន ៗ ជនខ្លះព្យាយាមលបលាក់លួចទ្រព្យអ្នកដទៃ ព្រោះសង្ឃឹមថាជាហេតុនៃសេចក្តីសុខរបស់ខ្លួន . . . ជនខ្លះទៀតព្យាយាមផឹកសុរា ព្រោះជឿជាក់ថា សុរាជាឱសថសម្រាប់ជួយខ្លួនឲ្យបានសុខកាយសប្បាយចិត្ត ម្ល៉យល់ថា សុរាជាគ្រឿងលើកតម្លៃមនុស្ស បើមនុស្សណាមិនចេះផឹក ឈ្មោះថាជាជនបោកថយ ឬជាមនុស្សដើរមិនទាន់សម័យ ៗ ប៉ុន្តែព្រះពុទ្ធបរមគ្រូទ្រង់ត្រាស់សំដែងថា **បុគ្គលអ្នកលេងសុរា ឈ្មោះថាបំផ្លាញខ្លួនឲ្យវិនាសធំ ដោយខ្លួនឯង ៗ**

បុគ្គលអ្នកលេងសុរា បានដល់មនុស្សអ្នកផឹកទឹកស្រវឹងផ្សេង ៗ មានជាអាទិ៍ ស្រាស ស្រាថ្នាំ ហេណ្ណេស្ស៊ី វីស្គី ប៊ីស្គី សាមប៉ាញ កូញ៉ាក់ ម៉ាកតែល រូបន្នា រ៉ូម ប៊ីយ៉ែរ ទឹកត្នោតជូរ អាភៀន កញ្ឆា ។ មនុស្សខ្លះយល់ថា ទឹកស្រវឹងឬគ្រឿងញៀនទាំងអស់នេះ ជារបស់ប្រសើរថ្លៃថ្នូរក្រៃលែងបំផុតនាលោកិយនេះ ។

សេចក្តីយល់នេះ ឈ្មោះថាត្រូវរបស់អ្នកចូលចិត្តហើយ ប៉ុន្តែវាទាស់ខុសនឹងទស្សនៈរបស់អ្នកប្រាជ្ញគ្រប់សម័យ មានព្រះពុទ្ធជាដើម សូម្បីអ្នកប្រាជ្ញសម័យបច្ចុប្បន្ន គោលគឺអ្នកប្រាជ្ញខាងវិជ្ជាពេទ្យ វិជ្ជាអនាម័យ ក៏មានទស្សនៈដូចព្រះពុទ្ធដែរ ។ ដូច្នេះ វិជ្ជាពុទ្ធសាសនាក្តី វិជ្ជាពេទ្យក្តី សុទ្ធតែហាមមនុស្សមិនឲ្យផឹកទឹកស្រវឹងដូចគ្នា ស្របគ្នា មិនមានទស្សនៈខុសគ្នាឡើយ ប៉ុន្តែផលិតផលសុរាបានលក់លាស់សម្បើម ។

ហេតុនេះ ជាដំបូង សូមលាតត្រដាងនូវគុណនិងទោសនៃសុរាតាមបែបពាណិជ្ជកម្មសិន ។ ពាណិជ្ជកម្មជាសាខាមួយនៃសេដ្ឋកិច្ច ។ រដ្ឋទាំងឡាយនៅនាជុំពិភពលោកនេះ ដែលមានជីវិតរស់នៅដោយឯករាជបរិបូរបាន ព្រោះអាស្រ័យមានសេដ្ឋកិច្ចមាំមួនជាមូលដ្ឋាន ។ ហេតុនេះបានជាសុរាមានឈ្មោះច្រើនបែប សម្បូរពោរពាស មានក្លិនក្រអូបឈ្ងុយប្លែក ៗ គួរឲ្យចង់ផឹក ចង់សេព ។ ការផ្សំសុរាឲ្យមានរសជាតិនិងក្លិនកាន់តែល្អឡើង ៗ ដោយអាស្រ័យពួកពាណិជករខាងសុរា ខំប្រឹងរកជីវជាតិ

នៃវត្ថុធាតុផ្សេងៗតាមវិជ្ជាវិទ្យាសាស្ត្រគីមី ហើយគេធ្វើការឃោសនា អួតអំពីគុណភាពនៃសុរា ថាអាចជួយលើកធាតុ ជួយបន្ថែមអាយុឲ្យបានវែងៗ ល។

ការឃោសនានោះ ទុកជាការធម្មតាទេ ព្រោះពាណិជត្រូវការលក់សុរាឲ្យដាច់ច្រើន ដើម្បីឲ្យឧស្សាហកម្មសុរារបស់ខ្លួនបានលូតលាស់ចំរើនកើនចំនួនជាលំដាប់ ៗ ចិត្តមនុស្សតែងតែទន់ទៅតាមសំដីលួងលោមអង្វរករ ឬស្របតាមអំនួតឃោសនា ហើយភ្លេចគិត វិនិច្ឆ័យរាវរកគុណទោសឬខុសត្រូវ ៗ ហេតុនេះបានជាសម័យបច្ចុប្បន្ន សុរាជាវត្ថុចាំបាច់នៃមនុស្សមួយភាគធំ ជាពិសេស នៅពេលអាពាហ៍ពិពាហ៍ សូម្បីត្រកូលជាពុទ្ធសាសនិកដែលបានប្រគល់កាយថ្វាយខ្លួន ចំពោះព្រះរតនត្រ័យយ៉ាងមុតមាំហើយក៏ដោយ ត្រូវតែលៃលករកសុរាដែលអ្នកស្រុកនិយមថាល្អ ដូចហេណេស្ស៊ី វីស្គី ប៊ីស្គី រ៉ូម ម៉ាកតែលជាដើម ៗ បើខ្វះសុរាជាទីគាប់ចិត្តភ្ញៀវ ភ្ញៀវខ្លះដែលមកជាកិត្តិយសក្នុងពេលមង្គលនោះ ត្រូវបន្ថយប្រាក់ចំណងដៃ ព្រោះគេយល់ថា អ្នកធ្វើការកំណាញ់ មិនហ៊ានចាយប្រាក់ ៗ ត្រង់ចំណុចនេះ យើងគួរពិចារណាអំពីបុព្វហេតុនៃប្រាក់ចំណងដៃ ថាតើបុព្វបុរសយើងបានបង្កើតឡើង ដើម្បីសងថ្លៃស្រានិងថ្លៃតុ ឬបង្កើតឡើងដើម្បីជួយគូអាពាហ៍ពិពាហ៍ឲ្យមានដើមទុនសម្រាប់រកស៊ី ? សូមពិចារណាមើល!

ទោះម្ដេចម្ដា ពាណិជសុរាចំណេញក្នុងមួយឆ្នាំ ៗ ស្ទើររាប់ប្រាក់មិនអស់ ព្រោះសុរាមានប្រយោជន៍ច្រើនប្រការ ដូចជាក្នុងមន្ទីរពេទ្យ គេប្រើសុរា (៩០ អង្សា) សម្រាប់សម្លាប់អតិសុខុមប្រាណ និងសម្រាប់ផ្សំថ្នាំផ្នែកខ្លះ មានថ្នាំក្អក ថ្នាំលើកកម្លាំង ។ល។ ក្នុងឧស្សាហកម្ម គេប្រើសុរាធ្វើទឹកអប់ ចំអិនសាច់ ដុតម៉ាស៊ីនឲ្យដើរ រំលាយវត្ថុច្រើនយ៉ាងមានជ័រឈើផ្សេង ៗ ជាដើម ។

ដូច្នេះ ឧស្សាហកម្មសុរាប្រាកដជាឲ្យផលប្រយោជន៍ដល់សង្គមមនុស្សមិនតិចទេ ។ យើងដឹងទៀតថា ឧស្សាហកម្មសុរាអាចជួយផ្នែកកសិកម្មឲ្យមានជីវិតធូរស្រាលផងដែរ ព្រោះសុរាកើតឡើងដោយអាស្រ័យផលិតផលកសិកម្ម ដូចជាផ្លែឈើដែលមានទឹកផ្អែម (ម្នាស់ ទំពាំងបាយជូរ ធាយថៅ អំពៅ ទឹកត្នោត ស្ករ . . .) ឬធញ្ញជាតិផ្សេង ៗ មានអង្ករពោតដំឡូងជាដើម ។ ពាណិជ្ជកម្មសុរាឲ្យផលចំណេញជាច្រើនលានរៀលក្នុងមួយឆ្នាំ ៗ ។

ប៉ុន្តែយើងកុំភ្លេចថា មនុស្សមួយភាគធំដែលនិយមប្រើសុរាក្នុងករណីបំផ្លាញខ្លួនឯង បំផ្លាញថវិកាជាតិឲ្យអស់ហិនហោចទៅវិញ ៗ ជាពិសេសឧស្សាហកម្មសុរាសម្រាប់ផឹក គឺយើងមិននិយាយអំពីសុរា ៩០ អង្សាសម្រាប់ដុត សម្រាប់ពេទ្យ សម្រាប់ទឹកអប់ជាដើមទេ ។ ឧទាហរណ៍ប្រាក់ចំណេញពីការលក់សុរាសម្រាប់ផឹក ក្នុងមួយឆ្នាំបានមួយលានរៀល ៗ

តើអ្នកផឹកទាំងនោះ ត្រូវក្រសួងសុខាភិបាល ជួយព្យាបាលជម្ងឺដែលបណ្ដាលមកពីសុរាវិញដែរឬទេ? បើដូច្នោះមែន តើថវិកាជាតិដែលចំណេញពីសុរា អាចទប់ទល់នឹងចំណាយខាងការព្យាបាលអាការរោគនៃប្រជាករបានដែរឬទេ? ទោះណាជាទប់ទល់បាន ហើយនៅសល់ចំណេញខ្លះ តើការថមថយកម្លាំងកាយ កម្លាំងស្មារតី និងការខូចខាតពេលវេលាកសាងប្រយោជន៍ជាតិនៃជនអ្នកជម្ងឺនោះ មានដែរឬទេ?

ដូច្នេះ លទ្ធផលដែលកើតពីសុរាសម្រាប់ផឹក មិនមែនជាហេតុនាំឲ្យចំរើនឡើយ ព្រោះចំណេញតែខាងការលក់សុរា ហើយត្រូវខាតខាងការព្យាបាលជម្ងឺប្រជាជន ៗ ព្រោះហេតុនោះបានជាព្រះសមណគោតមទ្រង់ហាមមនុស្សមិនឲ្យរកជំនួញសុរា ។

ទេ, មិនរកស៊ីលក់សុរាម្ដេចកើត! បើមនុស្សមួយភាគធំ និយមផឹកស្ទើរតែខានមិនបានទៅហើយ ៗ ម្យ៉ាងទៀត អ្នកនិយមផឹកទាំងនោះសុទ្ធតែត្រូវចាយប្រាក់ ទើបបានស្រាមកផឹក (មានផឹកស្រាឥតថ្លៃខ្លះដែរ ដូចជាមិត្តភក្តិបបួលឲ្យផឹក ឬជប់លៀងមួយដងមួយកាល) បើសុរាមិនមានប្រយោជន៍ចំពោះខ្លួនទេ ម្ដេចក៏គេហ៊ានទិញមកផឹករៀងរាល់ថ្ងៃ?

រឿងនេះ សូមធ្វើការដោះស្រាយ រាវរកនូវគុណនិងទោសនៃសុរាតាមបែបវិជ្ជាពេទ្យដូចតទៅនេះ ៖

សុរាជាថ្នាំពិសពុល វាអាចធ្វើមនុស្សដែលជានាត្រឹមត្រូវឲ្យក្លាយទៅជាមនុស្សប្លែកខុសពីធម្មតា ។ អ្នកប្រាជ្ញបានចែកឥទ្ធិពលសុរានេះជាបីសម័យគឺៈ សម័យក្លាហាន សម័យទន់ខ្សោយ និង សម័យគ្រាំគ្រាពិរៃ ។

ទី ១ – សម័យក្លាហាន ៖ សុរាហូរកាត់បំពង់កជ្រាបចូលដល់ក្រពះនៃមនុស្សក្នុងរយៈ ១៥ នាទីកន្លងមក វាធ្វើរូបកាយ - ស្មារតី - ចិត្តគំនិតនៃអ្នកប្រមឹកនេះ ឲ្យក្លាយទៅជាមនុស្សមានអាការប្លែកពីធម្មតា ព្រោះឥទ្ធិពលនៃសុរាបានសំដែងសព្វសព៌ាង្គកាយ គឺធ្វើអ្នកប្រមឹកនេះឲ្យមានកម្លាំង ឲ្យកើតសេចក្ដីក្លាហាន មានស្មាហាប់ មានប្រាជ្ញាវាងវៃ មានសេចក្ដីឧស្សាហ៍ខ្នះខ្នែង មានសំដីថ្វីមាត់ ឡូឡា អួតអាងហេតុការណ៍ជាអាថ៌កំបាំងផ្សេង ៗ មានអំពើឃាតកម្មនិងលួចប្លន់ ឬ និយាយហែកកេរ្ដិ៍ឈ្មោះនៃគ្រួសារជាដើម ឬក៏និយាយឡូឡាបន្លាចបន្លាក់ខ្លួនឯង ជាសំដីបៀតបៀនខ្លួនឯង ពុំនោះសោតដៀមដាមរករឿងហេតុអ្នកដទៃ ៗ សុរាខ្លះធ្វើឲ្យអ្នកផឹកធ្លាញ់ប្រាយ ព្រោះវាបានចូលទៅជួយសរសៃប្រសាទឲ្យក្លៀវក្លាដែលអាចទទួលអារម្មណ៍ផ្សេង ៗ មានរសជាតិនៃអាហារជាដើមបានដោយងាយ ៗ ជួនកាលវាធ្វើមនុស្សសុចរិតឲ្យក្លាយទៅជាក្លាហានក្នុងអំពើអាក្រក់ មានហ៊ានជេរ វាយ ទាត់ ធាក់ កាប់ចាក់ បាញ់ សម្លាប់អ្នកដទៃ ឬបៀតបៀនខ្លួនឯង ដោយឥតញញើត ។ ជួនកាល វាធ្វើមនុស្សអាក្រក់ឲ្យក្លាយទៅជាក្លាហានក្នុងអំពើល្អ មានការជ្រះថ្លាក្នុងគុណ

ព្រះរតនត្រ័យ បញ្ចេញសទ្ធាប្រកាសប្រាប់មហាជនថា ខ្លួនទីពឹងបំណាយទ្រព្យសម្បត្តិកសាងកុដិ សាលា វិហារ ឈាបនដ្ឋានជាដើម ឬសំដែងសេចក្ដីនឹករលឹកដល់គុណូបការៈនៃបុព្វការីបុគ្គលទាំងឡាយ មានមាតា-បិតាដ៏ជូនដ៏តាជាដើម ។ ប៉ុន្តែ បន្ទាប់ពីសេចក្ដីក្លាហាន ១៥ នាទីមក ស្រាផ្ដើមអុកផឹកឲ្យឈានចូលដល់សម័យទន់ខ្សោយ ។

ទី ២ – សម័យទន់ខ្សោយ : គឺជាសម័យដែលស្រាធ្វើកាយមនុស្សនេះ ឲ្យថមថយកម្លាំង ថយសេចក្ដីក្លាហាន ថយសេចក្ដីអង់អាចថយប្រាជ្ញាប៉ុ៉ាន់ ខ្លួន មិនចង់និយាយស្ដី នឹកព្រួយបារម្ភស្ដាយបំពោះសំដីដែលខ្លួននិយាយអួតអាងហួស ឬ បន្ទាបបន្ថោកហួសទៅហើយ ។ដើម្បីដឹងឥទ្ធិពលនៃស្រា គេអាចធ្វើបញ្ជាក់អុកផឹកដោយវិធីគោះក្បាលជង្គង់ គឺគេឲ្យអង្គុយលើកៅអីសំយុងជើងដែលបង្កើតជាមុម ៩០ អង្សា ដូចឧទាហរណ៍តទៅនេះ :

– មនុស្សធម្មតាមិនទាន់ផឹក កាលគេគោះ ជើងវាត់ឡើង ៤៥ អង្សា

– មនុស្សធម្មតាផឹកហើយ ១៥ នាទី កាលគេគោះ ជើងវាត់ឡើង ៩០ អង្សា គឺវាត់ឡើងត្រង់តាមគ្លៅ ។

– មនុស្សធម្មតាផឹកហើយ ៣០ នាទី កាលគេគោះ ជើងវាត់ឡើង ១៥ អង្សា គឺខ្សោយជាងមុនពេលផឹក ២ ភាគ ៣ ។

កាលបើពិសោធឃើញថា សរសៃវិញ្ញាណទាំងពងកាយខ្វាំងក្លា

ប្ទន់ទៅក្រោយហើយ សរសៃវិញ្ញាណដទៃទៀតគ្រប់ផ្នែកក៏ខ្ចាំងក្បាប្ទន់ទៅក្រោយដែរ នេះជាសេចក្ដីពិតដែលពិនិត្យឃើញទីនផ្នែកឃើនកល់គ្នា ។

ដូច្នេះហើយ បានជាអ្នកផឹកខ្លះនិយាយថា បើមិនផឹក ស៊ីបាយមិនឆ្ងាញ់ ធ្វើការមិនកើត ឥតកម្លាំងកាយ-ចិត្តទេ ។ ដើម្បីធ្វើឲ្យបានសម្រេច អ្នកផឹកជោគផឹកជាំ ត្រូវតែផឹកតទៅទៀត ឧទាហរណ៍ អ្នកប្រមឹកមុនផឹកលើកអង្ករមួយបាវមិនរួច ផឹកមួយកែវ គេលើកអង្ករនោះរួច លើករួចដោយកំឡាំងសុរាជួយប្រានស្ពាមពលនៃសរីរាង្គគ្រប់ផ្នែក ។ កន្លងមក ២៥ នាទី អ្នកដដែលនោះលើកអង្ករមួយបាវនោះលែងរួចទៀត ។ ដូច្នេះ ត្រូវតែផឹកទៀត លុះផឹកហើយ សមត្ថភាពគឺកម្លាំងកាយ-ស្មារតី កើតដូចមុន ។ ហេតុនេះបានជាអ្នកផឹក ចេះតែព្យាយាមផឹកជាលំដាប់លំដោយមិនព្រមឈប់ផឹក ព្រោះការងារគោជរកម្ម ឬបាបមិត្រ តម្រូវឲ្យផឹក ទើបអាចបំពេញកិច្ចការទាំងនោះឲ្យសម្រេចបាន ។

ប៉ុន្តែ រាងកាយទាំងមូលនៃអ្នកប្រមឹក ត្រូវគ្រាំគ្រាទ្រុឌទ្រោមចុះជាលំដាប់រាល់ៗថ្ងៃ ព្រោះស្ពាមពលនៃសុរាផុតកំដៅជានិរន្តរ៍ ឥតឈប់ឈរ ។

ម្យ៉ាងទៀត រូបរាងកាយមនុស្ស មិនអាចផ្លាស់ប្ដូរសរីរាវយវៈផ្សេងៗ មានការផ្លាស់ថ្លើម សួត-បេះដូង-ខួរក្បាល-ក្រពះ-ពោះវៀន-សរសៃវិញ្ញាណជាដើមបាន ដូចជាសម្ភារៈឡានមានពិស្តុង ដង់យ៉េន (Bielle) ស៊ីឡាំងជាដើមនៃម៉ាស៊ីនបានទេ ។ ម៉ាស៊ីនទាំងនោះ កាលជាងបង្កើត

មក គេបានវាស់កម្លាំងវាស្រេច ដូចជាម៉ាស៊ីនកម្លាំងមួយសេះ-ពីរសេះ-បីសេះ-ដប់សេះ-ម្ភៃសេះ ជាដើម គេចេះប្រើ គេត្រូវលៃលកប្រើតាមបំណងនៃអ្នកបង្កើតម៉ាស៊ីននោះ ទើបអាយុនៃម៉ាស៊ីននោះអាចឋិតថេរត្រឹមត្រូវតាមពាក្យសន្យា ឬ ច្បាប់កម្រិតនៃអ្នកកសាង ។

ឧទាហរណ៍ ឡានមួយ អ្នកកសាងបានធ្វើកន្លែងឲ្យអង្គុយចំនួនមនុស្ស ៥ នាក់ (ទម្ងន់មធ្យម ២៥០ គក.) គេធានាថាអាចប្រើបាន ៣៦០.០០០ គីឡូម៉ែត្រ (ឬគេសន្យាថារយៈកាល ១០ ឆ្នាំទើបខូច បើប្រើក្នុងមួយថ្ងៃ ១០០ គីឡូម៉ែត្រ ដោយដឹកទម្ងន់តែ ២៥០ គីឡូក្រាម) ។ ប៉ុន្តែ បើអ្នកប្រើមិនគោរពតាមច្បាប់នៃសង្ខារ ឬច្បាប់នៃធម្មជាតិទេ ចេះតែប្រើតាមអំពើចិត្តមានការដាក់លើសទម្ងន់ជាដើម កម្លាំង និង អាយុនៃឡាននេះ ក៏ត្រូវថយចុះ ពោលគឺឆាប់ខូច ពេលខូចគេអាចផ្លាស់ប្តូរជួសជុលបានដោយងាយ ព្រោះឡានជាគ្រឿងម៉ាស៊ីន ធ្វើដោយដែក ប៉ុន្តែការជួសជុលផ្លាស់ប្តូរ ធ្វើឲ្យប្រើតទៅទៀតកើតនេះ មិនពូកែមាំមួនដូចថ្មី កាលមិនទាន់ខូចទេ ។

ចំណែករូបរាងកាយនៃមនុស្ស ដែលធម្មជាតិតាក់តែងមក មិនមែនជាដែកទេ តើយើងអាចផ្លាស់ប្តូរដូចម៉ាស៊ីនបានដែរឬទេ ? ឮគេថាបានខ្លះដែរ ដូចជាការប្តូរ ឬ ជួសជុលភ្នែក តដៃ-ជើង កែពេតថ្លើម-បេះដូង-សួត-ខួរក្បាលជាដើម តាមបែបវិជ្ជាពេទ្យសម័យទំនើប ។ ការ

ផ្លាស់ប្តូរផួសផុលនេះ តើត្រូវមានការៈធ្ងន់ធ្លាក់មកលើរូបកាយយ៉ាងណាខ្លះ? ត្រូវទទួលគ្រោះថ្នាក់ច្រើនប្រការគឺ :

– ឈឺចាប់តើតពេញរាងកាយ

– ដេកស្តុកស្តឹងលើគ្រែពេទ្យអស់រយៈកាលយ៉ាងយូរ

– ដាច់ទ្រព្យសម្បត្តិច្រើនពាន់ម៉ឺនរៀល

– បង្កើតទុក្ខព្រួយដល់ក្រុមញាតិ ក្រុមគ្រួសារ ។ល។

ប៉ុន្តែ ពាក្យថាប្តូរផ្លាស់ព្យាបាលកែកុនបាននេះ មិនទាន់ប្រាកដមួយរយភាគរយទេ ព្រោះរបស់ដែលខូចខាតហើយ គេយកទៅកែកុនផួសផុល ក៏មិនដែលមាំ-ល្អ-ពូកែដូចដើមទេ ក៏តែងតែថយចុះគុណភាពជាដរាប ជួនកាលកែមិនកើត ត្រូវស្លាប់ក៏មានច្រើនដែរ ។ ដូច្នេះ រូបរាងកាយនៃអ្នកប្រមឹក ត្រូវតែគ្រាំគ្រា សមតាមការផឹកតិចឬច្រើន ដែលទាក់ទងទៅនឹងរយៈពេលវេលា យូរថ្ងៃ-ខែ-ឆ្នាំ ឬក៏ឆាប់ ។ រូបរាងកាយនៃអ្នកប្រមឹកដើងចាស់ ក្លាយសភាពទៅជាគ្រាំគ្រាពុំរ៉ៃ គួរឲ្យអាណោចអាធ័មក្នុងចិត្តណាស់ ។

ទី ៣ – សម័យគ្រាំគ្រាពុំរ៉ៃ : អ្នកព្យាយាមផឹក ផឹកយូរខែយូរឆ្នាំកន្លងមក គេឃើញ :

– សាច់ហើមព្រួក ៗ ពណ៌លឿងដូចចំបើង

– ភ្នែកលឿងស្លេកមើលទៅត្រឹម ៗ ពុំស្រួចច្បាស់ល្អ

- ស្បែកលឿងស្លូតស្តើង
- ពោះប៉ោង ឡើងសរសៃវាមតាំងពីពោះរហូតដល់ទ្រូង ថ្លើមហើមធំធ្លាក់ចុះមកក្រោមឆ្អឹងជំនីរ ហើយរឹង
- ខួរក្បាលខ្សោយ ស្មារតីផុត ៗ
- ស្ពតស្ពូត ពិបាកដកដង្ហើម
- ពោះវៀនក្តៅស្ពូត ឬ រលាក
- រាក ស្ពូត ឬ ស្ពុះ
- អាយុខ្លី
- ឈឺចាប់បន្តិចបន្តួច តែឡពិបាកព្យាបាល

ឧទាហរណ៍ : ពេលគ្រុនផ្តាសាយ ឬ ពេលកញ្ជ្រិល ឬក៏ពេលស្រាល ៗ ដទៃទៀតកើតឡើង អាចធ្វើអ្នកផឹកជោកជាំនេះឲ្យស្លាប់បានដោយងាយ ព្រោះសរីរាង្គគ្រប់ផ្នែក ត្រូវគ្រាំគ្រាអស់ហើយ ។ កាលណាអ្នកផឹកជោកជាំនេះជានជម្ងឺមកដល់ គេមិនត្រូវបញ្ឈប់លែងឲ្យផឹកតែម្តងទេ គឺគេត្រូវលៃលកបន្ថយបន្តិចម្តង ៗ ជាលំដាប់ ។ បើបញ្ឈប់ព្រឹបតែម្តង អ្នកជម្ងឺនេះ ជួនកាលត្រូវទទួលគ្រោះថ្នាក់ដល់ស្លាប់ ជួនកាលក្លាយទៅជាមនុស្សឆ្កួតភ្លាមក៏មាន ។

ទោះជាមិនមានជម្ងឺធ្ងន់ជាក់ស្តែងក៏ដោយ អ្នកផឹកជោកជាំនេះ អាចក្លាយទៅជាមនុស្សឆ្កួត ឬ ស្រវឹង ដោយមិនបាច់ផឹកស្រាថ្មីទៀតទេ ព្រោះ

ផលវិបាកនៃស្រាក្នុងអតីតកាលនោះ បានផុតកំដៅប្រព័ន្ធសរសៃប្រសាទ គ្រប់ផ្នែក មានខួរក្បាលធំ កណ្ដាល-តូចជាដើម ឲ្យស៊ាំក្នុងដំណើរឆ្កួតស្រវឹងហើយ ៗ ហេតុនេះ បានជាយើងឃើញអ្នកប្រមឹកដើងចាស់ ច្រើនតែនិយាយឡូឡា អ៊ូរទាំដេរប្រទេច ក៏យបានឆ្ងាំង អួតអាង ពីសេចក្ដីក្លាហានរបស់ខ្លួន ។ល។ ឬកំផ្ទឹងតើយ មិននិយាយស្ដី ប្រៀបដូចមនុស្សឆ្កួតមិននិយាយ បើហាមាត់និយាយ ៗ ខុសតែម្ដង ។ល។

អ្នកប្រមឹកដោកតែងទទួលផលជាទុក្ខដាក់ស្ដែងគឺ :

— ក្រទ្រព្យសម្បត្តិព្រោះផឹកស្រា

— បើមានគ្រួសារ គ្រួសារនៅជាមួយមិនបាន ព្រោះស្រវឹងឡូឡានិយាយហែកកេរ្ដិ៍គ្រួសារឯង

— ឥតអៀនខ្មាស មានការលែងខ្លួនទទេដូចតិរច្ឆាន ឬដេកនៅលើចិញ្ចើមថ្នល់ ឬក៏ដើរដួលម្នាក់ឯងជាដើម

-- ខូចកេរ្ដិ៍ឈ្មោះ កិត្តិយសនៃគ្រួសាររហូតដល់សូន្យពូជ

— មានមិត្តភក្ដិសុទ្ធតែបាបមិត្រ គឺមិត្តនាំទៅកាន់សេចក្ដីវិនាស ហើយកត់សំគាល់បាបមិត្រនោះថាជាកល្យាណមិត្រ ឬថាជាកល្យាណជន

— ស្អប់កល្យាណមិត្រ ព្រោះសំគាល់ថាជាជនទុច្ចរិត ។

ព្រះពុទ្ធជាបបញ្ជាស់ថា មនុស្សណាគប់ចិត្តអ្នកមានចរិយាថ្លៃថ្នូរ មិនរើរពយ មិនឡូឡា មិនរឡេមឡោម គឺថាចូលចិត្តមនុស្សសុភាព

ស្លូតត្រង់ ចរិយាទន់ភ្លន់ មានស្មារតីមាំមួន មានសតិរស់រវើក មានសម្បជញ្ញៈរឹងប៉ឹង ៗ រូបកាយមនុស្សលោកទាំងអស់ ដែលអាចជួបប្រទះសុភមង្គលបានដោយអាស្រ័យ សតិសម្បជញ្ញៈជាមគ្គុទេសក៍ ព្រោះសតិជាគ្រឿងដាស់តឿនរំលឹកសព្វកិច្ចការ សម្បជញ្ញៈជាគ្រឿងវិនិច្ឆ័យពិភាក្សាពារកហេតុផល ឲ្យយល់ច្បាស់នូវហេតុចំរើនវិនាស ខុសត្រូវបាបបុណ្យ គុណទោស ។ល។

មនុស្សខ្វះសតិសម្បជញ្ញៈ បានដល់មនុស្សប្រមឹកជោក បើបច្ចុប្បន្នកាលនេះមិនបានផឹក ក៏អតីតកាលធ្លាប់បានផឹកដែរ ហេតុនេះបានជាបុរសស្ត្រីខ្វះ ត្រូវទទួលមតកគឺខ្វះសតិសម្បជញ្ញៈ ឬក្លាយទៅជាមនុស្សឆ្កួត ឬក៏មិនសូវមានប្រាជ្ញា វិចារណញ្ញាណ ព្រោះផលវិបាកនៃថ្នាំពិសពុល គឺសុរាដែលខ្លួនធ្លាប់បានសេពទុកមកយូរហើយ ។ កាលបើខ្វះសតិសម្បជញ្ញៈហើយ មនុស្សត្រូវធ្លាក់ចូលទៅក្នុងសេចក្ដីធ្វេសប្រហែស (បមាទធម៌) គ្រប់កិច្ចការទាំងអស់ ពោលគឺធ្វេសប្រហែលក្នុងកងការកុសលគ្រប់ជំពូកមាន ទាន សីល ភាវនា កតញ្ញុតា កតវេទិតា សុចរិតយុត្តិធម៌ ខន្តី សន្តោស សច្ច ជាដើម ហើយចូលចិត្តប្រព្រឹត្តអកុសលកម្មផ្សេងៗ មានការសម្លាប់សត្វ លួចទ្រព្យគេ លួចប្រពន្ធគេ លេងល្បែងភ្នាល់ជាដើម ។ មនុស្សឋិតនៅក្នុងបមាទធម៌នេះ ព្រះសក្យមុនីគោតមបរមគ្រូហៅថា មនុស្សស្លាប់ស្រេចទៅហើយ ឬអន់ជាងមនុស្ស

ស្តាប់ទៅទៀត ព្រោះពេលវេលានៃមនុស្សប្រមាទនេះ ជាពេលវេលាគ្រាំគ្រាពន្លិកាយឥតអំពើ ឬពេលរេចរិលសេចក្តីចំរើនផ្លូវខ្លួន - ញាតិនិងពិភពលោក ឬថាជាពេលវេលាកសាងតែអកុសលកម្ម ដែលទុកដូចជាកសាងគុកប្រាក់ ខ្នោះឃ្នាង គឺឋាននរក ឲ្យកាន់តែមាំឡើង ៗ ដាក់ខ្លួនឯងតែប៉ុណ្ណោះ ៗ ដូច្នេះ ការលេងស្រា ប្រាកដជាបំផ្លាញខ្លួនឯងគ្រួសារឯង ជាតិឯង ឲ្យខូចប្រយោជន៍បច្ចុប្បន្ននិងបរលោក ៗ

ក្នុងសិង្គាលោវាទសូត្រ គម្ពីរទីឃនិកាយ បាដិកវគ្គ ព្រះពុទ្ធទ្រង់សំដែងថា ការផឹកសុរានាំឲ្យមានទោសជាលោកិយ ៦ យ៉ាងគឺ :

ទី ១ – នាំឲ្យវិនាសទ្រព្យសម្បត្តិឃើញជាក់ស្តែងក្នុងលោកនេះ (សន្ទិដ្ឋិកា ធនជានិ) គឺវិនាសទ្រព្យធនដែលមានស្រាប់ព្រោះចាយក្នុងការទិញស្រា ៗ ពេលស្រវឹង ចាយខ្ជះខ្ជាយឥតគិតពីទ្រព្យមានស្រាប់ឬមិនមានឡើយ បានដល់ការចាយទិញគ្រឿងស៊ីផឹកផ្សេង ៗ ឥតសណ្តាប់ធ្នាប់ ឬលេងល្បែងស្រីប្រុស ល្បែងភ្នាល់ ៗល។ ទ្រព្យដែលត្រូវចំរើនឡើង ក៏ខូចខាតខានចំរើនឡើង ព្រោះរវល់តែយកពេលវេលាចំណេញប្រាក់ ទៅបំផ្លាញឲ្យក្លាយទៅជាពេលវេលាប្រមឹកទៅវិញ ៗ ដូច្នេះទ្រព្យចាស់ក៏អស់ទៅ ទ្រព្យកើតថ្មីក៏ខានកើតឡើង ពោលគឺវិនាសធនធានអស់រលីង ៗ

ទី ២ - នាំឲ្យកើតការឈ្លោះប្រកែកគ្នា (កលហប្បវឌ្ឍនី) គឺឈ្លោះ

តែខ្លួនឯងម្នាក់ឯង គ្រួសារឯងញាតិមិត្រជិតខាងឯង ប្រៀបដូចមនុស្សឆ្កួតឥតដឹងខុសត្រូវ ។

ទី ៣ – នាំឲ្យកើតរោគផ្សេង ៗ មានរោគក្អក-ត្រចៀក-ច្រមុះ អណ្តាត-កាយ-ខួរក្បាល បេះដូងជាដើម (រោគានំ អាយតនំ) ។

ទី ៤ – នាំឲ្យខូចកេរ្តិ៍ឈ្មោះ (អកិត្តិសញ្ជននី) គឺត្រូវគេតិះដៀល ព្រោះសំដែងអាការ ឬកពាខុសពីច្បាប់ផ្លូវលោកនិងផ្លូវធម៌ ។

ទី ៥ – នាំឲ្យហ៊ានបញ្ចេញកេរ្តិ៍ខ្មាសរបស់ខ្លួន ឬគ្រួសារខ្លួនបង្ហាញអ្នកដទៃ (ហិរិកោបីននិទ្ទំសនី) ពោលគឺឥតមានការអៀនខ្មាស ឬលាក់លាម ហេតុភេទអាក្រក់អ្វីបន្តិចបន្តួចសោះឡើយ ។

ទី ៦ – នាំឲ្យអាប់អន់ថយចុះនៃប្រាជ្ញាបារមី (បញ្ញាយ ទុព្វលីករណី) គឺខូចប្រព័ន្ធសរសៃប្រសាទគ្រប់ផ្នែក សរសៃប្រសាទជាវត្ថុសម្រាប់ទ្រ-ទ្រង់ការបេះដឹង យល់ ស្តាប់ ពិចារណា សតិ សម្បជញ្ញៈ ពោលគឺជាគ្រឿងកត់បំណាំហេតុការណ៍គ្រប់យ៉ាង ។

ទ្រឹស្តីពុទ្ធសាសនាបញ្ជាក់ថា **សុរាជាវត្ថុមានពិសពុល** រាប់ផ្ទាញអ្នកផឹកឲ្យមានទោស ៦ ប្រការ ឃើញជាក់ស្តែងនឹងភ្នែក ដូចអធិប្បាយមកនេះ ដែលស្របគ្នាទាំងស្រុងនឹងវិជ្ជាពេទ្យក្នុងពិភពលោកគ្រប់សម័យមិនមានខុសគ្នាបន្តិចបន្តួចសោះឡើយ ។

ហួសពីនេះទៅទៀត ព្រះសមណគោតមជាអគ្គអ្នកប្រាជ្ញ បានរក

ឃើញថា អ្នកប្រមឹកកាលស្លាប់ពីជាតិនេះទៅ ត្រូវទៅសោយទុក្ខទោសក្នុងឋាននរកទៀត លុះរួចទុក្ខទោសឋាននរកមកហើយ ត្រូវមកកើតជាសត្វតិរច្ឆាន ឬមនុស្សដែលមានសតិសម្បជញ្ញៈទន់ខ្សោយ ឬក៏ជាមនុស្សលេលាពុំនោះសោតជាមនុស្សឆ្កួត ពេទ្យមើលមិនជា ពោលគឺឆ្កួតដរាបដល់ស្លាប់ ។ ហេតុនេះ ការផឹកសុរា ឈ្មោះថាជាប្រធាននៃសេចក្តីវិនាស ។

ដូច្នេះ បុគ្គលអ្នកលេងសុរា - កញ្ឆា - អាភៀនជាដើម ដែលជាគ្រឿងស្រវឹងឬគ្រឿងញៀន ឈ្មោះថាជាអ្នកបំផ្លាញប្រយោជន៍ខ្លួន គ្រួសារញាតិ ជាតិ និងប្រយោជន៍ពិភពលោក ព្រោះអ្នកប្រមឹកឬអ្នកក់អាភៀនជាដើមនេះ មិនសូវដែលបានជួយបង្កើតបង្កើនផលិតផលសម្រាប់ទ្រទ្រង់ពិភពលោកទេ រឿចនតែជាអ្នកបរិភោគផលិតផលដែលគេបង្កើតស្រាប់ៗ ។ ហេតុនេះ យើងគួរតែចៀសវាងគ្រឿងស្រវឹងគ្រឿងញៀនទាំងអស់ ដើម្បីទុកពេលវេលា ទុកកម្លាំងកាយកម្លាំងស្មារតី កសាងប្រយោជន៍ជាតិសាសនានិងពិជពន្លក ឬកសាងកំណើតថ្មីរបស់យើង ឲ្យបានរុងរឿងក្នុងលោកនេះនិងបរលោក ។

# តាមឯកសារទំនៀមទម្លាប់ខ្មែរ

## ក្រមួនលាបមាត់

លោក មាស-បាំ វរមន្ត្រី

ទាយការិយាល័យ នៅសាលាក្រុងភ្នំពេញ

រៀបរៀង

ដែលហៅថា ក្រមួនលាបមាត់ ឬក្រមួនមាត់ គឺជាវត្ថុធាតុ១ មុខ ដែលស្ត្រីខ្មែរស្ទើរតែគ្រប់រូបតែងកប់អាន យកទៅលាបបបូរមាត់នៅពេលទទួលទានស្លាម្លូរ ។

ការនិយមលាបក្រមួនមាត់ មកពីវត្ថុធាតុនេះមានជាតិស្អិត ។ កាលណាគេលាបទៅ បបូរមាត់លើក្រោមជាប់គ្នា ទប់កាកស្លាម្លូរ ដែលកំពុងទទួលទានកំដង់ហក់ កុំឲ្យហៀរធ្លាក់ជ្រុះមកខាងក្រៅ នាំឲ្យប្រឡាក់សពត់អាវ កន្សែងដែលគ្របដណ្តប់ ។

គេសំគាល់ឃើញក្រមួនលាបមាត់មានចែកជា ៣ បែបគឺ :

១- ក្រមួនលាបមាត់រឹងបាក់ពុម្ពជាកង់ ។ ។

២- ក្រមួនមាត់ទន់ស្អិត ។

៣- ក្រមួនមាត់ទន់រអិល ។

ក្រមួនទាំងបីបែបខាងលើនេះ ខ្ញុំសូមលើកយកមកអធិប្បាយតែក្រមួនមាត់ ទន់ស្អិត និងទន់រអិល ដោយហេតុថា ក្រមួនមាត់ដំពូកនេះ ក្រុម

គ្រួសារខ្ញុំ នៅស្រុកកៀនស្វាយ "កណ្ដាល" ធ្លាប់គាត់តែងធ្វើផ្សារបរិច្ចេញមគ្រួសារបន្ទាប់ពីការដាំដំណាំតាមរដូវដូចជា : ពោតស, ក្រហម, សណ្ដែកបាយ, សណ្ដែកដី, ល្ងស-ខ្មៅ, ឃ្លោក, ត្រឡាច, ល្ពៅ, ប៉េង-ប៉ោះ, ត្រប់, ម្ទេសផ្លោក, ថ្នាំជក់ ។ល។ និងផលនៃផ្លែឈើដាំដំណាំស្រុក ដូចជា : ចេក, ម្នាស់, ស្វាយ, ខ្នុរ ។ល។

## ក្រមួនរឹងបាក់ពុម្ពជាកង់ ៗ បែបទី ១

ក្រមួនប្រភេទនេះ ញាតិសន្ដានខ្ញុំឥតធ្វើទេ និងអធិប្បាយដំណបអ្នកអាននៅពុំបាន ។

## ក្រមួនមាត់ទន់ស្អិត "បែបទី២"

ក្រមួនមាត់ប្រភេទនេះ ជាក្រមួនមាត់លេខ ១ ដែលបុរសស្ត្រីតែងតែពប់អាន ប្រើប្រាស់ច្រើនជាងក្រមួនមាត់ដែលមានសភាពទន់អិល និងក្រមួនរឹងហៅថា ក្រមួនកង់ ។

ហេតុដែលបណ្ដាលឲ្យគេពប់អានបែបនេះ មកពីការប្រើប្រាស់ទៅឃើញបានលទ្ធផលជាទីគាប់ចិត្តក្នុងការប្រើ គឺ :

ក- លាបសក់ក្បាល ឬ ពត់ពុកមាត់ឲ្យនៅឈរត្រង់បានស្អិតស្ទេរយូរថ្ងៃ មិនឲ្យរាំទន់គោងចុះមកក្រោម ។

សូមអធិប្បាយពីជំនាន់សក់ឈរដូចតទៅ :

កាលជំនាន់ជាង ៣០ ឆ្នាំមុននេះ មានបុរសស្ត្រីនៅស្រែបំការតែង

និយមកាត់សក់ខ្លីជ្រងដំរីរះផ្កាថ្កូវ ។ អ្នកខ្លះសក់ទន់បេះតែធ្លាក់មកក្រោម ដើម្បីទប់ទល់ចាប់សក់ឲ្យនៅឈរឡើងលើកុំឲ្យហ្វាក់ធ្លាក់ចុះបាននោះ គេត្រូវយកក្រមួនមាត់មកលាបសក់ឲ្យបានល្អ និងមានក្លិនផ្កាក្រអូបសាយភាយផង ។ ចំណែកអ្នកក្រុងបុរសគេច្រើនតែកាត់សក់វែង ខ្លះសិតទៅក្រោយ ខ្លះវែកចំហៀង ខ្លះវែកចំពាក់កណ្ដាលតាមការនិយមរាប់អាននៃបុគ្គលម្នាក់ៗ ។ ឯស្រីអ្នកក្រុងវិញ គេកាត់សក់វែងសិតទៅក្រោយមានគាស់ក្បាំងពីមុខ ឬ កាត់សក់វែងក្រឡឹងឲ្យមូលតាមរាងក ហៅថាសក់ដើងកញ្ចើ « Cheveux bombés » ។ គេមិនសូវត្រូវការយកក្រមួនមាត់ទៅលាបសក់ទេ ច្រើនប្រើប្រេងក្រមួនដែលនាំចូលមកពីប្រទេសក្រៅ ។

ប៉ុន្ដែខាងលោកប្រុសនាម៉ឺន-មន្ដ្រី ឬ លោកអ្នកមានធនធានស្ដុកស្ដម្ភ ឬក៏លោកអ្នកខ្លះចង់ឲ្យមានឋានៈ ប្រហាក់ប្រហែលនឹងនាម៉ឺនផងដែរនោះ ច្រើនទុកពុកមាត់ឲ្យវែង យកក្រមួនមាត់មកលាបពត់ស្នែងក្របី ឲ្យបានសមសួនជាមានឋានៈឧត្ដុង្គឧត្ដម ជាទីគោរពកោតខ្លាចដល់ប្រជាពលរដ្ឋទូទៅ ។ ទោះនឹងយាត្រាទៅទីកន្លែងណាដែលអត់មានអ្នកណាស្គាល់ ក៏គង់មានអ្នកស្រុកខ្លះបង្ហាញអាការ ទំនងជាគោរពកោតខ្លាចដល់លោកអ្នកមានពុកមាត់នោះជាពុំខាន ។

មួយទៀត អ្នកទុកពុកមាត់ជាស្នែងក្របី បើក្នុងភូមិស្រុកគេតែង

សំគាល់ថា ជាមេស្រុក ឬជាគ្រូអាចារ្យដែលអ្នកស្រុកភូមិតែងគប់អាន តែងពឹងពាក់ តែងធ្វើជាម្លប់គ្របដណ្តប់ឲ្យសេចក្តីសុខក្សេមក្សាន្តដល់ប្រ-ជាពលរដ្ឋនៅក្នុងស្រុកភូមិ ។

ហេតុដូច្នេះហើយបានជាសម័យនោះ ការទុកពុកមាត់នៃបុរសជាការតាក់តែងលំអនិងជាការលើកដម្កើងឋានៈនិងកិត្តិយស ។

១- ជាថ្នាំកែរោគ- ប្រើវាផ្សំនិងដំណាប់ពិស-លេកកែវ-បូសឡជញ្ជក់ មានមុខងាយខ្ទុះ ឈាម ឲ្យបានជាសះស្បើយក្នុងពេលខ្លី ។

គ- ជាវត្ថុធាតុសម្រាប់បញ្ចូលអាគមគាថា- សិល្បសាស្ត្រ- ធ្មប់ ធ្វើជាស្នេហ៍ សំកប់លាបពន្លដុំវិញសន្ទាក់ដៃ ដើម្បី លើបុគ្គលដែលមានខ្មោចព្រាយអារក្សអ្នកតា បិសាច ចូលញាំញីក្នុងរាងកាយឲ្យវង្វេងបាត់សតិ-បញ្ញា ស្មារតី និយាយរវើរវាយ និងសើចយំឥតមានអៀនខ្មាស ។

ឯវិធីប្រើក្រមួនបញ្ចូលជាមួយនឹងសិល្បអាគមគាថានោះ ខ្ញុំមិនដែលបានឃើញនៅវេលាដែលគ្រូហ្ម គេប្រើរ ។ ប៉ុន្តែដល់មានគ្រូពេទ្យគេដកដោះបន្សាបអំពើអាគមគាថា ពីបុគ្គលជម្ងឺនោះបានជាសះស្បើយទៅវិញបាន ឃើញភស្តុតាងខ្លះដែលគួរជាទីចាប់អារម្មណ៍ គឺជួនកាលឃើញមានរូបសូនលាបក្រមួនមាត់ចងខ្សែសំរែបបន្ទាចាក់រូបរុំនឹងស្លឹកចេក កប់ក្នុងដីក្រោមខ្ទមអ្នកតាម្ចាស់ស្រុកឬក្រោមដំណើរផ្ទះអ្នកជម្ងឺ ឬក៏គ្រូពេទ្យគេឲ្យថ្នាំផឹកទៅ មានក្អួតតាមមាត់ ឬធ្លាក់តាមបាតមក នូវវត្ថុ ផ្សេងៗមាន

សភាពខុសពីកំពូត ឬលាមកធម្មតា ។ គេសំគាល់ឃើញមានជម្ងឺខ្លះទៀតបណ្ដាលដល់ស្លាប់ ។ លុះគេយកខ្មោចទៅរំលាយនឹងភ្លើង សាច់ឈាមឆ្អឹងបានរលាយសុះអស់ នៅសល់តែសាច់មួយដុំរឹងស្វិតពុំអាចនឹងយល់ថាជាចំណែកសាច់ត្រង់កន្លែងណានៃសពនោះបានសោះ ។

តាមដែលគ្រូពេទ្យហ្មចេះដោះបន្សាប អំពើអំពាន់ឬស្នេហ៍ គេបានអធិប្បាយប្រាប់ថា វិធីប្រើធ្វើឲ្យឈឺគ្រាំគ្រា ឬដោះឲ្យជាសះស្បើយទៅវិញបានលុះត្រាតែគេយកក្រមួនមាត់មកប្រើជាវត្ថុធាតុដើម ទើបប្រព្រឹត្តទៅបានសម្រេចដូចបំណង ។

## វិធីស្លក្រមួនមាត់

គេសំគាល់ឃើញថា វិធីស្លក្រមួនមាត់មានតាក់តែងធ្វើឡើងជា២ បែបគឺ:

ក)- ស្លនឹងខាប់ដុតអង្កាម

ខ)- ស្លនឹងខ្ទះដែក ឬស្ពាន់ដុតមស

ជាដំបូងខ្ញុំសូមយករបៀបស្លក្រមួនមាត់នឹងខាប់ដុតអង្កាមមកថ្លែងរួច សឹមយកវិធីស្លនឹងខ្ទះមកពណ៌នាជាបន្តបន្ទាប់ទៅទៀត ។

(នៅមានត)

# វិវត្តន៍នៃអក្សរខ្មែរ

(ក) (១)

លោក ឌ. តាម រៀបរៀង

១– ស្រៈព្រាហ្មី : (២)




២– ព្យញ្ជនៈ:




៣– ការផ្សំស្រៈនិស្ស័យនឹងព្យញ្ជនៈ:




---

(១) នៅកម្ពុជសុរិយា ភាគ ២ ខ្ញុំដាក់ថា ចលនានៃអក្សរខ្មែរ តែចំណងជើងនេះឃ្លៀតឃ្លាតបន្តិច ខ្ញុំសូមកែ វិវត្តន៍នៃអក្សរខ្មែរវិញ ។

(២) ចម្លងចេញពីសៀវភៅ ( Inscription of Asoka )

សិលាចារឹកដែលមានបែបជាអក្សរព្រាហ្មី ខ្ញុំយកមកជូនចំពោះលោកអ្នកស្រាវជ្រាវខាងអក្សរសាស្ត្រខ្មែរ គឺសិលាចារឹកព្រះបាទអសោកនៅលុម្ពិនី ។ តាមយោបល់អ្នកកាន់ព្រះពុទ្ធសាសនាដឹងតាមប្រវត្តិសាស្ត្រថា សសរថ្ម (ស្តម្ភ) ដ៏ប្រសើររបស់ព្រះបាទអសោក ដែលមានសិលាចារឹកផងនេះ ជារបស់ជាក់ស្តែងណាស់ ។ សិលាចារឹកនេះត្រូវក្រសួងបុរាណវត្ថុរក្សាទុកដោយល្អ នៅក្នុងចំណោមសិលាចារឹករបស់ព្រះបាទអសោកៗ តួសិលាចារឹកនេះមាន ៤ បន្ទាត់ ដូចខ្ញុំថតជូនខាងក្រោមនេះ (១)



សិលាចារឹកនេះសរសេរតាមអក្សរខ្មែរសម័យបច្ចុប្បន្នថា :

បន្ទាត់ទី ១ : ទេវាន បិយេន បិយទសិន លាជិន វីសតិវសភិសិតេន

(១) ដកស្រង់ចេញពីសៀវភៅ Bhagawan Buddha, dy R-R. Diwakar

បន្ទាប់ទី ២ : អតន ឤគាច មហីយតេ ហិទ ពុធេ ជាតេ សក្យមុនីតិ

បន្ទាត់ទី ៣ : សិលាវិគឌភីចា កាលាបិត សិលាថម្ភេ ច ឧសបាបិតេ

បន្ទាត់ទី ៤ : ហិទ ភគវំ ជាតេតិ លុំមិនិគាមេ ឧពលិកេ កដេ

បន្ទាត់ទី ៥ : អឋភាគិយេច

ប្រែជាសេចក្ដីខ្មែរថា

១ – ព្រះមហាក្សត្រជាទីស្រឡាញ់នៃពួកទេវតា ព្រះអង្គទ្រង់ពជាភិសេកមក ២០ ឆ្នាំហើយ

២-៣ ស្ដេចយាងមកកាន់កន្លែងនេះ ដោយព្រះអង្គឯង ទ្រង់សមាពានសីលធ៌បរិសុទ្ធនៅទីនេះ ព្រោះកន្លែងនេះហើយដែលព្រះសក្យមុនី ព្រះអង្គទ្រង់ប្រសូត ហើយទ្រង់ឲ្យធ្វើរបងថ្មុំងសិលាជារបងព័ទ្ធជុំវិញ និងសសរថ្មមួយផង ។

៤ – ព្រោះហេតុនោះហើយ បានជាព្រះអង្គទ្រង់មកប្រសូតនៅកន្លែងនេះ ប្រជាពស្ត្រនៅក្នុងលុម្ពិនីគាំងមូលនេះ ត្រូវរួចពន្ធដារ

៥ – តែត្រូវបង់ ១ ភាគក្នុង ៨ ភាគ ។

## លក្ខណៈនៃអក្សរខ្មែរ

យើងត្រូវយល់ថា អក្សរខ្មែរយើងមានដើមកំណើតមកពីអក្សរព្រាហ្មីនៅប្រទេសឥណ្ឌាសម័យបល្លវៈ និងចាលុក្យៈ ។

សូមសង្កេតសិលាចារឹក ដែលគេចាត់ចូលជាសម័យបល្លវៈ(១) ក្នុងសតវត្សទី ៧ នៃគ្រិស្តសករាជ (It must also belong to the Pallava period Gandhara character)



សរសេរជាខ្មែរថា :

១ – ឯតទនិឞ្ដកម្យមមលោ

1 — Mandagappattu inscription of Vichitrachitta, copy from Epigraphica Indica Vol. XVII.

ខ្ញុំបានឃើញសិលាចារឹកនេះ នៅបណ្ណាល័យនៃវិទ្យាស្ថានបុរាណវត្ថុនៅនីវដេហ្លី (ឥណ្ឌា) ។

២ – ហមសុធំវិចិត្រ ចិត្តេន

៣ – និម្មាិ បិតន្ធបេ (ណា) ព្រះហ្មា
ប៊ី

៤ – ឝៈវិស្ណុរិក្សិតាយតនម

ប្រែជាសេចក្តីខ្មែរថា

ប្រាសាទនេះ ដែលព្រះរាជាព្រះនាមចិត្រវិចិត្តកសាងឡើង ដោយមិនប្រើឥដ្ឋ, ឈើ, លោហធាតុ ហើយនិងបាយអ ជាប្រាសាទឧទ្ទិស ចំពោះព្រះព្រហ្ម, ព្រះឥសូរ និង ព្រះវិស្ណុ ។

ព្រះបាទកៅណ្ឌិន្យ ជាបឋមក្សត្រនៃប្រទេសកម្ពុជា ។ មហាក្សត្រអង្គនេះហើយ ដែលបាននាំអារ្យធម៌ឥណ្ឌាចូលមកប្រទេសកម្ពុជាមុនគេ តាំងពីសតវត្សទី ១ នៃគ្រិស្តសករាជ ។ អក្សរខ្មែរយើងសម័យនោះ បែបទ្រង់ទ្រាយស្រដៀងគ្នានឹងអក្សរឥណ្ឌាខាងទក្សិណ ។

តាមការស្រាវជ្រាវរបស់អ្នកអក្សរសាស្ត្រខ្មែរយើងថា អក្សរខ្មែរមានលំនាំដូចឥណ្ឌានោះ ខ្ញុំសូមជូនទូវការប្រៀបធៀបរវាងអក្សរខ្មែរ និងឥណ្ឌាសម័យព្រាហ្មីខ្លះ ។ ការប្រៀបធៀបនេះ ខ្ញុំដកស្រង់យកពីវចនានុក្រមសំស្ក្រឹតអង់គ្លេសរបស់លោក មូនីយេ មូនីយេវិល្យាម្ស (Sir Monier Monier Williams) ។ លោកនេះបានប្រៀបអក្សរក្រិក និង ទេវនាគរី ព្រមទាំងបែបអក្សរព្រាហ្មីទៀត ។ បែបអក្សរសម័យព្រាហ្មីដែលខ្ញុំយក

មកជូននេះ សូមលោកយកទៅប្រៀបធៀប នឹងសិលាចារឹកខ្មែរសម័យ បុរាណ ។

## បែបព្យញ្ជនៈធៀបគ្នារវាងអក្សរក្រិកព្រាហ្មីនាគរី នឹង ខ្មែរ



មុននឹង យកបែបអក្សរព្រាហ្មីទៅប្រៀបធៀប សូមលោកយល់ឲ្យច្បាស់នូវពាក្យថា «ព្រាហ្មី» ។ អក្សរព្រាហ្មី គឺជាអក្សរបុរាណទី ២ របស់ឥណ្ឌា ។ អក្សរនេះ បានជាគេឲ្យឈ្មោះបែបនេះ ពីព្រោះពួកព្រាហ្មណ៍ជាអ្នកឲ្យឈ្មោះ ហើយពួកព្រាហ្មណ៍ជាអ្នកជឿថាអក្សរនេះជាអក្សរដែលព្រះព្រហ្មបង្កើត (១) . . . (The second kind of ancient I dian script is called Brahma or Brahmi . . . given to it by the Brahmans because as they assert it was invented by their God Brahma . . ) ប្រែថា អក្សរបុរាណរបស់ឥណ្ឌាទី ២ ហៅថា ព្រាហ្មឬព្រាហ្មី ដែលពួកព្រាហ្មណ៍ឲ្យឈ្មោះ ពីព្រោះព្រាហ្មណ៍នៅជឿថាព្រះព្រហ្មជាអ្នកបង្កើតអក្សរបែបនេះ ។

ជំនឿនេះ មិនខុសពីជនជាតិខ្មែរយើងខ្លះទេ ដែលជឿថា អក្សរខ្មែរ គឺជាតួព្រះ ៗ អក្សរ ១ តួជានិមិត្តរូបនៃព្រះពុទ្ធមួយតួដែរ ។

## ការប្រែប្រួលតួអក្សរខ្មែរ

### ១- ព្យញ្ជនៈ

តាំងពីជាតិខ្មែរយើងមានអក្សរមករហូតមកដល់សម័យសព្វថ្ងៃនេះ

---

១ វចនានុក្រមសំស្ក្រឹត អង់គ្លេស

តាមអ្នកស្រាវជ្រាវអក្សរខ្មែរយើងថា អក្សរខ្មែរកែប្រែសណ្ឋានអក្សរ ១០ ដងហើយ(១) ។ បែបអក្សរដែលបរទេសស្រាវជ្រាវ ឃើញនៅខ្វះបែបអក្សរម្យ៉ាង(២) ដែលទើបតែចេញពីតួព្រាហ្មក ។



តំរូអក្សរនេះ គេប្រទះឃើញនៅសិលាចារឹកនៅភ្នំកាន់ជ័យ (កំពង់ចាម) សតវត្សទី ៦ ហើយមានសណ្ឋានដូចអក្សរឥណ្ឌាសម័យបល្លវៈ ។



(នៅមានត)

---

១) Langue khmère par Maspéro

២) បែបអក្សរដែលទើបតែបែកចេញពីអក្សរព្រាហ្មី សូមអាន អក្សរសាស្ត្រខ្មែរ ដោយលោក លី ធាមតេង ទំព័រ ១១ គ.ស. ១៩៦០ ។

# រឿងសាមកុក

ចៅពញាវិបុលរាជសេនា នូ កាន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាស់បើបានអាន
និងចេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ

យូរ-អ៊ុន

## សាមកុកខ្សែ ៥៧

តាំងពីចោហងលើកទ័ពទៅដល់ស្រុកហាន់តុង ហើយចោហងលើកវិលទៅប៉ងនឹងច្បាំងនឹងទៀវហ៊ុយ, ម៉ាឈៀវនៅស្រុកប៉ាសេ រហូតដល់ឡៅតី ខុងបេងលើកទ័ពទៅវាយស្រុកហាន់តុង ។

---

ឯចោហងកាលទៅដល់ស្រុកហាន់តុងហើយ ក៏ចាត់ចែងឲ្យហែហ៊ូអៀននិងទៀវកាប់ ទៅរក្សាស្រុកគ្រប់តាមផ្លូវនៅដំបន់នោះ ហើយចោហងក៏លើកកងទ័ពទ្ទឹងទៅច្បាំងនឹងទៀវហ៊ុយ ម៉ាឈៀវ ឯស្រុកប៉ាសេ លុះទៅដល់កណ្ដាលផ្លូវទទួលដំណឹងថា ទៀវហ៊ុយ ឲ្យម៉ាឈៀវលើកវិលទៅដល់ដំបន់ហែពៀន ។

ខណៈនោះ ម៉ាឈៀវក៏ចាត់ឲ្យង៉ីឡាន់និងង៉ិមអេងលើកទាហានទៅល្បាតលាតត្រាវល់ទទួល ប្រទះនឹងចោហង ង៉ីឡាន់ក៏ប្រឹក្សានឹងង៉ិមអេងថា បើប្រសិនជាយើងនឹងចូលទៅច្បាំងនឹងកងទ័ពនេះ ទាហានយើងក៏តិច

ពេក ត្រូវតែវិលត្រឡប់ទៅប្រាប់ ម៉ាឈៀវសិនទើបគួរ ងិមអេងថាដែលនឹងទៅវិញទទេនោះ មុខជាម៉ាឈៀវនឹងចាប់ទោសយើងវិញមិនខាន ឯកងទ័ពចោហាងទើបតែនឹងមកដល់ គួរនឹងចូលទៅច្បាំងឲ្យដឹងដៃគ្នាសិនទើបគួរ ពោះបើយ៉ាងណាទាហានចោហាងគង់នឹងថយដៃត្រឡប់ទៅវិញមិនខាន ទើបងិមអេងបរសេះពាំលំពែងចូលទៅស្រែកឡកចំអកឲ្យចោហាងដល់មុខបន្ទាយ ៗ

ចោហាងឮដូច្នោះក៏ខឹងណាស់ បរសេះចេញពីក្នុងបន្ទាយមកតស៊ូគ្នានឹងងិមអេងបាន ៣ ភ្លេង ចោហាងយកលំពែងចាក់ត្រូវងិមអេងធ្លាក់ពីលើសេះស្លាប់ ហើយកាប់សម្លាប់ទាហានស្លាប់ជាច្រើន ង៉ីឡាន់ឃើញកម្លាំងនឹងតទល់ពុំបាន ក៏នាំទាហានដែលសល់នោះរត់ទៅដល់ដំបន់ហៃ-ពៀន ហើយចូលទៅប្តឹងម៉ាឈៀវគ្រប់ប្រការ ៗ

ម៉ាឈៀវបានដឹងដូច្នោះក៏ខឹងណាស់ថា ខ្លួនគ្រាន់តែជាអ្នកយាមល្បាតទេ បើបានឃើញប្រទះនឹងសត្រូវ គួរតែវិលមកប្រាប់យើងសិន ហេតុអ្វីខ្លួនប្រញាប់តែច្បាំងឲ្យខូសការដូច្នេះ ទោសខ្លួនជាទម្ងន់ខ្លាំងណាស់ ង៉ីឡាន់ឆ្លើយថា កាលទៅប្រទះនឹងសត្រូវនោះ ខ្ញុំបាទបាននិយាយប្រាប់ថា ឲ្យវិលមកជំរាបលោកឲ្យជ្រាបសិន ងិមអេងមិនព្រមស្តាប់ត្រឡប់ចចេស ចូលទៅតតាំងច្បាំងទាល់តែស្លាប់ខ្លួន បានជាខ្ញុំបាទបែករត់មកដល់លោកនេះ ម៉ាឈៀវក៏ឲ្យកាត់ទោសព្យួរង៉ីឡាន់ឲ្យ

កងបាល ទើបឲ្យត្រួតត្រាបណ្ដាពលទាហានឲ្យមានព្រមព្រៀងហើយ ក៏ឲ្យតែងសំបុត្រមកប្ដឹងរឿងរ៉ាវទាំងពួងចូលទៅដល់ស្រុកសៃគួន១ច្បាប់ ឲ្យទៀវហ៊ុយ ១ ច្បាប់ ។

ឯទាហាននោះ លុះមិនឃើញម៉ាឈៀវចេញមកច្បាំងជាយូរថ្ងៃ ក៏គិតបារម្ភក្រែង ម៉ាឈៀវ នឹងធ្វើកលឧបាយផ្សេង ៗ ទើបលើកកងទ័ពត្រឡប់ថយទៅតាំងបន្ទាយនៅស្រុក ហាទ់តុងវិញ ទៀវខាប់ដឹងដូច្នោះ ក៏ចូលទៅសួរពិគ្រោះទាហានថា ខ្លួនលោកបានលើកទ័ពចេញទៅកាប់សម្លាប់ទាហាន ម៉ាឈៀវស្លាប់ជាច្រើនហើយ ហេតុម្ដេចក៏គេចត្រឡប់លើកទ័ពចូលមកវិញ ។

ទាហានតបថា ខ្លួនយើងបានធ្វើការបានប្រៀបដល់សត្រូវ ក៏មែនហើយ តែមិនបានឃើញម៉ាឈៀវចេញមកតស៊ូគ្នាជាយូរថ្ងៃណាស់ យើងមានបារម្ភក្រែងម៉ាឈៀវ នឹងធ្វើកលឧបាយផ្សេង ៗ ប្រការមួយ កាលយើងនៅក្នុងស្រុកផៀបកុននោះ គួនឡូទំនាយថា ព្រះចៅវុយអង នឹងខូចខាតបង់ប្អូន ឬទាហានឯកម្នាក់នៅក្នុងឆ្នាំសាន់ យើងនឹកបារម្ភក្រែងដូចទំនាយគួនឡូ បានជាថយទ័ពមកសិន ។

ទៀវខាប់បានស្ដាប់ហើយអស់សំណើចថា ខ្លួនលោកជាវង្សព្រះ-ចៅវុយអង ហើយលោកក៏ជាទាហានឯក ហេតុម្ដេចទៅជឿស្ដាប់ពាក្យទំនាយគ្រូមើលដូច្នោះ មិនគួរសោះខ្ញុំបាទនឹងសុំនាំទាហានរបស់ខ្ញុំបាទ

លើកទៅវាយយកស្រុកប៉ាសេឲ្យបាន បើបានស្រុកប៉ាសេវេលាណា ស្រុកសែឈួន ក៏ដូចនៅក្នុងកណ្ដាប់ដៃយើងវេលានោះ ។

ចោហងតបថា អ្នកក៏បានដឹងមកហើយថា ទៀវហ៊ុយនោះមានថ្វីដៃខ្លាំងពូកែក្លាហាន បានមកនៅស្រុកប៉ាសេនោះ ហេតុម្ដេចអ្នកមើលងាយទៀវហ៊ុយដូច្នេះ ទៀវខាប់ថា ឯមនុស្សឯទៀត ៗ គេរមែងកោតខ្លាចថ្វីដៃទៀវហ៊ុយទាំងអស់ តែខ្លួនខ្ញុំបាទនេះមើលទៅឃើញទៀវហ៊ុយមានគំនិតប្រាជ្ញាដូចកូនក្មេង ៧ ខួប ខ្ញុំបាទនឹងសុំអាសាចេញទៅចាប់ខ្លួនទៀវហ៊ុយឲ្យទាន់តែបាន ចោហងថាបើអ្នកឯងធ្វើការនោះត្រឡប់ជាមិនបានវិញ តើនឹងឲ្យធ្វើប្រការម្ដេច ? ។

ទៀវខាប់តបថា ខ្ញុំបាទសុំសរសេរសំបុត្រសញ្ញាទុកជូនលោក បើមិនបានសមប្រកបដូចពាក្យថាទេ សុំឲ្យលោកកាត់ក្បាលខ្ញុំបាទចេញចុះ ថាហើយក៏សរសេរសំបុត្រសញ្ញាទុកឲ្យចោហង ហើយចាត់បែងទាហានបាន ៣ ម៉ឺន លើកទៅជិតដំបន់ហៃតៀន រៀបតាំងបន្ទាយមួយឈ្មោះ ផេកងៀម បន្ទាយមួយឈ្មោះ បង់បៅ បន្ទាយមួយឈ្មោះ បង់សេក បែងទាហានឲ្យនៅរក្សាបន្ទាយទីមួយ ៗ ទាហាន ១ ម៉ឺន ម៉ាណៀវក៏មិនបានចេញច្បាំងលុះនៅមកមួយថ្ងៃ ទៀវខាប់ក៏បែងទាហានបន្ទាយមួយទាហាន ៤.០០០ លើកកាត់ផ្លូវតម្រង់ទីទៅវាយប៉ាសេ ។

ទៀវហ៊ុយដឹងដូច្នោះ ក៏ប្រឹក្សានឹងលុយតង់ថា យើងនឹងគិតប្រការម្ដេច លុយតង់ថា ផ្លូវទាំងអស់នេះឆ្ងាយដាច់ស្រយាលណាស់ សព្វតែ

ច្រកជ្រោះជ្រលងដងស្ទឹង ក្នុងព្រៃភ្នំ ខ្ញុំបានសុំទាហានទៅពួនបង្កប់ បើគងក្រវៃលទៀវវាប់មិនបានដើរមកដល់ ព្រោះផ្លូវនោះ បំពោះច្រកភ្នំត្រូវឲ្យលោកលើកកងទ័ពធំចេញទៅតស៊ូ និងទៀវវាប់ឲ្យជាប់ដៃ ខ្ញុំបានទទឹងនាំទាហានចេញមកវាយប្រសព្វពីក្រោយគងទឹងចាប់ខ្លួនទៀវវាប់បាន ។

ទៀវហ៊ុយយល់ឃើញត្រូវ ក៏ចាត់ចែងទាហាន ៥.០០០ ឲ្យលុយតងលើកទៅពួនបង្កប់នៅក្រៅស្រុក ហើយទៀវហ៊ុយក៏នាំទាហាន ១០.០០០ ចេញទៅតាំងបន្ទាយនៅបៀតជាប់គ្នា ទៀវហ៊ុយក៏បរសេះនាំទាហានទៅស្រែក ឡុកបំអកឲ្យទៀវវាប់ ៗ បានឮក៏ខឹងណាស់ បរសេះចេញមកតយុទ្ធនិងទៀវហ៊ុយបាន ៣០ ក្វេង ។

លុយតងឃើញដូច្នោះ ក៏លើកទាហានវាយស្កាត់ចុងផ្លូវចូលទៅសម្លាប់ទាហានទៀវវាប់ ស្លាប់ជាច្រើន ទៀវវាប់ឃើញកំឡាំងនឹងធន់ពុំបាន ក៏ញាក់សេះនាំទាហានវេះរត់ទៀវហ៊ុយ ក៏តាមពីក្រោយបណ្ដាយទៅ លុយតងក៏បញ្ចេញទាហានមកវាយស្កាត់ពីមុខទាប់ ទៀវវាប់និងទាហានបំពានទៅមិនរួច ក៏ស្ទុះបះទំលាយទៅខាង បែកខ្ញែកគ្នារត់ចេញទៅ ទៀវហ៊ុយ និង លុយតងលើកទ័ពប្រសព្វគ្នាដេញតាមទៅទៀវវាប់ក៏រត់ចូលបន្ទាយបាន ទៀវហ៊ុយ និង លុយតងក៏លើកទាហានបំពានវាយបន្ទាយផេកផៀម ហើយឲ្យទាហានបាញ់ធ្នូចម្រុះបោះបោលដុំថ្មទៅជាច្រើនណាស់ ទៀវវាប់ក៏ឲ្យទាហានត្រួតត្រាក្សាបន្ទាយមិនបានជាអន្តរាយ ៗ

(នៅមានត)

# រឿងចៅរលាដូង

## ( រឿងព្រេងខ្មែរ )

(៣)

លោក ឌ. ពាម ស្រាវជ្រាវនិងរៀបរៀង

ថ្ងៃពុធជាថ្ងៃពេលារៀបមង្គលការចៅរលាដូង ប្រជារាស្ត្រនៅក្នុងនគរក៏មកប្រសិទ្ធិពរថ្វាយនាងពៅគ្រប់ៗគ្នា ហើយបរិភោគផឹករាំលេងសប្បាយចំនួន ៣ យប់ ៣ ថ្ងៃ នៅថ្ងៃទីបំផុត ស្ដេចទ្រង់ត្រាស់ហៅព្រះរាជបុត្រីពៅមកហើយមានបន្ទូលថា "នៅពេលកំឡុង ៣ ថ្ងៃ ៣ យប់នេះ កូនបានធ្វើអ្វីខ្លះជាមួយចៅរលាដូង ចូរកូនទៅក្រាបទូលព្រះមាតាកូនផង តែកូនកុំទៅនិយាយជាមួយមាតាខ្លាំងៗពេក ត្រូវឲ្យមានវាចាទន់ភ្លន់" ។ នាងពៅទៅទូលព្រះមាតាថា « មាតា! ចៅរលាដូងបាននិយាយលេង បានប្រព្រឹត្តការលោកិយដូចតែជនឯទៀតដែរ ។ ព្រះមាតាក៏តបទៅវិញថា «ចុះចៅរលាដូងធ្វើអ្វីកើតដូចមនុស្សដទៃ បើគ្មានដៃជើងផង?» ។ នាងពៅទូលព្រះមាតាថា «ព្រះមាតា! ចៅរលាដូង មិនមែនជាមនុស្សដូចគេឯងទេ ។ ព្រះមាតាអើយ! ពេលយប់ចៅរលាដូងចេញពីស្រោមមកសសុះជាងខ្ញុំទៅទៀត ហើយល្អដូចទេវបុត្រ ។

ព្រះរាជធីតានាំដំណឹងនោះទៅទូលព្រះរាជា ។ នៅពេលនោះព្រះរាជបុត្រីច្បងនិងកណ្ដាលលបស្ដាប់ដឹងថា ចៅរលាដូងចេញពីស្រោមល្អដូច

ទេវបុត្រ ក៏មានសេចក្តីប្រណែន ហើយនាំគ្នាទៅលួចឃ្លាំមើលចៅលោដូង និង នាងពៅ ។ ព្រះរាជបុត្រីលួចលបមើល ក៏ឃើញចៅលោដូងចេញពីស្រោមមែន មានរូបរាងជាទេវបុត្រសុទ្ធសាធ ដូចព្រះច័ន្ទពេញបូណ៌មី ហើយក៏ចាប់ចិត្តស្នេហា តែមិនដឹងជាធ្វើដូចម្តេច ។ រាជបុត្រីច្បងទាំងពីរព្រះអង្គ ចេះតែរកមធ្យោបាយរៀងខ្លួន ដើម្បីនឹងឲ្យបានរៀបការជាមួយចៅលោដូង ។

ភ្ញៀវបរិភោគការចៅលោដូងអស់កាលមួយរយថ្ងៃ មួយរយយប់ក៏ក្រាបបង្គំទូលលាព្រះរាជាទៅលំនៅរៀងៗខ្លួន ។ ពេលដែលភ្ញៀវត្រឡប់ទៅផ្ទះអស់វិញ ព្រះនាងពៅក៏ប្រាប់ចៅលោដូងថា «ភ្ញៀវទៅអស់ហើយដំណាក់យើងស្ងាត់ណាស់ សូមបងកុំទៅក្នុងស្រោមយូរពេក សូមបងចេញមកហើយទៅឃ្វាលក្របីឲ្យមហាជនគេឃើញផង ។ ចៅលោដូងមិនព្រមចេញពីក្នុងស្រោមទៅវេលាថ្ងៃសោះ ចាំតែវេលាយប់ទើបចេញពីស្រោម ។ នៅពាក់កណ្តាលអធ្រាត្រ ចៅលោដូងចេញពីស្រោមហើយទៅអាស្រ័យដំណេកជាមួយព្រះនាងពៅ ដល់ព្រឹកឡើងក៏ចូលទៅក្នុងស្រោមវិញជារៀងរាល់ពេល ។ ថ្ងៃមួយចៅលោដូងចេញពីស្រោមទៅគេងជាមួយនាងពៅលក់ទៅ ស្រាប់តែនាងពៅលួចយកស្រោមទៅលាក់បាត់ទៅ ។ ពេលដែលចៅលោដូងក្រោកឡើងរកស្រោមមិនឃើញ ក៏យកកន្ទេលមករុំខ្លួនហើយសួរទៅនាងពៅថា «អូន! ឃើញស្រោម

រលាដូងបងឬទេ? យកមកឲ្យបងវិញ៖" តែនាងពៅឆ្លើយថា "ខ្ញុំមិនឃើញទេបង" ។ ចៅរលាដូងនៅក្នុងកន្ទេលញ័រចំប្រប់ដេកថ្ងូរដូចកូនព្រាប ព្រោះមិនធ្លាប់ត្រូវត្រជាក់ ឬកំដៅហើយក៏លែងតបទៅជាមួយភរិយា ។ នាងពៅឃើញដូច្នោះ ក៏ទៅយកសំពត់មានដំឡៃដូចជាសាក្លាតជាដើម មកឲ្យចៅរលាដូងស្លៀក ប្រហែលជា ៤-៥ ថ្ងៃ ចៅរលាដូងក៏មានទម្លាប់ស្លៀកពាក់ខោអាវដូចគេឯង ។ ក្រោយមកនាងពៅប្រាប់នូវសេចក្តីពិតទៅចៅរលាដូងថា "ខ្ញុំយកស្រោមរលាដូងកប់ចោលក្នុងដីមែន" ទើបចៅរលាដូងសើចញឹម ៗ ។ នាងពៅថា កាលដែលបងនៅក្នុងស្រោមរលាដូង បងស្រីខ្ញុំទាំងពីរនាក់ចេះបង្អាប់ខ្ញុំថា ទៅយកប្តីមនុស្សគ្មានដៃគ្មានជើង ដូច្នេះហើយបានជាខ្ញុំយកទៅកប់ក្នុងដីទៅ ។ សំឡេងសើចរវាងគូស្នេហាទាំងពីរ ក៏ផ្ទុះឡើងក្រោមចង្កៀងព្រឹម ៗ នៅក្នុងព្រះរាជដំណាក់ដ៏សែនមនោរម្យ ។

ថ្ងៃក្រោយមក បងស្រីនាងពៅទាំងពីរព្រះអង្គ ក៏លបទៅមើលបន្ទប់នាងពៅនិងចៅរលាដូង ឃើញគេប្រកៀកប្រគងសប្បាយអស្ចារ្យ ទើបនាងមានដំរេកចាប់ក្តួចសេចក្តីស្នេហាចំពោះចៅរលាដូង តែនាងមិនដឹងជារកមធ្យោបាយយ៉ាងណានឹងយកចៅរលាដូងបាន ទីបំផុតនាងទាំងពីរព្រះអង្គ ក៏សុខចិត្តថា ឲ្យគ្រាន់តែបានដេកលេងជាមួយចៅរលាដូងក៏សុខចិត្តដែរ ។

ពេលណាក៏ដោយ  តែចៅលលាដ៍ដូងចេញទៅក្រៅប្ដុះទៅឃ្វាលក្របី មនុស្សម្នាមហាជនចេះតែសរសើរមិនដាច់ពីមាត់ថា ចៅលលាដ៍ដូងជាមនុស្សមានសំណាងបាននាងពៅមកធ្វើជាភរិយា អ្នកខ្លះថា នាងពៅមានសំណាងបានចៅលលាដ៍ដូងមានរូបដូចទេវបុត្រមកធ្វើជាស្វាមី ។ អ្នកស្រុកដឹងថាចៅលលាដ៍ដូងជាមនុស្សអស្ចារ្យចេញពីស្រោម  ក៏នាំគ្រឿងសក្ការ មកប្រសិទ្ធិពរជូនគូស្វាមីភរិយានេះ  យ៉ាងអ៊ឹកធឹកពេញព្រះរាជវាំង ។ អ្នកខ្លះប្រប្រៀតប្រៀតត្រលប់ទៅមុខ  ចង់តែឃើញចៅលលាដ៍ដូងច្បាស់ ម្នាក់ៗចេះតែប្រជែងគ្នា ទោះតែអាមាត្យការពារមិនឈ្នះ ។  អ្នកស្រុកប្រុសស្រីឃើញចៅលលាដ៍ដូងល្អស្អាតដូច្នោះ ក៏ស្រែកឲ្យពរសព្ទសាធុការ  ហើយអ្នកខ្លះថា  ល្អរកអ្វីប្រៀបពុំបាន !

ចៅលលាដ៍ដូងនាំនាងពៅជាភរិយាទៅជំរាបសួរសុខទុក្ខម្ដាយបង្កើត ។ ពេលដែលចៅលលាដ៍ដូងទៅដល់ផ្ទះ ម្ដាយញាតិសន្ដាន  មើលចៅលលាដ៍ដូងមិនស្គាល់សោះ  តែលុះដល់ចៅលលាដ៍ដូងបង្គាប់ភរិយាឲ្យយកបណ្ណាការទំនែកចេកអំពៅជាដើមដាក់ទៀបបាទាម្ដាយហើយ  ទើបម្ដាយស្គាល់ថាជាកូនឯងចៅលលាដ៍ដូង  ដែលព្រះឥន្ទ្រប្រទាននៅពេលដែលទៅដងទឹកនៅស្ទឹង ។ ពេលនោះ ញាតិសន្ដានគ្រៀងលានក៏អញ្ជើញមកចងដៃឲ្យពរសព្ទសាធុការឲ្យចៅលលាដ៍ដូងនិងនាងពៅ ។ ពេលដែលបងប្អូនញាតិមិត្រឃើញចៅលលាដ៍ដូងល្អដូចទេវបុត្រ ក៏មានពាក្យដដែកឡើងថា កាល

ដែលចៅលលាដូងនៅជាមួយម្ដាយ វានៅតែក្នុងលលាដូងមូលដូចបាល់ ដល់បានទៅឃ្វាលក្របីល្អួង ស្រាប់តែមានសិល្បមន្ដអាគមហើយចេញពីស្រោមល្អដូចទេវបុត្រ ទាល់តែញាតិមិត្រមើលមិនស្គាល់ ។

ចៅលលាដូង នាំភរិយាវិលមកព្រះរាជដំណាក់វិញ នៅជាមួយប្រពន្ធបានប្រហែលជាមួយអឌ្ឍមាស ក៏ចេញទៅរកជំនួញជួញប្រែ ។ ពេលនោះ បងស្រីនាងពៅពីរព្រះអង្គក៏ទៅជាមួយដែរ ។

ពេលរៀបចេញដំណើរទៅតាមទូក នាងពៅយកព្រះទម្រង់ (ចិញ្ចៀន) របស់ចៅលលាដូងមកពាក់ ទើបនាងអញ្ជើញព្រះរៀមទាំងពីរព្រះអង្គឡើងកាន់ផលយាន ។ ព្រះរាជបុត្រីទាំង ៣ ព្រះអង្គគង់នៅលើកន្ទេលអួយ ចៅលលាដូងនៅឆ្ងាយតែម្នាក់ឯងក្នុងសំពៅ ។ ចំណែកនាយកេត្រាក៏ចេញសំពៅទៅតាមបង្គាប់ចៅលលាដូង ។

ផលយានត្រូវក្ដោងនៅតាមឆ្នេរសមុទ្រ កាត់តម្រង់ទៅប្រទេសដែលត្រូវទៅធ្វើជំនួញ ។ ព្រះរៀមច្បងទាំងពីរព្រះអង្គរបស់នាងពៅ ក៏យាងឲ្យនាងពៅមកឈរនៅក្បែរគែមសំពៅ ហើយទើបសុំព្រះទម្រង់ពីព្រះហស្ដនាងពៅមើល ។ ពេលនេះហើយដែលព្រះរៀមរបស់នាងពៅចង់ពង្រាត់បង្រាស់នាងពៅចេញពីចៅលលាដូង ហើយយកចៅលលាដូងធ្វើជាស្វាមីទាំងពីរព្រះអង្គ ។ នាងពៅដោះព្រះទម្រង់ចេញពីព្រះហស្ដហើយព្រះរៀមទាំងពីរព្រះអង្គ ក៏ធ្វើជាដណ្ដើមគ្នាមើល ហើយធ្វើជាឲ្យធ្លាក់ទៅក្នុងសមុទ្រ ។

# ព្រះរាជនិពន្ធរាមកេរ្តិ៍

(ត)

លោក ឧ. តាម ស្រាវជ្រាវ និង រៀបរៀង

បន្តិចនោះក៏គ្មាន ទើបបាននាំគ្នា ទាំងអស់ក្រាបថ្វាយបង្គំទូលទៅព្រះចម-មកុដលើត្រៃលោក សូមទ្រង់ជ្រាប ។ កាលនោះ ព្រះមុនីនាថនាថា បានឃើញទេវលោកទាំងពួងមកទូលថា លើកតម្រង់មិនរួចដូច្នោះហើយ ព្រះអង្គទ្រង់ព្រះចិន្តាគិតទៅឃើញថា កូនព្រះបាទឡាត្យទៀនអសុរមាន មុខនោះ១០ដៃ២០ ល្បីឮមកថាមានឫទ្ធាក្លាហានខ្លាំងណាស់ ឈ្មោះ ទសកណ្ឋអសុរ សោយរាជ្យនៅក្រុងលង្កាទ្វីបនាយ ។ ព្រះអង្គទ្រង់គិត ឃើញដូច្នោះហើយ ក៏ទ្រង់បង្គាប់ប្រាប់ប្រើទៅចេតបុត្រជាទេវបំរើ ហើយ ថាចូរអ្នកទៅហៅទសកណ្ឋអសុរជាឆាប់ ដែលនៅក្រុងត្រៃពិជ័យលង្កា មហានគរនោះឲ្យមកក្នុងថ្ងៃនេះហោង ។

កាលនោះ រីឯចេតបុត្រទេវបំរើ លុះបានស្ដាប់ព្រះរាជតម្រាស់ ត្រាស់ប្រើអាត្មាហើយ ក៏លើកដៃក្រាបថ្វាយបង្គំលា ហើយក៏ហោះទៅ មួយរំពេចលេចដល់ដែននគរលង្កា ហើយហោះទៅលើអាកាស ចំពោះ ត្រង់ទៅមុខសីហបញ្ជរ ហើយក៏ស្រែកប្រាប់ទៅចៅក្រុងលង្កាថា ម្នាល ទសកណ្ឋអសុរ ឥឡូវនេះព្រះឧង្ការ ព្រះមហាឥសូរប្រើយើងឲ្យមកហៅ អ្នក ថាឲ្យឡើងទៅគាល់ឯស្ថានកៃលាសគិរីក្នុងវេលានេះជាឆាប់ ។ កាល នោះក្រុងទសកណ្ឋអសុរទ្រង់ឫទ្ធិ កំពុងតែគង់ស្ថិតនៅលើបល្ល័ង្កពេជ្ររត្ន

វេទនា ទូរអស់មុខមន្ត្រីសេនាអាមាត្យគាល់ហៅនៅប្រចាំការ លុះស្រាប់តែពួកទេវបំរើស្រែកថា អង្គព្រះសយម្ភូញាណ មានទេវឱង្ការឲ្យហៅអាត្មាដូច្នោះហើយ អសុរាក៏ទ្រង់គ្រឿងរុងរឿងអលង្ការណ៍ទ្រង់កាន់ធ្នូសរសិល្បជ័យស្រេច ហើយព្រះអង្គក៏ហោះហៀរត្រៀវរ៉ៃប្រ អណ្ដែតត្រសែតដោយមេឃទៅ លុះហោះបានមកដល់មណ្ឌលទីគិរីស្ថានកៃលាសហើយក៏ចូលទៅក្រាបថ្វាយបង្គំគាល់នៅផាកណ្ដាលពួកទេវតាកិន្នរទេពទាំងឡាយ ៗ

កាលនោះ ព្រះចមចក្រាមហាស្ថានកៃលាស ទតមកឃើញទសកណ្ឋអសុរាអង្គុយគាល់ហៅនៅព្រះភក្ត្រហើយ ព្រះអង្គក៏ទ្រង់មានបញ្ជាត្រាស់ថា រីរុលហកព់មកធ្វើភ្នំកៃលាសនេះ ឲ្យទ្រុតគ្រោមផ្អៀងផ្អៀងទៅទិសឦសាន អញបានប្រើអស់ទេវលោកទាំងពួងឲ្យលើកតម្រង់ក៏មិនរួចត្រង់បានឡើយ បានជាអញប្រើបំរើឲ្យទៅហៅអ្នកឯងមកឲ្យលើកតម្រង់ឲ្យបានត្រង់ឡើងដូចដែលវិញ ។ កាលនោះ រីអង្គទសកណ្ឋអសុរាក៏លើកហត្ថាបង្គំប្រណម្យក្រាបទូលតបសព្វគ្នាមតាមព្រះឱង្ការថា ទូលព្រះបង្គំទជាខ្ញុំសុំយកអាសាធ្វើការថ្វាយ កុំឲ្យទ្រង់ព្រះករុណាព្រួយព្រះ-ចិន្តាឡើយ លុះក្រាបទូលស្រេចហើយ ក៏ទ្រង់បុទ្ធជាតួដពន្យវង្សព្រហ្មលើកដៃ ថ្វាយបង្គំលាចេញមកហើយ អសុរាក៏សម្ដែងបុទ្ធិនិមិតខ្លួននោះធំប៉ុនមហាព្រហ្មដូចភ្នំព្រះសុមេរុគិរីជាទីអស្ចារ្យ ហើយអសុរាក៏ទៅពីខាងក្រោមតាំងឈរជើងនោះជាន់លើសិលាគ្រឡាមហាប្រថពីហើយ ក៏ចូល

លីលើកឡើងតែម្តងដាក់លើស្មា ហត្ថាទាំង ២០ ក៏ឱបទៅជ្រង់ភ្នំគ្រប់មុមទាំងអស់ហើយ ក៏តាំងសម្តែងឫទ្ធីអានុភាពលាន់ឮខ្ទរខ្ទារ ញាប់ញ័រព្រះ-ធរណីតាំងលើកលីទ្រឲ្យត្រង់ តម្រង់ឲ្យត្រូវដូចដើមវិញកាលណាហើយក៏ដាក់ចុះហោង ។ កាលនោះ ពួកទេវលោកគ្រប់ ៗ ស្ថានក៏បានឃើញឫទ្ធីទសកណ្ឋអសុរ នឹង នេត្រាដូច្នោះហើយ ក៏មានសេចក្តីភិតភ័យតក្កមាក៏លាន់មាត់ថា ឱគ្នាយើងអើយទាំងអស់គ្នា ឃើញថាទីងទៅជាខ្ញុំអសុរយក្សាទាំងមហាឥសីពិធ្យាធរកិន្នរនាគគន្ធព្វគន្ធីនសុបណ្ណាគ្រុឌា ក៏បែរមើលមុខគ្នាទៅវិញទៅមកនិយាយរកគ្នា ជាទុក្ខទោមនស្សក្រៃពេកទាំងអស់គ្នាហោង ។ រីឯក្រុងទសកណ្ឋអសុរក៏មានចិត្តនោះត្រេកអរសោទរណាស់ ព្រោះដោយសារខ្លួននោះ បានតម្រង់ស្ថានកៃលាសត្រង់ដូចចិត្ត ស្រេចហើយក៏ចូលមកក្រាបបង្គំគាល់ហើយ ក៏មានដួងចិត្តនោះកំរើបដោយឫទ្ធិមិនគិតយកយសសក្តិខ្លួនជាយក្ស លោកលន់ពន់មោះហិមាហើយវាក៏ហានក្រាបទូលថាព្រះបង្គំជាខ្ញុំ សព្វថ្ងៃនេះជាចមមកុដក្រុងលង្កា អាណាចក្រលើយក្សទាំងពួងឥឡូវនេះខ្ញុំព្រះករុណា ដែលសោយរាជសម្បត្តិគ្រប់គ្រងបុរីរាជធានីនេះ គ្មានរាជទេពីជាទីអគ្គមហេសីសោះ នោះខ្ញុំព្រះករុណា សូមព្រះរាជទាននាងព្រះឧមាភគវតី យកទៅធ្វើជាអគ្គមហេសីសោយរាជសម្បត្តិហោងតាមតែទ្រង់ព្រះករុណាមេត្តាប្រោស ។

កាលនោះ ព្រះសយម្ពូវនាថនាថា បានស្តាប់ពាក្យអសុរពទី ភូមី ក៏ទ្រង់រំពឹងគិតទៅតូចព្រះទ័យណាស់ទឹកថាអានេះ វាព្រហ៊ើនហ៊ានសុំយកនាងឧម្មា ជាមាតាអសុរពុទ្ធិ មិនគិតដល់ពង្សវង្សា ហើយចុះអញបានជាបង់វាបាទីងវាថាឲ្យវាយកតាមចិត្តប្រាថ្នា បើទុកជាអញឲ្យទៅវា ក៏គង់តែវាយកមកឲ្យអញវិញមិនអីទេ ទ្រង់ព្រះបិន្តាគិតឃើញដូច្នោះហើយ ទើបថ្លែងព្រះឧង្ការថា ណែអសុរទសកណ្ឋ ដែលឯងប្រាថ្នា ហាមាត់ហ៊ានសុំយកនាងឧមាភោគវត្តីនោះ អញក៏មិនថាអីទេ អញក៏ឲ្យតាមចិត្តឯងប្រាថ្នាហោង ៗ រីឯទសកណ្ឋអសុរក៏មានចិត្តនោះត្រេកអរពន់ពេកក្រៃ ក៏លើកដៃឡើងថ្វាយបង្គំប្រណម្យក្រាបទូលលាវាទៅ ទីងលូកដៃពអង្គព្រះឧមាភោគវត្តី ពាល់ត្រូវខ្លួននាងកាលណា ក៏ក្តៅដូចភ្លើងឆេះ វាក៏មានះចូលវាប់លើកព្រះបាទានាងឡើង ឲ្យនាងអង្គុយពីលើក្បាល ហើយហោះទៅ ក៏វាបណ្តាលចេញកំដៅពីខ្លួននាងឧមានោះផង ហើយថែមទាំងព្រះអាទិត្យផង អសុរក៏ទ្រាំទ្រពនាងលើក្បាលពុំបាន ក៏វាក់នាងចុះឲ្យនាងដើរដើបណ្តើរនាងទៅហោង ៗ

កាលនោះ រីឯពួកទេវតាតូចធំទាំងពួង លុះឃើញព្រះឥសូរព្រះភគវាន ឲ្យនាងឧមាភោគវត្តីទៅទសកណ្ឋកាលណាហើយ ក៏ផ្អើលភ្ញាក់ភ័យរន្ធត់ស្លុតស្លុងព្រះស្មារតីទាំងអស់គ្នា ក៏បបួលគ្នាទៅគាល់ព្រះនារាយណ៍ឫទ្ធាដែលគង់ស្ថិត នៅឯឆ្នេរសមុទ្រសាគរនោះ លុះបានមកដល់កាល-

ណា កំនាំគ្នាក្រាបទូលថា ឥឡូវនេះព្រះមហាចមមកុដស្ថានកៃលាស ព្រះអង្គទ្រង់ព្រះរាជទានព្រះនាងឧមាគោគវត្តីឲ្យទៅរាក្សសទសកណ្ឋ យក្សបណ្ដាពួកទេពទេវ ក៏បានសេចក្ដីក្ដៅក្រហាយតែគ្រប់ ៗ ស្ថានទេវលោកខ្ទះក៏ទ្រង់យំសោកសោកខ្លួនខ្លាំងណាស់ ដូច្នេះសូមព្រះអង្គជាម្ចាស់ ជួយជីវិតទេវលោកឲ្យបានសេចក្ដីសុខឥតទុក្ខតទៅ ៗ កាលនោះព្រះនារាយណ៍បុទ្ធបានស្ដាប់ទេវតាទូលប្រាប់ដូច្នោះហើយ ព្រះអង្គក៏មានបន្ទូលថា រីឯព្រះឧមាគោគវត្តីនោះ ដែលទ្រង់ព្រះករុណាព្រះរាជទានឲ្យទៅរាក្សសទសកណ្ឋពាលា អ្នកពាល់គ្នាកុំគិតភ័យឡើយ មិនអីទេគង់តែរកទីងថាយវិញពុំខានឡើយ ព្រះអង្គទ្រង់មានព្រះបន្ទូលតែម៉្លេះហើយ ព្រះអង្គក៏ទ្រង់ហោះមកមួយរំពេច លឿនហួសមក ជាមុនទសកណ្ឋវិញ លុះបានមកដល់កាលណាហើយ ព្រះអង្គក៏និមិត្តខ្លួនព្រះអង្គទៅជាយក្សតាសម្នួយនាក់ហើយ ដៃកាន់ចបកាប់កាប់តពួថៅ ជីកគាស់កាប់ដើមចំការដាំដំណាំនោះ យកដើមឈើនោះមកកប់ខាងចុងទៅខាងដី យកគល់ទៅខាងលើអាកាស ស្រេចហើយក៏តាំងតូនដីរែកទឹកស្រោចដំណាំនោះ បែកញើសរហាមហើយធ្វើដូចជាត្រេកអរញោញញឹមញញែមរង់ចាំបញ្ឆោតក្រុងទសកណ្ឋអសុរ ៗ

កាលនោះ រីក្រុងទសកណ្ឋអសុរ លុះនាំនាងឧមាគោគវត្តី បណ្ដើរដើរមកតាមផ្លូវ លុះមកដល់ហើយក៏ឃើញយក្សក្រញាស់មួយនាក់ ស្លូវ

ព្រោងធ្វើចំការដាំដើមឈើយកគល់ឡើងលើ ចុងចុះក្រោមកប់ទៅក្នុងដី ហើយរែកទឹកស្រោចធ្វើញញឹមញញែម គ្រហែមម្តង ៗ ដូចជាអរណាស់ ដូច្នោះហើយអសុរក៏ទឹកឆ្ងល់សង្ស័យក្នុងចិត្តគិតថា មនុស្សក្នុងពិភពផែន-ដីក្រោយលោកនេះ មិនមែនមានលោកណាអ្នកណាធ្វើការយ៉ាងដូច្នេះ កាលណាហើយក៏រទឹងបានផ្លែផ្កាស៊ីទឹងគេ គិតដូច្នោះហើយ ទសកណ្ឋអសុរក៏ដើរចូលទៅបានជិតយក្សចាស់ព្រះនរាយណ៍ហើយ ក៏ពោលនូវពាក្យរាំចាថា ណៃយក្ស! តាចាស់ឯងនេះពេញហៅជាឆោតខ្លៅល្ងង់អីដល់ម្ល៉េះ រីដែលតាឯងដាំដើមឈើយ៉ាងនេះតើរទឹងបាន ផ្លែផ្កាផលប្រយោជន៍ទឹងអាស្រ័យពីណាមក យើងមិនដែលឃើញឡើយ កាលនោះយក្សព្រះនរាយណ៍ក៏បានស្តាប់សំដីអសុរថាឲ្យដូច្នោះហើយ ក៏ធ្វើជាសើចញញឹមញញែមហើយឆ្លើយតបទៅវិញថា ឯងថាឲ្យអញនេះថាជាមនុស្សឆ្កោតខ្លៅល្ងង់ណាស់ អញគិតទៅក្រឡះទៅថាឯងនោះឆោតឆ្កួតល្ងង់ជាងអញវិញ គិត ៗ ទៅអញចង់តែទះដៃសើចលេងសប្បាយ ឲ្យសមមុខឯងទៀត ព្រោះឯងនេះនៅមិនទាន់ដឹងខ្លួនផង ។

កាលនោះ រីទសកណ្ឋអសុរបានស្តាប់យក្សចាស់ថាឲ្យដូច្នោះហើយ អសុរក៏ទឹកឆ្ងល់សង្ស័យនឹងពាក្យយក្សចាស់ពោលថាឲ្យនោះ ទើបឆ្លើយតបទៅវិញថា ណៃយក្សតាចាស់ហេតុដូចម្តេចបានជាតាឯងពោលនូវពាក្យ មិនគួរមិនគប្បីហ៊ានស្តីឲ្យយើង មិនមានកោតក្រែងអញឡើយ

ខ្លួនអញនេះអម្បូរពូជពង្សវង្សសោត្រៃតាទីងមហាព្រហ្ម លោកក៏ជាធំក្នុងត្រ័យកពដែរ ឯងថាអញឆោតខ្លៅនោះ តើឃើញអញឆោតដោយអ្វី ៗ ខ្លះ មើលឯងប្រាប់មកអញឲ្យដឹងផង កុំអីខ្លួនឯងនេះអញវាយនឹងដំបងឲ្យស្លាប់ ៗ កាលនោះយក្សព្រះនពយណ៌ធ្វើជាសើចញឹមៗ ហើយទើបពោលវាចាតបទៅអសុរាថា ខ្លួនអញនេះជាយក្សបាសមែន ប៉ុន្តែអញអាណិតអាឯងយកតែបុណ្យទៅចុះ តាមមារយាទអាឯងនេះ ព្រហើនដូណាស់ មិនចង់ប្រាប់សោះ តែបើអញប្រាប់អាឯងហើយ អាឯងកុំភ្លេចគុណអញ ទើបអញនឹងប្រាប់អាចង្រៃ ពាលប៉ោឡៃឯងឲ្យដឹង ចុះអាឯងដូចម្តេចក៏មិនយកនាងល្អជា ក៏ទៅយកឯស្រីកាឡកិណីដូចជាយកព្រះកាលទៅបំផ្លាញគោត្តត្រកូលពូជពង្សវង្សា អាឯងនឹងសាបសូន្យអស់ទាំងក្រុងលង្កាទ្វីបមួយរំពេចហោង ៗ រីឯក្រុងទសក្រ្តយក្សា ក៏បានស្តាប់យក្សតាបាសថាដូច្នោះហើយអសុរាក៏នឹកសង្ស័យ ឆ្នៃគិតថានាងនេះប្រហែលជាមែនដូចពាក្យតាបាសគាត់ថា នាងនេះចំឡែកផ្លែកនឹងស្រីទាំងអស់ខ្លួននោះក្តៅដូចភ្លើងពាល់មិនបាន គិតហើយក៏សួរទៅយក្សតាបាសថា នាងណាដែលតាឯងថាល្អនោះ ណ្ហើយតាអើយតាឯងអាណិតមេត្តាជួយប្រាប់ខ្ញុំចុះ លោកតាខ្ញុំនឹងយកនាងនេះទៅផ្លាស់វិញ អាណិតតែខ្ញុំចុះ ខ្ញុំមិនភ្លេចគុណលោកតាទេ ខ្ញុំនឹងតបព្រះគុណលោកតាឲ្យពេញចិត្ត ៗ

កាលនោះ យក្សព្រះនពយណ៌បានស្តាប់ក៏ឆ្លើយតបទៅវិញថា នាង

មួយនោះ ដែលឈ្មោះនាងមណ្ឌាគិរី ជាស្រីមានលក្ខណាឆោមលោមល្អ ល្អះលើសអស់ស្រីនៅស្ថានសួគ៌ាជាទីសេចក្ដីចំរើន ទើបបានតពូជពង្សវង្ស ត្រកូលតទៅហោង ៗ កាលនោះ ទសកគ្រូអសុរលុះបានស្ដាប់ពាក្យ យក្សតាចាស់ប្រាប់ដូច្នោះហើយ ក៏នឹកអរណាស់ទើបឱនក្បាលចុះ យក ដៃលើកព្រះបាទាឡើងទ្រគង់លើក្បាលហើយ ក៏ហោះវិលត្រឡប់ក្រោយ វិញយកនាង:ទៅថ្វាយសម្ដេចព្រះឥសូរាធិបតី លុះហោះមកដល់ហើយ ទើបដាក់នាងចុះ ហើយក៏ក្រាបថ្វាយបង្គំថ្វាយនាងវិញហោង ទើបក្រាប បង្គំទូលទៅព្រះឥសូរថា ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទាននាងមណ្ឌា-គិរីវិញ តាមតែទ្រង់ព្រះករុណាមេត្តាប្រោស ៗ កាលនោះ រីអង្គព្រះ-ឥស្សរាធិបតីត្រ័យកពចមមកុដកៃលាសស្ថាន បានស្ដាប់អសុរទូលដូច្នោះ ហើយនឹងឃើញនាងឧមាភោគវត្តីយកមកឲ្យវិញដូច្នោះហើយ ព្រះអង្គ ទ្រង់ញញឹមអរហើយមានព្រះឧង្ការថា រីអង្គនាងឧមាភោគវត្តីនេះ ជាព្រះ មាតាទេវបុត្រទេវតាទាំងពួង រាសនាឯងនេះមិនគួរទេ ឥឡូវនេះថាអើបើ ឯងសុំយកនាងមណ្ឌាគិរីវិញអញក៏មិនថាអ្វីទេ អញក៏ឲ្យតាមចិត្តឯង ហោង ៗ ត្រាស់ហើយព្រះអង្គក៏ទ្រង់ត្រាសហៅទៅនាងមណ្ឌាគិរីឲ្យចេញ មក នាងលុះឮព្រះឧង្ការព្រះមហាឥសូរហៅហើយ នាងក៏ចេញមកក្រាប ថ្វាយបង្គំគាល់ ហើយព្រះអង្គក៏ទ្រង់ព្រះរាជទានឲ្យទៅទសកគ្រូអសុរថា ឯងយកទៅចុះ ទើបបានរុងរឿងថ្កុំថ្កើងឧត្ដមបរមរាជធានីក្នុងទីលង្កាហោង ៗ

(នៅមានត)

ផ្នែកកំណត់និងប្រវត្តិការណ៍

# ពិធីបុណ្យបូជាព្រះសព និងការតែងតាំងចៅអធិការ និង ឧបជ្ឈាយ៍ នៅវត្តព្រះស្រីសារពេជ្ញ ឃុំជាយ ស្រុកបាភ្នំ ព្រៃវែង

សហជីវិន យ៉ែម មុនីរ័ត្ន ប្រមុខខេត្តព្រៃវែង មន្ត្រីខេត្ត ស្រុក ឃុំ និងមន្ត្រីក្រសួងធម្មការខ្លះ បានទៅរួបរួមជាមួយពុទ្ធបរិស័ទក្នុងស្រុកបាភ្នំ និងស្រុកពាមរហ៍ ក្នុងពិធីបុណ្យបូជាព្រះសពព្រះតេជព្រះគុណ បួយ-ទី អតីតចៅអធិការវត្តព្រះស្រីសារពេជ្ញ និងពិធីបុណ្យប្រកាសតែងតាំងលោកគ្រូចៅអធិការនិងឧបជ្ឈាយ៍ថ្មីសំរាប់វត្តព្រះស្រីសារពេជ្ញ ក្នុងឃុំជាយ ស្រុកបាភ្នំ ក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះសង្ឃរាជថ្នាក់ទី ២ ។

យើងសូមជូនសុន្ទរកថានៃពិធីបុណ្យនេះ ទាំងស្រុងដូចតទៅ

## សុន្ទរកថាស្វាគមន៍

ថ្លែងដោយព្រះបាឡាត់ភមរា ប្រាក់-ចុក

បំពោះសម្តេចព្រះសុធម្មាធិបតី ព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ ក្នុងឱកាសបូជាសពលោកគ្រូចៅអធិការ ឡួយ ធី វត្តព្រះស្រីសារពេជ្ញ ឃុំជាយ ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីថ្ងៃទី ២០ កុម្ភៈ ឆ្នាំ ១៩៦៥ មានសេចក្តីដូចតទៅនេះ ៖

សូមព្រះតេជះតំកល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូល ក្រោមល្អងធូលីព្រះបាទ សម្តេច
ព្រះសុធម្មាធិបតី ព្រះសង្ឃរាជគណ.ធម្មយុត្តិកនិកាយ

សូមទ្រង់ជ្រាប ។

បពិត្រសម្តេចជាអម្ចាស់ ! ថ្ងៃនេះចាត់ទុកថាជាអភិលក្ខិតសម័យ ប្រកបដោយនក្ខត្តឫក្សដ៏មហាប្រសើរ ដែលពុទ្ធបរិស័ទចំណុះវត្តព្រះស្រី-សារពេជ្ញ គ្រប់ប្រភេទ, ព្រមទាំងគណៈកម្មការ មានទូលព្រះបង្គំជាប្រធាន, បានបញ្ចេញនូវមនោសញ្ចេតនា ប្រកបដោយប្រីតិប្រាមោទ្យ យ៉ាងរំភើបជាទីបំផុត, ដោយបានផ្ញើបដិសណ្ឋារកិច្ចថ្វាយចំពោះល្អងធូលីព្រះបាទ, និងបានឃើញព្រះភក្ត្រដ៏ប្រិមប្រិយនៃសម្តេចជាអម្ចាស់, ជាទីស្រឡាញ់និងជាទីគោរពរបស់ខ្លួន ស្តេចយាងមកជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យបូជាសព ព្រះគ្រូញាណទេពាចារ្យបិតញ្ញាណោ ឈួយ ធី អតីតចៅអធិការវត្តព្រះស្រីសារពេជ្ញ ដែលទូលព្រះបង្គំជាខ្ញុំទាំងឡាយកំពុងតែចាត់ចែងធ្វើឡើងនេះ ។

សូមទ្រង់ព្រះមេត្តាប្រោស ! ចំពោះព្រះរាជដំណើរនៃល្អងធូលីព្រះបាទ ដែលទ្រង់សព្វព្រះរាជហឫទ័យ ស្តេចយាងមកកាន់វត្តព្រះស្រីសារពេជ្ញនេះ មិនមែនគ្រាន់តែដើម្បីញ៉ាំងពិធីបុណ្យបូជាសពឱ្យមានសភាពថ្កុំថ្កើងរុងរឿងប៉ុណ្ណោះទេ, គឺជាកត្តាមួយសំដែងឲ្យឃើញយ៉ាងជាក់ច្បាស់ នូវ

ព្រះរាជហឫទ័យប្រោសប្រណីរបស់ល្អងធូលីព្រះបាទ ចំពោះមកលើពុទ្ធបរិស័ទជាកូនចៅព្រះអង្គ នៅក្នុងជនបទឆ្ងាយដាច់ស្រយាលដោយពុំបានរើសមុខ ដែលទូលព្រះបង្គំជាខ្ញុំទាំងឡាយ បានចារិកទុកក្នុងហទយវត្ថុរបស់ខ្លួនគ្រប់ ៗ គ្នា ពុំអាចនឹងបំភ្លេចបាននូវ ព្រះមហាករុណាធិគុណដ៏ធ្ងន់លើសលប់នេះ, ហើយបានប្ដេជ្ញាអស់ពីដួងចិត្តថ្វាយនូវសេចក្ដីស្វាមីភក្ដិគោរពបូជា ប្រកបដោយកតញ្ញូកតវេទិតា ដរាបលុះត្រាតែអវសាននៃជីវិតរៀង ៗ ខ្លួន ។

សូមទ្រង់ព្រះមេត្តាប្រោស! ដូចល្អងធូលីព្រះបាទទ្រង់ទតឃើញស្រាប់ហើយ វត្តព្រះស្រីសារពេជ្ជនេះស្ថិតនៅឆ្ងាយពីព្រះរាជធានី មានផ្លូវគមនាគមន៍ពុំបានប្រសើរទាំងសេនាសនៈ និងគ្រឿងសម្ភារៈប្រើប្រាស់ក្នុងវត្តទៀតសោតក៏ពុំសូវមានគ្រប់គ្រាន់ ហេតុនេះហើយទូលព្រះបង្គំជាខ្ញុំទាំងឡាយដឹងច្បាស់ថា ការធ្វើបដិសណ្ឋារកិច្ចថ្វាយចំពោះសម្ដេចជាអម្ចាស់ មុខជាពុំបានសមរម្យនឹងព្រះកិត្តិយសរបស់សម្ដេចជាអម្ចាស់ប៉ុន្មានទេ គង់មានការឆ្គាំឆ្គងភ្លាត់ខុសខ្វះខាតខ្លះ តែទោះបីយ៉ាងណា ៗ ក្ដីទូលព្រះបង្គំជាខ្ញុំទាំងឡាយ មានសេចក្ដីសង្ឃឹមយ៉ាងកក់ក្ដៅជាមុនថាសម្ដេចជាអម្ចាស់មុខជានឹងទ្រង់ព្រះមេត្តាសន្ដោសប្រោសប្រណីចំពោះកូនចៅដែលស្ថិតនៅចុងកាត់មាត់ញកឆ្ងាយ ហើយចង់សំដែងនូវស្វាមីភក្ដិដោយចិត្តស្មោះត្រង់ពុំខាន ។

ជាទីអវសាននេះ កូនខ្ញុំនាមនៃពុទ្ធបរិស័ទទាំងឡាយ និងកូននាមផ្ទាល់ខ្លួនព្រះបង្គំជាខ្ញុំ សូមថ្វាយនូវព្រះពរសាគមន៍ ដោយសុំបួងសួងចំពោះគុណព្រះរតនត្រៃ និងវត្ថុស័ក្តិសិទ្ធិដែលមាននៅក្នុងសកលលោកទាំងមូល មានទេព្តារក្សាវត្តព្រះស្រីសារពេជ្ញនេះជាដើម សូមជួយពិតក្តិរក្សាសម្តេចជាអម្ចាស់ សូមឱ្យការគង់ប្រថាប់នៅនាវត្តព្រះស្រីសារពេជ្ញនេះក្តី និងក្នុងការធ្វើព្រះរាជដំណើរនិវត្តន៍ទៅកាន់ព្រះរាជធានីវិញក្តី សូមទ្រង់ប្រកបតែនឹងព្រះបរមសុខគ្រប់ឥរិយាបថ និង សូមទ្រង់មានព្រះជន្មាទីឃាយុយឺនយូរជាងរយព្រះវស្សា ដើម្បីបានជាទីពឹងពំនាក់នៃពុទ្ធបរិស័ទជាកូនចៅតរៀងទៅ ។

ម្យ៉ាងទៀត អាត្មាភាពតាងនាមឧបាសក - ឧបាសិកា គណៈកម្មការនិងសិស្សានុសិស្សទាំងអស់ សូមសំដែងនូវមនោសញ្ចេតនាប្រកបដោយបីតិសោមនស្សរីករាយយ៉ាងជ្រាលជ្រៅជាទីបំផុតថែមទៀត ចំពោះឯកឧត្តមព្រះតេជព្រះគុណ ព្រមទាំងអស់លោកទាំងឡាយ មានឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងធម្មការនិងលោកអ្នកឧកញ៉ា ចៅហ្វាយខេត្តព្រៃ-វែង ជាដើម ដែលមានចិត្តសប្បុរសស៊ូលះបង់ធុរៈផ្ទាល់ខ្លួនអញ្ជើញមកទាំងនឿយហត់ ដើម្បីជួយទំនុកបំរុងក្នុងពិធីបុណ្យបូជាសពព្រះគ្រូញាណទេពាចារ្យ អតីតចៅអធិការវត្តព្រះស្រីសារពេជ្ញនេះ អាត្មាភាព សូមបួងសួង សុំអានុភាពនៃព្រះរតនត្រៃនិងកុសលរាសីទាំងអម្បាលនេះ ជួយ



សម្តេចព្រះសង្ឃរាជថ្នាក់ទី ២ ទ្រង់ប្រថាប់ក្នុងព្រះពន្លាពិសេស



សម្តេចព្រះសង្ឃរាជ ស្តេចយាងបូជាផ្កា ចំពោះព្រះសព

អភិបាលទ្រទ្រង់ឯកឧត្តម - ព្រះតេជព្រះគុណ - លោកស្រី - ព្រមទាំងអស់លោកអ្នកទាំងឡាយ សូមឲ្យបានប្រកបតែនឹងសេចក្ដីសុខ-ចំរើនគ្រប់ទិវាពត្រីកាលចាប់ដើមតាំងពីពេលនេះតទៅកុំបីឃ្លៀងឃ្លាតឡើយ ។

គួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស

សូមព្រះតេជះតម្កល់លើត្បូង !

គួរពុំគួរសូមអភ័យទោស

---

## ជីវប្រវត្តិព្រះគ្រូញាណនេពជារ្យ

### បិតញ្ញាណោ ម្ជុយ-ឌី

ថ្លែងដោយព្រះតេជព្រះគុណ ស្វាយ សុខ ចៅអធិការមង្គលរតនារាម កំពង់ត្របែកព្រៃវែង

សូមព្រះតេជតម្កល់លើត្បូង

សូមព្រះពរទានក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទ សម្ដេចព្រះសង្ឃរាជជាអម្ចាស់

សូមក្រាបបង្គំទូលព្រះថេរានុថេរៈ គ្រប់ព្រះអង្គ;

សូមជំរាបឯកឧត្ដម- ព្រះតេជព្រះគុណ- ព្រមទាំងលោកស្រី- និងលោកអ្នកសប្បុរសទាំងអស់

សូមទ្រង់ជ្រាប សូមទានជ្រាប សូមជ្រាប ។

ជាបឋម! ក្នុងនាមគណៈកម្មការបុណ្យ ព្រមទាំងឧបាសក-សិកានិងក្រុមសិស្សានុសិស្សវត្តព្រះស្រីសារពេជ្ញទាំងប៉ុន្មាន មានព្រះបាឡាត់គមព ប្រាក់ ជុក ជាប្រធាន សូមថ្វាយនូវមនោសញ្ចេតនាប្រកបដោយ

បីតិសោមនស្សទិន់កតញ្ញូតាយ៉ាងជ្រាលជ្រៅជាអតិបរមា ចំពោះសម្តេចជាអម្ចាស់ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ព្រមទាំងឯកឧត្តម-ព្រះតេជព្រះគុណលោកស្រី-និងលោក-អ្នកសប្បុរសទាំងអស់ ដែលមានហឫទ័យប្រោសប្រណី ស្តេចយាងមកជាព្រះអធិបតីដ៏ខ្ពង់ខ្ពស់ និងនិមន្ត អញ្ជើញមកជួយឧបត្ថម្ភកុសលពិធីបុណ្យបូជាសព ព្រះគ្រូញាណទេពាចារ្យ ឋិតញាណោ ឃួយ ធី អតីតចៅអធិការវត្តព្រះស្រីសារពេជ្ញ ដែលទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា អាត្មាភាពទាំងអស់គ្នា បានចាត់ចែងធ្វើឡើងនេះឲ្យមានសភាពថ្កុំថ្កើងរុងរឿងគួរជាទីពេញចិត្តយ៉ាងក្រៃលែង ។

សូមទ្រង់ព្រះមេត្តាប្រោស ! សូមអភ័យទោស ពេលនេះទូលព្រះ-បង្គំជាខ្ញុំ ខ្ញុំព្រះករុណា អាត្មាភាព សូមព្រះរាជវរោកាស សូមឱកាស ថ្លែងនូវជីវប្រវត្តិព្រះសពព្រះគ្រូញាណទេពាចារ្យ ឋិតញាណោ ឃួយ ធី ដោយត្រួស ៗ ថ្វាយទ្រង់ជ្រាប និងប្រគេនជូនជ្រាបដូចតទៅនេះ :

## ព្រះគ្រូញាណទេពាចារ្យ
## ឋិតញាណោ ឃួយ ធី

ចៅអធិការវត្តព្រះស្រីសារពេជ្ញ ឃុំធាយ ស្រុកបាភ្នំ (ព្រៃវែង) កើតនៅថ្ងៃសៅរ៍ ខែចេត្រ ឆ្នាំមមែ បញ្ចស័ក ព.ស. ២៤២៥ ក្នុងភូមិបាបោងក្រោម ឃុំបាបោង ស្រុកពាមរហ៍ ខេត្តព្រៃវែង ជាបុត្រច្បង នៃឧបាសកឃួយ ឃោក ឧបាសិកា ដើង ស្រុកកំណើតរបស់បិតានៅភូមិ បាបោង

ក្រោម ស្រុកកំណើតរបស់មាតានៅភូមិដើមទឹក ឃុំពង់ទោះ ស្រុកបាភ្នំ (ព្រៃវែង) ។

កាលកុមារ ឡួយ ធី កើតបានមួយឆ្នាំ ។ បាសក បួយ ឃ្លោក មានប្រពន្ធមួយទៀត ហើយទៅនៅតាមប្រពន្ធចុង ឯខេត្តកំពង់ឆ្នាំងដល់បានកូនស្រីមួយ ។ បាសក បួយ ឃ្លោក ទទួលអនិច្ចកម្មទៅ ។

ឯឧបាសិកាដើងនៅកំព្រាតែពីរនាក់ ទឹង កុមារទី នៅភូមិបាបាង ក្រោមបានជាងមួយឆ្នាំ ដោយសេចក្ដីលំបាក ទិដ្ឋការរស់នៅពេក ទ្រាំមិនបាន ក៏នាំកូនវិលត្រឡប់មកនៅជាមួយបងស្រី ដែលមានប្ដីនៅភូមិល្វា ក្នុងឃុំដាយ ស្រុកបាភ្នំ ខេត្តព្រៃវែងវិញ ឯរបរកទទួលទានតែម្នាក់ឯង ដោចខ្សែកពីបង ។ ដល់កុមារ បួយ ទី អាយុបានជាង ១០ ឆ្នាំ មាតាក៏យកឲ្យទៅសិក្សាអក្សរសាស្ត្រក្នុងសំណាក់ ព្រះតេជព្រះគុណ អ៊ុំ ចៅអធិការវត្តព្រះស្រីសារពេជ្ញ ក្នុងឃុំដាយ (ស្រុកបាភ្នំ ព្រៃវែង) វត្តនោះនៅខាងជើងភូមិល្វា មានចម្ងាយប្រមាណជាង ៥០០ ម៉ែត្រពីភូមិទៅ ។

កុមារ បួយ ទី នៅសិក្សាឯវត្តតិចពេលណាស់ នៅផ្ទះច្រើនជាងដើម្បីជួយធ្វើការ ព្រោះម្ដាយនៅតែម្នាក់ឯង កេរ្ដិ៍មតិកមិនសូវមានទីងគេផង ដោយមានវិរិយភាពនិងសេចក្ដីវៃឆ្លាតមិនយូរប៉ុន្មានបានរៀនចេះដឹងអក្សរសាស្ត្រ និង ធម៌វិន័យល្មមសមគួរតាមសម័យនិយម ។ កុមារ បួយ ទី ជាទីពេញចិត្តព្រះទ័យរបស់ព្រះតេជព្រះគុណ ព្រះនាម អ៊ុំ ពនពេក

ណាស់ ដោយសេចក្ដីព្យាយាម វិជ្ជាគតិនិងបំរើគោរពគ្រូ ។

លុះជន្មាយុបាន ១៥ ឆ្នាំ កុមារ បួយ ទី បានចូលទៅសូមបព្វជ្ជាក្នុង សំណាក់ព្រះតេជព្រះគុណព្រះនាម អ៊ុំ លោកក៏ព្រមអនុញ្ញាតឲ្យកុមារ បួយ ទី បព្វជ្ជាជាសាមណេរ ក្នុងឆ្នាំរការនព្វស័ក ព.ស. ២៤៣៩ ។ ឯសាមណេរ បួយ ទី តាំងពីថ្ងៃដែលបព្វជ្ជាមក មានចរិយាស្រគត់ស្រគំ ឧស្សាហ៍ប្រតិបត្តិបំរើគ្រូតាមកាលគួរ ។

បព្វជ្ជាបានមួយវស្សាក៏លាចាកសិក្ខាបទ សឹកចេញទៅនៅបំរើម្ដាយ ដល់ព្រះជន្មាយុ ២១ ឆ្នាំ ក៏ចូលទៅនៅវត្តដដែលទៀត ដើម្បីសិក្សាសិក្ខា-បទចំនួន ៥ ខែ បានចេះចប់ បុព្វសិក្ខាបទ ១២៧ និងអភិសមាចារ ក៏ទៅសូមឧបសម្បទាជាភិក្ខុភាវៈ ក្នុងពទ្ធសីមាវត្តសំបួរ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្ដាល និមន្តព្រះតេជព្រះគុណកុល ចៅអធិការវត្តសំបួរ ជាឧប-ជ្ឈាយ៍និមន្តព្រះតេជព្រះគុណព្រះនាម ញឹក ចៅអធិការវត្តបឹងក្អែក និងព្រះតេជព្រះគុណព្រះនាម អ៊ុំ ចៅអធិការវត្តព្រះស្រីសារពេជ្ញ ជាអនុ-សាវននិងកម្មវាចា ព្រះឧបជ្ឈាយ៍ឲ្យនាមបញ្ញត្តិថា „ បិតញ្ញាណោ " ក្នុងឆ្នាំឆ្លូវជោះបញ្ចស័ក ព.ស. ២៤៤៥ ឧបសម្បទបាន ៣ ថ្ងៃ ត្រឡប់ទៅនៅវត្តព្រះស្រីសារពេជ្ញវិញ ។ លុះឧបសម្បទបាន ៥ វស្សា ក៏និមន្តទៅកាន់ខេត្តកំពង់ឆ្នាំងនាំយកអដ្ឋិរបស់ បិតា មកធ្វើបុណ្យរំលាយនៅទីវត្តព្រះស្រីសារពេជ្ញ ។

ភិក្ខុ បួយ ទី ចាប់តាំងពីឧបសម្បទមក តែងចិញ្ចឹមម្ដាយជានិច្ច

របស់ណាដែលកើតឡើងដោយផ្ទាល់ខ្លួន យកទៅជូនមាតាទាំងអស់ ទុំទុកបំរុងថែទាំ តាំងពីទីលំនៅ ស្បៀកពាក់ ទទួលទានគ្រប់គ្រាន់ ព្រមទាំងថ្នាំកែរោគនិងព្យាបាលរោគពេលដែលមានជម្ងឺ ។

ឧបសម្បទបាន ១០ វស្សា មាតាក៏ទទួលអនិច្ចកម្មទៅក្នុងជន្មាយុ ៦០ ឆ្នាំ បានធ្វើបុណ្យរំលាយសពមាតារួចយកធាតុបិតាមាតាទាំងពីរ ទៅទុកថែរក្សាលើសំណឹងរបស់ខ្លួន សូម្បីកសាងចេតិយរួចហើយក៏មិនដាច់ព្រះទ័យនឹងយកទៅបញ្ចុះ មិនចង់ឲ្យឃ្លាតពីសំណឹងរបស់លោកសោះ ម៉្លោះហើយធាតុនេះ ទៅមិនទាន់បញ្ចុះដរាបដល់ឥឡូវនេះ ចំណែកមតករបស់មាតាបន្តិចបន្តួច ប្រមូលយកដាក់វត្ត ថ្វាយជាទានបូជាទាំងអស់ ។

ចេតិយដែលសាងបំរុងបញ្ចុះធាតុមាតាបិតានិងគ្រូលោកនោះ ឥឡូវចង់ខូចអស់ តែមុនពេលអនិច្ចធម្ម លោកបានផ្តាំព្រះបាលីដ្ឋកមកថា ឲ្យជួសជុលចេតិយនេះ រួចហើយយកធាតុមាតាបិតា គ្រូ និងអដ្ឋិព្រះអង្គលោកទៅបញ្ចុះជាមួយគ្នាក្នុងចេតិយនេះ ។

### អំពីកាន់តំណែងជាចៅអធិការ

ភិក្ខុ បួយ ទី ឧបសម្បទបាន ៥ វស្សា ដោយសេចក្តីវៃឆ្លាត លោកគ្រូ អ៊ុំ តាំងឲ្យធ្វើជាគ្រូសូត្រឆ្វេង ឧបសម្បទបាន ១០ វស្សា លោកគ្រូ អឹម តាំងឲ្យធ្វើជាគ្រូសូត្រស្តាំក្នុងវត្តព្រះស្រីសារពេជ្ញ ។ ដល់ឆ្នាំម្សាញ់ត្រីស័ក ព.ស. ២៤៨៤ ព្រះគ្រូវិន័យមុនី ជុំ អឹម អនិច្ចធម្មទៅ សម្តេច

ព្រះមង្គលទេពាចារ្យព្រះនាម ( ស៊ុក ) បានតាំងគ្រូសូត្រ មួយ ទី ជាគ្រូញាណទេពាចារ្យ ជាចៅអធិការ គ្រប់គ្រងពុទ្ធបរិស័ទ ភិក្ខុសាមណេរ ក្នុងវត្តព្រះស្រីសារពេជ្ញ ក្នុងព្រះជន្មាយុ ៥៩ ឆ្នាំ វស្សា ៣៩ ។

ដល់ឆ្នាំរកាសប្តស័ក ព.ស ២៤៨៨ ព្រះគ្រូគន្ធានុវង្ស សោក វត្តបុប្ផារតី (អនិច្ចធម្ម ) សម្តេចព្រះសុធម្មាធិបតីព្រះនាម អ៊ុង ស្រី តាំងព្រះគ្រូញាណ-ទេពាចារ្យ មួយ ទី ជាទីឧបជ្ឈាយ៍ ដើម្បីឧបសម្បទាក្នុងវត្តព្រះសារពេជ្ញ និងវត្តបុប្ផារតី ក្នុងព្រះជន្មាយុ ៦៣ ឆ្នាំ វស្សា ៤៣ ។

អំពីសមិទ្ធិជាស្នាព្រះហស្ត

លោកបានកសាងព្រះវិហារដែលលោកគ្រូ ជុំ អឹម កសាងពុំទាន់ហើយ និងកសាងកុដិថ្មមួយខ្នង អំពីបេតុងអារមេ និងផ្លាសផុលសាលាធំមួយខ្នងដែលលោកគ្រូនួនកសាង កសាងពុំទាន់ហើយ កសាងកុដិឈើពីរខ្នង បានកសាងសាលារៀន ៣ ខ្នង មានថ្នាក់រៀន ៦ និងសុំបើកសាលានេះរៀននៅក្នុងវត្ត ។

ដោយគុណបំណាច់ដែលបានបង្កើតសាលារៀននេះ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ទ្រង់ប្រទានមេដៃយ៍ អស្សប្ញទ្ធិមុនីសារភ័ន កាលពីថ្ងៃ ៣ ១១ ១២ ឆ្នាំឆ្លូវ ឯកស័ក ព.ស. ១៤៩២ ត្រូវនឹងថ្ងៃ ១ ខែវិច្ឆិកា ១៩៤១ ។

## អំពីអនិច្ចធម្ម

ព្រះគ្រូញាណទេពាចារ្យព្រះនាមបិតញាណោ ប៊ុយ ទី ជាមហាថេរ មួយអង្គក្នុងចំណោមមហាថេរទាំងឡាយ ដែលមានគុណសម្បទ ចរិយា-សម្បទ និងសមត្ថភាពគ្រប់គ្រាន់ ៗ ស្រាប់តែដល់ថ្ងៃ ១ កើត ខែជេស្ឋ ឆ្នាំថោះបញ្ចស័ក ព.ស. ២០៥៦ ក្នុងព្រះជន្មាយុ ៨១ ឆ្នាំ មច្ចុសេនា ចូលមកបៀតបៀនករជ្ជកាយរបស់លោកគ្មានគោតញញើតសោះ បណ្តា សិស្សានុសិស្សទាំងអស់ស្វែងរកគ្រូពេទ្យ ប្រកបឱសថដ៏ចំណាន ៗ ប៉ុន្មានណាក៏ដោយ មច្ចុសេនាធ្វើហាក់ដូចជាគថ្លង់គ្មានស្តាប់ៈ តែបន្ត សកម្មភាពរបស់ខ្លួនរៀងរាល់ថ្ងៃ ដរាបមកដល់ថ្ងៃពុធ ៦ កើតខែកត្តិក ឆ្នាំ ថោះបញ្ចស័ក ព.ស. ២៥០៦ វេលាម៉ោង ៨ និង ៥០ នាទីយប់ ក្នុងព្រះ-ជន្មាយុ ៨១ ឆ្នាំ ស្តេចមច្ចុរាជកំណាចមកចាប់ដណ្តើមយកជីវិតិន្ទ្រិយរបស់ ព្រះតេជព្រះគុណអង្គនេះ ពីកណ្តាលជំនុំសិស្សានុសិស្សឥតគោតញញើត ឡើយ ៗ បន្ទាប់ពីអនិច្ចធម្មមក យើងខ្ញុំជាសិស្សានុសិស្ស និងគណៈ កម្មការសម្រាប់វត្ត បានធ្វើចុតហ្មាយមួយច្បាប់ថ្វាយសម្តេចព្រះសង្ឃរាជ ដើម្បីថ្វាយដំណឹងអនិច្ចធម្មនេះ សម្តេចទ្រង់ជ្រាបក្រាមបានប្រទានបច្ច័យ ៥០០៛ មកចូលក្នុងបុណ្យសពនេះ ៗ

ចាប់តាំងពីថ្ងៃអនិច្ចធម្មនៃព្រះតេជព្រះគុណអង្គនេះមក យើងខ្ញុំជា សិស្សានុសិស្ស បាននាំគ្នាធ្វើទក្ខិណានុប្បទាន ឧទ្ទិសកុសលប្រគេន

ដល់វិញ្ញាណក្ខន្ធ របស់ព្រះអង្គលោកវៀងពល់ថៃសីល ។

យើងខ្ញុំជាសិស្ស និង គណៈកម្មការបុណ្យ មានព្រះគ្រូ សំវរវិន័យ ដើក ហុម ចៅអធិការវត្តពោធិយារាមជាប្រធានលោកគ្រូ កុន វត្តព្រែកក្របៅ, លោកគ្រូ ស្វាយ សុន វត្តមង្គលរតនារាម, ព្រះបាល័ដ្ឋកមរាវត្ត ព្រះស្រីសារពេជ្ញ, ព្រះបាល័ដ្ឋព្រហ្មវិជ្ជាវត្តបទុមវតី ជាអនុប្រធាន បាន មូលមតិជាឯកច្ឆន្ទកំណត់ធ្វើបុណ្យឈាបនកិច្ចព្រះសព ចាប់តាំងពីថ្ងៃ ១៩ កុម្ភៈ ឆ្នាំ ១៩៦៥ រហូតដល់ថ្ងៃ ២១ ខែឆ្នាំដដែលទើបចប់កម្មវិធីបុណ្យ ។

សូមអំណរគុណព្រះតេជព្រះគុណព្រះមហាព្រហ្មមុនី ឡុង ណាវ លោកយកព្រះទ័យទុកដាក់ជួយគួបតែងគិតគូរតាំងពី ៦ ឆ្នាំមុន បានសុំក្តារម្ឈូសតម្កល់សពនេះពីថៅកែ គីម ឡុង យកមកបំរុងទុក លោកគ្រូបាល័ដ្ឋ ជួង ចន បានជួយដឹកនាំពីភ្នំពេញមកដល់វត្តនេះ តាំងពីឆ្នាំ ១៩៦០ ។ លោកគ្រូបាល័ដ្ឋព្រហ្មវិជ្ជា ហែម សាយឿន លោកគ្រូបាល័ដ្ឋ សុក សារិទ្ធ លោកគ្រូបាល័ដ្ឋ នុម អន លោកបានជួយទំនុកបំរុង ជាមេភ្លើង និងនិមន្ត មកជួយរៀបចំដោយព្រះអង្គលោក តាំងពីជាវមករហូត ដល់ពេលធ្វើ បុណ្យនេះ ។

កុសលបុញ្ញរាសីដែលកើតឡើង អំពីធ្វើបុណ្យឈាបនកិច្ចនេះ សូម ថ្វាយចំពោះសម្តេចព្រះសង្ឃរាជជាព្រះបិតាសង្ឃ សូមព្រះអង្គប្រកបតែ នូវសេចក្តីសុខ ប្រាសចាករោគាព្យាធិ សូមមានព្រះជន្មាយុជាងរយ

ព្រះវស្សា សូមប្រគេនចំពោះព្រះថេរានុថេរៈ និងជូនព្រះតេជព្រះគុណ, ឯកឧត្តម លោកជំទាវ, លោកស្រី, លោកអ្នក, លោកអាចារ្យ ឧបាសក ឧបាសិកា ដែលបាននិមន្តអញ្ជើញមកជាអធិបតីក្នុងពិធីនេះ សូមឲ្យប្រកបតែនូវសេចក្ដីសុខចំរើន គ្រប់ពេលវេលា និងប្រកបដោយពុទ្ធពរ ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

---

## សុន្ទរកថា

សហជីវិន ប៉ិន្ន សុន
នាយកមន្ត្រីក្រសួងធម្មការ

សូមថ្វាយព្រះករុណាគ្រប់ព្រះអង្គ និងជំរាបលោក-អ្នកពុទ្ធបរិស័ទទាំងឡាយ

សូមជ្រាប ។

ឆ្លៀតក្នុងឱកាសនេះ សម្ដេចព្រះសុធម្មាធិបតីព្រះសង្ឃរាជជាអម្ចាស់ បានទ្រង់ព្រះមេត្តាប្រោសតែងតាំងព្រះបាឡាត់ កមរា ប្រាក់ ជុក ឆាយា បិតសីលោ ជន្មាយុ ៥៦ វស្សា ៣៦ នៅវត្តព្រះស្រីសារពេជ្ញ ឃុំឆាយ ស្រុកបាភ្នំ ខេត្តព្រៃវែង ឲ្យធ្វើជាចៅអធិការវត្តនេះ និងជាព្រះឧបជ្ឈាយ៍ មានសមណស័ក្តិជាព្រះគ្រូវិសុទ្ធិញាណ ទីបានានុក្រមជាមន្ត្រីកិត្តិយស ជាបន្ទាប់អំពីព្រះសពព្រះគ្រូញាណទេពាចារ្យ ប៊ូយ ទី អតីតចៅអធិការដែលបានទទួលអនិច្ចធម្មទៅហើយនេះ ឲ្យស្របទៅតាមសេចក្ដីត្រូវការរបស់

លោក-អ្នកទាំងឡាយបន្តទៅទៀត ដោយមានរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនសិក្សាធិការយល់ព្រមផង ព្រោះព្រះអង្គទ្រង់បានសង្កេតឃើញថា ព្រះបាឡាត់អង្គនេះជាថេរៈមួយរូប ដែលមានវស្សាយុកាលចាស់ជាងព្រះសង្ឃទាំងពួងក្នុងវត្តនេះទាំងមានគុណសម្បត្តិ សមត្ថភាព និងបំណេះវិជ្ជាផ្លូវលោក ផ្លូវធម៌ ល្មមដឹកនាំពួកសព្រហ្មចារី (ភិក្ខុ សាមណេរ) ឧបាសក ឧបាសិកា ឲ្យត្រេកអររីករាយជ្រះថ្លា ក្នុងការបំពេញបុណ្យកុសល ធម្មចរិយា សម្មាបដិបត្តិផ្សេង ៗ តាមបាន ៗ ទាំងជាអ្នកមានអធ្យាស្រ័យ សុភាពរៀបរយត្រជាក់ត្រជុំសមរម្យជាទីជ្រកកោននៃពួកពុទ្ធបរិស័ទបាន និងមានសេចក្ដីឧស្សាហ៍ព្យាយាមក្នុងការបំពេញករណីយកិច្ចផ្សេង ៗ ដែលជាប្រយោជន៍ដល់សាសនានិងប្រទេសជាតិ មានការជួយសាង សាលា វិហារ ជាដើម ដូច្នេះសូមលោក-អ្នកពុទ្ធបរិស័ទទាំងឡាយមានសេចក្ដីសោមនស្សរីករាយក្នុងការដែលព្រះថេរៈអង្គនេះ បានឡើងឋានៈ ជាព្រះចៅអធិការនេះ ហើយសូមតាំងចិត្តជឿស្ដាប់និងធ្វើតាមពាក្យណែនាំទូន្មានប្រៀនប្រដៅរបស់លោកដែលប្រកបដោយធម្មវិន័យ និងត្រឹមត្រូវតាមព្រះច្បាប់សម្រាប់រដ្ឋ ដើម្បីសេចក្ដីសុខចំរើន និងសាមគ្គីធម៌ដ៏ជាមូលដ្ឋាននៃសេចក្ដីសុខសន្តិភាព និងការតាំងនៅនៃព្រះពុទ្ធសាសនាជាស្ថាពរតរៀងទៅ ។

ម្យ៉ាងទៀតខ្ញុំព្រះករុណា មានសេចក្ដីសង្ឃឹមថា ព្រះថេរៈអង្គនេះ

មុខជាទីនយកព្រះទ័យទុកដាក់បំពេញសកម្មភាពក្នុងករណីយកិច្ចផ្សេង ៗ ដែលជាមុខងារ នាទី របស់លោកឲ្យបានសម្រេចលទ្ធផលប្រកបដោយជោគជ័យគ្រប់ប្រការ ទាំងខាងផ្លូវលោកនិងផ្លូវធម៌ជាមិនខាន ។

នៅទីបំផុតនេះ ខ្ញុំព្រះករុណាសូមប្រគេន សព្ទសាធុការពរដល់ព្រះថេរៈចៅអធិការថ្មីនេះ សូមឲ្យបានប្រកបដោយពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍តរៀងទៅកុំបីខានឡើយ ។

សូមព្រះពុទ្ធសាសនា ដែលជាពន្លឺរស្មីនៃសេចក្ដីសុខសន្តិភាពតាំងនៅក្នុងលោក អស់កាលជាយូរអង្វែង ជាងប្រាំពាន់ព្រះវស្សា ។

---

សេចក្ដីថ្លែងព្រះរាជអំណរព្រះគុណចំពោះសម្ដេច
ព្រះសង្ឃរាជ ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ១៩៦៨

ថ្លែងដោយព្រះបាឡាត់ភមរា ប្រាក់ -ថុក

សូមព្រះតេជះតម្កល់លើត្បូង

ទូលព្រះបង្គំជាខ្ញុំ សូមក្រាបថ្វាយបង្គំទទួលនូវព្រះអំណរព្រះ-គុណដ៏ធ្ងន់ នៃសម្ដេចជាម្ចាស់ដែលទ្រង់សព្វព្រះរាជហឫទ័យតែងតាំងរូបទូលព្រះបង្គំជាខ្ញុំ ឲ្យធ្វើជាចៅអធិការ ធ្វើជាព្រះឧបជ្ឈាយ៍ និងតាំងឲ្យមានសមណសក្តិជាព្រះគ្រូវិសុទ្ធិញាណមន្ត្រីកិត្តិយសទីបានា ដើម្បីគ្រប់គ្រងរក្សាទីអារាម ទ្រព្យគរុភណ្ឌ ព្រមទាំងភិក្ខុ សាមណេរ ឧបាសក-ឧបាសិកា វត្តព្រះស្រីសារពេជ្រ និងឲ្យបព្វជ្ជា ឧបសម្បទដល់កុលបុត្តខាង

គណៈធម្មយុត្តិកទៅ សូមទ្រង់ព្រះមេត្តាប្រោស! ដើម្បីសំដែងនូវបដិការៈ ឲ្យសមទឹងកិត្តិយសដ៏ខ្ពង់ខ្ពស់ ដែលសម្ដេចជាអម្ចាស់ទ្រង់ប្រោសព្រះរាជទានដល់ព្រះបង្គំជាខ្ញុំនេះ ទូលព្រះបង្គំជាខ្ញុំ សូមប្ដេជ្ញាជាថ្មីឡើងទៀតចំពោះព្រះភក្ត្រសម្ដេចជាអម្ចាស់ថា: ខំយកចិត្តទុកដាក់គោរពបដិបត្តិតាមធម៌វិន័យ បំរើព្រះពុទ្ធសាសនា ស្ថិតនៅក្រោមព្រះកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់នៃសម្ដេចជាអម្ចាស់ឲ្យអស់អំពីសមត្ថភាពដរាបល្អុះត្រាតែអវសាននៃជីវិត ។

ម្យ៉ាងទៀត ខ្ញុំព្រះករុណា អាត្មាភាព សូមថ្លែងនូវអំណរគុណចំពោះព្រះថេរានុថេរៈគ្រប់ព្រះអង្គ ព្រមទាំងឯកឧត្តម ព្រះតេជព្រះគុណ និងលោកអ្នកឧបាសក-សិកា ទាំងអស់ ដែលបានសំដែងនូវកាយវិការប្រកបដោយសមានចិត្តសោមនស្សរីករាយ ចំពោះការដែលសម្ដេចជាអម្ចាស់ទ្រង់តែងតាំងខ្ញុំព្រះករុណា អាត្មាភាព ឲ្យធ្វើជាចៅអធិការនិងព្រះឧបជ្ឈាយ៍នេះ ខ្ញុំព្រះករុណា អាត្មាភាព សូមអរគុណជាទីបំផុតហើយសូមមេត្តាជួយទំនុកបំរុងដល់ខ្ញុំព្រះករុណា អាត្មាភាព នៅក្នុងវិស័យតាមគន្លងព្រះពុទ្ធសាសនា ឲ្យបានចរុងចំរើនរុងរឿងតាមមធ្យោបាយដ៏ប្រសើរ ដែលព្រះថេរានុថេរៈគ្រប់ព្រះអង្គ ព្រមទាំងឯកឧត្តម ព្រះតេជៈព្រះគុណ និងលោកអ្នកសប្បុរសទាំងអស់ធ្លាប់មានការពិសោធន៍មកហើយ ដល់ខ្ញុំព្រះករុណាអាត្មាភាពផង ។

សូមអរព្រះតេជព្រះគុណ សូមអរគុណ ។